ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# ពិធីសារជាតិ
# ស្តីពី
# ការពិនិត្យមរណភាពមាតា និងទារក
# ជុំវិញកំណើត និងការឆ្លើយតប

ឆ្នាំ ២០២៥

# បុព្វកថា

កម្ពុជាសម្រេចបានជោគជ័យដ៏សំខាន់ៗ ក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ អត្រាមរណភាពកុមារក្រោមអាយុ៥ឆ្នាំ និងកុមារទើបនឹងកើតបានធ្លាក់ចុះច្រើនជាងពាក់កណ្តាលចន្លោះឆ្នាំ២០១៤ ដល់ ២០២១-២២ គឺពី ៣៥ ចុះនៅត្រឹម១៦ និងពី១៨ ចុះនៅត្រឹម៨ ក្នុងចំណោមកំណើតរស់ ១០០០ នាក់ជាលំដាប់។ ស្ត្រីដែលជាមាតាចំនួន ៩៧,៥ %បានសម្រាលកូនជាមួយបុគ្គលិកជំនាញ និងនៅមូលដ្ឋានសុខាភិបាល។ ទោះជាយ៉ាងណាអត្រាមរណភាពមាតា (MMR) ស្ថិតនៅកម្រិតដដែលក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ គឺ១៥៤ ក្នុងចំណោមកំណើតរស់ចំនួន ១០០ ០០០ នាក់ តាមរបាយការណ៍អង្កេតប្រជាសាស្ត្រឆ្នាំ២០២១-២០២២ ដែលអត្រាមរណភាពនេះធ្វើឱ្យប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេស ដែលមានអត្រាមរណភាពមាតាខ្ពស់បំផុតក្នុងតំបន់ ក្នុងខណៈការសម្រាលកូនដោយបុគ្គលិកជំនាញកើនឡើងក៏ដោយ។

ការផ្តល់សេវាសុខាភិបាលមានការរីកចម្រើនគួរឱ្យកត់សំគាល់ ប៉ុន្តែការខិតខំបន្ថែមត្រូវការជាចាំបាច់ដើម្បីកែលម្អគុណភាព នៃការថែទាំ កាត់បន្ថយបានបន្ថែមទៀតអត្រាមរណភាពមាតា និងរក្សាវឌ្ឍនភាព នៃសុខភាពទារក និងកុមារ ការប្រឹងប្រែងនេះតម្រូវឱ្យមានទាំងយន្តការកែលម្អគុណភាព (QI) ដើម្បីតាមដានជាប្រចាំក៏ដូចជាការគាំទ្រក្នុងការអនុវត្តការងារកែលម្អ ។

ការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប (MPDSR) រួមបញ្ចូលការតាមដានបែបគុណភាពចុះអង្កេតស៊ីជម្រៅទាក់ទងនឹងមូលហេតុ និងស្ថានភាពដែលពាក់ព័ន្ធនឹងការស្លាប់មាតា និងទារកទាំងនៅក្នុងមូលដ្ឋានសុខាភិបាល ឬនៅសហគមន៍។ ដំណើរការនេះគឺជាផ្នែកសំខាន់ នៃកិច្ចខិតខំប្រឹងប្រែងកែលម្អគុណភាព ដើម្បីកាត់បន្ថយមរណភាពមាតា និងទារកនៅក្នុងផ្ទៃ និងទារកទើបនឹងកើត ដែលអាចទប់ស្កាត់បានតាមរយៈការត្រួតពិនិត្យករណីមរណភាព និងប្រើប្រាស់ក្នុងការអភិវឌ្ឍផែនការសកម្មភាពជាក់លាក់ និងដែលអាចធ្វើបាន ដើម្បីបំពេញចន្លោះខ្វះខាតក្នុងការទទួលបានការថែទាំប្រកបដោយគុណភាព ។

ការអនុវត្ត MPDSR ដោយផ្អែកលើគោលការណ៍ស្នូលមួយចំនួនដើម្បីធានាបានទាំងប្រសិទ្ធភាព សុចរិត និងមានផលជះជាវិជ្ជមានលើប្រព័ន្ធសុខាភិបាល។ ជាមួយនឹងកិច្ចសហការដ៏រឹងមាំ និងការរៀនសូត្រចែករំលែកព័ត៌មានអាចកាត់បន្ថយដំណើរការដែលធ្វើស្មួនគ្នា និងពង្រឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីទប់ស្កាត់មរណភាពមាតា និងទារកដែលអាចបង្ការបាន។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញថ្ងៃទី ៣០ ខែ[illegible] ឆ្នាំ ២០២៥

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាន រ៉ា**



[1] Cambodia Demographic and Health Surveys 2014 & 2021/22.

# សេចក្ដីថ្លែងអំណរគុណ

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណដល់ **លោកជំទាវសាស្ត្រាចារ្យ អ៊ឹម សិទ្ធិភារ្យ** រដ្ឋលេខាធិការ ក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការសម្របសម្រួលក្នុងការពង្រឹងគុណភាពថែទាំព្យាបាលសុខុមាលភាព មាតា ទារក កុមារ និងរោគស្ត្រី ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំក្នុងដំណើរអភិវឌ្ឍពិធីសារជាតិនេះ ។

សូមថ្លែងអំណរគុណដល់ក្រុមការងារពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើតនិងការឆ្លើយតបដែលមាននាយកដ្ឋានដែលពាក់ព័ន្ធ នៃក្រសួងសុខាភិបាល ក្រុមការងារអញ្ជើញមកពី មន្ទីរសុខាភិបាលខេត្តបាត់ដំបង កំពង់ចាម សៀមរាប ពោធិ៍សាត់ និងរតនគិរី តំណាងមកពីមន្ទីរពេទ្យឯកជន គណៈវិជ្ជាជីវៈ សមាគមវិជ្ជាជីវៈ និងអង្គការដៃគូរអភិវឌ្ឍន៍សុខាភិបាល ដែលបានដាក់ធាតុចូលដ៏មានតម្លៃដែលធ្វើឱ្យពិធីសារនេះ កាន់តែគ្រប់ជ្រុងជ្រោយ។

លើសពីនេះសូមថ្លែងអំណរគុណដល់ មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន និងអង្គការសុខភាពពិភពលោកប្រចាំតំបន់ និងនៅប្រទេសកម្ពុជាដែលបាន ផ្ដល់ទាំងបច្ចេកទេស និងថវិកាក្នុងដំណើរការអភិវឌ្ឍន៍ និងបោះពុម្ពនូវឯកសារដ៏មានសារសំខាន់នេះ។ ឯកសារនេះពិតជាមានសារៈសំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីទប់ស្កាត់មរណភាពមាតាដែលអាចបង្ការបាន និងធ្វើឱ្យសុខភាពស្ត្រី និងកុមារកាន់តែប្រសើរនៅទូទាំងប្រទេសកម្ពុជា។

# មាតិកា


បុព្វកថា ........ 2

សេចក្តីថ្លែងអំណរគុណ ........ 3

បញ្ជីរាយនាមក្រុមការងារគ្រប់គ្រងនិងដឹកនាំបញ្ចប់សេចក្តីព្រាង MPDSR ........ 6

អក្សរកាត់ និងពាក្យបំព្រួញ ........ 10

1. សេចក្តីផ្តើម ........ 11

2- និយមន័យ ........ 13

3- គោលការណ៍សំខាន់ៗ នៃការពិនិត្យមរណភាពមាតា និងទារកជុំវិញ កំណើត និងការឆ្លើយតប (MPDSR) 15

3.1- រក្សាការសម្ងាត់ ........ 15

3.2 - គ្មានការស្តីបន្ទោស ៖ « គ្មានការស្តីបន្ទោស» មិនមែនមានន័យថា «មិនទទួលខុសត្រូវ» ........ 15

4- ការផ្សារភ្ជាប់ជាមួយប្រព័ន្ធព័ត៌មាន ........ 17

5- ការផ្សារភ្ជាប់ជាមួយការកែលម្អគុណភាព (QI) ........ 19

6- រចនាសម្ព័ន្ធ នៃការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប ........ 21

6.1 លក្ខខណ្ឌយោងសម្រាប់គណៈកម្មាការថ្នាក់ជាតិ ........ 23

6.2 លក្ខខណ្ឌយោងរបស់គណៈកម្មាការថ្នាក់ខេត្ត ........ 25

6.3 លក្ខខណ្ឌយោងរបស់គណៈកម្មាការថ្នាក់មន្ទីរពេទ្យ ........ 28

7- ជំហាន នៃការតាមដាន និងឆ្លើយតបចំពោះមរណភាពមាតា និងទារកជុំវិញកំណើត ........ 32

7.1 កំណត់អត្តសញ្ញាណករណី ........ 33

7.2 ការប្រមូលទិន្នន័យ ឬព័ត៌មាន ........ 33

7.3 ការពិនិត្យរួមគ្នាករណីមរណភាពមាតា និងទារកជុំវិញកំណើត ការវិភាគព័ត៌មាន និងផ្តល់អនុសាសន៍ ... 36

7.4 អនុវត្តសកម្មភាពដើម្បីការកែលម្អ ........ 39

7.5 តាមដានការអនុវត្តការងារ MPDSR និងការកែលម្អគុណភាព នៃការថែទាំ ........ 39

8- ការតាមដាន និងឆ្លើយតបចំពោះមរណភាពមាតា និងទារកជុំវិញ កំណើតក្នុងអំឡុងពេលមានគ្រោះមហន្តរាយ ........ 41

ឧបសម្ព័ន្ធ ........ 43

ឧបសម្ព័ន្ធទី ១ ៖ តារាងតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាការ MPDSR ថ្នាក់មន្ទីរពេទ្យ ថ្នាក់ខេត្ត និងថ្នាក់ជាតិ ........ 43
ឧបសម្ព័ន្ធទី ២ ៖ លិខិតជូនដំណឹង និងបញ្ជាក់មូលហេតុមរណភាព ........ 46
ឧបសម្ព័ន្ធទី ៣ ៖ ទម្រង់ពិនិត្យករណីមរណភាពមាតា ........ 50
ឧបសម្ព័ន្ធទី ៤ ៖ ទម្រង់ពិនិត្យករណីមរណភាពទារកជុំវិញការសម្រាល ........ 57
ឧបសម្ព័ន្ធទី ៥ ៖ និយមន័យមូលហេតុមរណភាព ........ 61
ឧបសម្ព័ន្ធទី ៦ ៖ ក្រមសីលធម៌សម្រាប់ការប្រជុំ ........ 66
ឧបសម្ព័ន្ធទី 7 ៖ ទម្រង់របាយការណ៍ប្រជុំពិនិត្យរួមគ្នាករណីមរណភាព និងផែនការសកម្មភាព ........ 67
ឧបសម្ព័ន្ធទី ៨ ៖ ទម្រង់សង្ខេបរបាយការណ៍ប្រចាំខែរបស់មូលដ្ឋានសុខាភិបាល ........ 69
ឧបសម្ព័ន្ធទី ៩ ៖ កត្តារួមចំណែកដែលអាចកែប្រែបាន (រៀបចំនៅក្នុងគំរូការពន្យារពេលបី) ........ 72
ឧបសម្ព័ន្ធទី ១០ ៖ វិញ្ញាបនប័ត្រវេជ្ជសាស្ត្រនៃមូលហេតុនៃការស្លាប់ (សេណារីយ៉ូ 1 - ធ្លាក់ឈាមក្រោយសម្រាល) ........ 73
ឧបសម្ព័ន្ធទី ១១ ៖ បញ្ជីរាយនាមអ្នកចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងពិធីសារជាតិ MPDSR ........ 74

## បញ្ជីរាយនាមក្រុមការងារគ្រប់គ្រងនិងដឹកនាំបញ្ចប់សេចក្តីព្រាង MPDSR

| | | |
|---|---|---|
| ១. លោកជំទាវសាស្ត្រាចារ្យ | **អ៊ឹម សិទ្ធិភារ៉ា** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ២. លោកជំទាវសាស្ត្រាចារ្យ | **គ្រុយ លាងស៊ីម** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៣. លោកជំទាវសាស្ត្រាចារ្យ | **ឧុង រដ្ឋាវី** | ទីប្រឹក្សាក្រសួងសុខាភិបាល |
| ៤. លោកស្រីសាស្ត្រាចារ្យជំនួយ | **គីម រ័ត្ននា** | នាយកមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| ៥. លោកស្រីវេជ្ជបណ្ឌិត | **ជាង កន្និដ្ឋា** | អង្គការសុខភាពពិភពលោក WHO |
| ៦. លោកវេជ្ជបណ្ឌិត | **សុខ សុគន្ធ** | អង្គការ UNFPA |
| ៧. លោក | **ខួន ប្រុស** | អង្គការ UNFPA |
| ៨. លោកស្រី | **សំអុល ចន្ទណា** | USAID EQHA II FHI360 |
| ៩. លោកស្រីវេជ្ជបណ្ឌិត | **គ្រៀល ដាវ៉ា** | USAID EQHA II FHI360 |
| ១០. លោកវេជ្ជបណ្ឌិត | **មាន រតនសម្បត្តិ** | Vital Strategies |
| ១១. លោកវេជ្ជបណ្ឌិត | **YOKOBORI Yuta** | JICA |

## គណៈកម្មការថ្នាក់ជាតិពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប ក្នុងព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**ប្រការ១._**

ត្រូវបង្កើតគណៈកម្មាធិការជាតិពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប ដែលមានសមាសភាពខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោកជំទាវសាស្ត្រ. | **អ៊ឹម សិទ្ធិភារៀ** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ប្រធាន |
| ២- លោកជំទាវសាស្ត្រ. | **ក្រុយ លាងស៊ីម** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៣- លោកស្រីសាស្ត្រ.ជំ. | **តឹម វ័ត្ថនា** | នាយកមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក | អនុប្រធាន |
| ៤- លោកជំទាវសាស្ត្រ. | **ទុង រដ្ឋាវី** | ទីប្រឹក្សាក្រសួងសុខាភិបាល | សមាជិក |
| ៥- ឯកឧត្តមសាស្ត្រ. | **សាន់ ច័ន្ទសឿន** | ទីប្រឹក្សាក្រសួងសុខាភិបាល | សមាជិក |
| ៦- លោកស្រីសាស្ត្រ.ជំ. | **ស៊ុយ សុវណ្ណធីតា** | អគ្គនាយកនាយករងបច្ចេកទេសសុខាភិបាល | សមាជិក |
| ៧- លោកសាស្ត្រ.ជំ. | **កុយ វីរីយ៉ា** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ៨- លោកស្រីសាស្ត្រ.ជំ. | **ខួន យ៉ាំណែត** | នាយករងមន្ទីរពេទ្យគន្ធាបុប្ផា | សមាជិក |
| ៩- លោកវេជ្ជ. ឯក. | **រស់ សាផាត** | ប្រធានផ្នែកបណ្តុះបណ្តាល មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក | សមាជិក |
| ១០- លោកវេជ្ជបណ្ឌិត | **អ៊ុយ គីណា** | ប្រធានផ្នែកសម្ភព និងរោគស្ត្រី នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | សមាជិក |
| ១១- លោកស្រីសាស្ត្រ.ជំ. | **ជួង សុខណែត** | អនុប្រធានផ្នែកសម្ភពនៃមន្ទីរពេទ្យកាល់ម៉ែត | សមាជិក |
| ១២- លោកស្រីវេជ្ជ.ឯក. | **ជួប កែវសំណាង** | នាយរងមន្ទីរពេទ្យព្រះអង្គឌួង | សមាជិក |
| ១៣- លោកវេជ្ជ.ឯក. | **ចិន ស័កវិសិដ្ឋ** | មន្ត្រីផ្នែកប្រពោធនកម្មទារកនៃមន្ទីរពេទ្យកាល់ម៉ែត | សមាជិក |
| ១៤- លោកវេជ្ជ. | **ម៉ែន ដាលី** | មន្ត្រីផ្នែកប្រពោធនកម្មទារកនៃមន្ទីរពេទ្យកាល់ម៉ែត | សមាជិក |
| ១៥- លោកស្រីវេជ្ជ. | **សៀង លំអងគន្ធា** | ប្រធានកម្មវិធីជាតិសុខភាពបន្តពូជ នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក | សមាជិក |
| ១៦- កញ្ញា | **ខួន សុភាព** | ប្រធានគណៈធ្មបកម្ពុជា | សមាជិក |

| | | | |
|---|---|---|---|
| ១៧- លោក | **ជា សុភ័ក្រមុនីរ័ត្ន** | ប្រធានគណៈគិលានុបដ្ឋាក | សមាជិក |
| ១៨- លោកស្រីអនុ. | **ឈិន សុខណាយ** | អនុប្រធានគណៈកម្មការថែទាំ នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក | សមាជិក |
| ១៩- លោកវេជ្ជ. | **ខ៉ែត ប៉ាធី** | ប្រធានផ្នែកសណ្តំនៃមន្ទីរពេទ្យកាល់ម៉ែត | សមាជិក |
| ២០- លោកវេជ្ជ.ឯក. | **សាយ សារិទ្ធ** | ជំនួយការប្រធានផ្នែកសណ្តំ នៃមន្ទីរពេទ្យកាល់ម៉ែត | សមាជិក |
| ២១ តំណាងអង្គការដៃគូអភិវឌ្ឍន៍ UNFPA, WHO, UNICEF | | | សមាជិក |

**គណៈកម្មការថ្នាក់ជាតិមានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- ពិនិត្យមើលរបាយការណ៍ថ្នាក់ខេត្តទាំងអស់។
- វិភាគទិន្នន័យដើម្បីកំណត់ពីលំនាំ និងនិន្នាការនៃមរណភាពរបស់មាតា និងទារកជុំវិញកំណើត ផ្តល់ព័ត៌មានត្រឡប់ដល់ថ្នាក់ខេត្ត និងមន្ទីរពេទ្យជាតិ កម្មវិធីជាតិ និងនាយកដ្ឋាននានារបស់ក្រសួងសុខាភិបាល។ កែលម្អគុណភាព និងអនុវត្តផែនការសកម្មភាពដើម្បីកែលម្អគុណភាពសេវាជាប្រចាំ។
- សម្របសម្រួលការបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- រៀបចំរបាយការណ៍ប្រចាំឆ្នាំសម្រាប់ចែកចាយជាមួយក្រុមការងារ។
- ផ្តល់អនុសាសន៍សម្រាប់ការអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រដើម្បីកាត់បន្ថយមរណភាពមាតាជុំវិញកំណើត។
- ធានាការសម្ងាត់ និងការការពារទិន្នន័យអ្នកជំងឺក្នុងអំឡុងពេលដំណើរការពិនិត្យឡើងវិញ។

**ភាពញឹកញាប់នៃកិច្ចប្រជុំ**

- គណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបថ្នាក់ជាតិនឹងជួបប្រជុំរៀងរាល់ត្រីមាស ដើម្បីពិនិត្យទៅលើរបាយការណ៍តាមខេត្ត និងតាមមន្ទីរពេទ្យជាតិ និងតាមដានគុណភាពផ្តល់សេវា ការធ្វើផែនការ និងដំណើរការសកម្មភាព។
- ក្នុងករណីចាំបាច់ ការប្រជុំបន្ទាន់នឹងត្រូវរៀបចំឡើង។

**ការរាយការណ៍ និងគណនេយ្យភាព**

- គណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប ធ្វើរបាយការណ៍ប្រចាំឆ្នាំ ដោយបញ្ជាក់ពីរបកគំហើញសំខាន់ៗ អនុសាសន៍ និងវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព។

### រក្សាការសម្ងាត់

- សមាជិកទាំងអស់នៃគណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប ត្រូវតែរក្សាការសម្ងាត់ចំពោះព័ត៌មានណាដែលទាក់ទងនឹងមរណភាព និងទិន្នន័យដែលរសើបដែលបានពិភាក្សាក្នុងអំឡុងពេលពិនិត្យករណីមរណភាព។
- ដើម្បីពង្រឹងការងារនេះ ការរក្សាការសំងាត់ និងគោលការណ៍មិនមែនចាប់កំហុស ត្រូវតែបញ្ជាក់ឡើងវិញនៅរាល់ពេលចាប់ផ្ដើមការប្រជុំរបស់គណៈកម្មាការ។

### ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ

- គណៈកម្មាការ នឹងវាយតម្លៃជាប្រចាំនូវប្រសិទ្ធភាពការងារ ដោយពិនិត្យមើលការអនុវត្តផែនការសកម្មភាព និងផលប៉ះពាល់លើការកាត់បន្ថយអត្រាមរណភាពរបស់មាតា និងទារកជុំវិញកំណើត។

### ប្រការ២._

ត្រូវបានតែងតាំងលេខាធិការដ្ឋានសម្រាប់ គណៈកម្មាធិការថ្នាក់ជាតិពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប ដែលមានសមាសភាពខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោកសាស្ត្រាចារ្យជំ. | **ភុយ វីរីយ៉ា** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | ប្រធាន |
| ២- លោកវេជ្ជ. ឯកទេស | **រស់ សារ៉ាផាត** | ប្រធានផ្នែកបណ្តុះបណ្តាល | អនុប្រធាន |
| ៣- លោកស្រីសាស្ត្រ.ជំ. | **ជួន សុខណៃត** | អនុប្រធានផ្នែកសម្ភព | សមាជិក |
| ៤- លោកវេជ្ជ.ឯកទេស | **ប៊ិន ស័ក្តិសិដ្ឋ** | មន្រ្តីផ្នែកប្រពោធនកម្មទារក | សមាជិក |
| ៥- លោកស្រីអនុបណ្ឌិត | **ឈិន សុខណាយ** | អនុប្រធានគណៈកម្មការថែទាំ | សមាជិក |
| ៦- តំណាងអង្គការដៃគូអភិវឌ្ឍន៍ UNFPA, WHO, UNICEF | | | សមាជិក |

**តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋានរួមមាន៖**

- លេខាធិការដ្ឋាននេះនឹងត្រូវបានគាំទ្រពីមន្ត្រីជំនួយបន្ថែមទៀតដើម្បីតាមដានទិន្នន័យ និងជួយក្នុងដំណើរការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប។
- ត្រួតពិនិត្យតាមដាន និងជួយក្នុងការរៀបចំកិច្ចប្រជុំគណៈកម្មាការជាតិ MPDSR ដើម្បីធានាថាកិច្ចប្រជុំត្រូវបានធ្វើឡើងដោយទាន់ពេលវេលា ហើយរបាយការណ៍ត្រូវបានដាក់ជូនទាន់ពេលវេលានិងសមស្រប
- សម្របសម្រួលកម្មវិធីបណ្តុះបណ្តាលនានានៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងស្រុក។ ជួយក្នុងការអភិវឌ្ឍន៍នូវវគ្គសិក្សា និងម៉ូឌុលដែលសមស្រប
- សម្របសម្រួលប្រតិបត្តិការ និងការស្រាវជ្រាវ។
- សម្របសម្រួលសកម្មភាពផ្សេងៗទៀតដែលទាក់ទងនឹង MPDSR ដែលប្រធានគណៈកម្មាការស្នើសុំ។

## អក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| CRVS | ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន |
| DHIS-2 | ប្រព័ន្ធព័ត៌មានសុខាភិបាលស្រុកប្រតិបត្តិ |
| DHS | នាយកដ្ឋានមន្ទីរពេទ្យ |
| DPHI | នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល |
| EmONC | សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបកើត |
| HC | មណ្ឌលសុខភាព |
| HMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល |
| ICU | ផ្នែកប្រពោធនកម្ម |
| MCCDs | លិខិតវេជ្ជសាស្ត្របញ្ជាក់មូលហេតុមរណភាព |
| MCH | សុខភាពមាតា និងទារក |
| MMR | អត្រាមរណភាពមាតា |
| MOH | ក្រសួងសុខាភិបាល |
| MOI | ក្រសួងមហាផ្ទៃ |
| MPDSR | ការស្រាវជ្រាវមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប |
| NCOD | ប្រព័ន្ធចុះទិន្នន័យសុខាភិបាលឌីជីថលលិខិតជូនដំណឹងអំពីមរណភាព |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NICU/NCU | ផ្នែកពោធនកម្មទារក ឬផ្នែកថែទាំទារក |
| NIS | វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ |
| NMCHC | មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| NRHP | កម្មវិធីជាតិ សុខភាពបន្តពូជ |
| OBGY | សម្ភព និងរោគស្ត្រី |
| OD | ការិយាល័យស្រុកប្រតិបត្តិ |
| PHD | មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត |
| QAO | ការិយាល័យធានាគុណភាពសុខាភិបាល |
| QI | ការកែលម្អគុណភាព |
| QoC | ការកែលម្អថែទាំ |
| RH | មន្ទីរពេទ្យបង្អែក |
| ToR | លក្ខខណ្ឌយោង |
| WHO | អង្គការសុខភាពពិភពលោក |

# 1. សេចក្តីផ្តើម

ក្នុងរយៈពេលជាងមួយទសវត្សរ៍នេះ ប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សំគាល់ក្នុងការធ្វើឱ្យប្រសើរឡើងសុខភាពកុមារ និងទារក ។ អត្រាមរណភាពកុមារ និងទារក បានធ្លាក់ចុះពីរដងចាប់ផ្តើមពីឆ្នាំ២០១៤ មកដល់ឆ្នាំ២០២១-២០២២ ពោលគឺចំនួនកុមារស្លាប់បានថយចុះពី៣៥នាក់ មកនៅ ១៦នាក់ និងទារកស្លាប់បានថយចុះពី១៨ មកនៅត្រឹម៨នាក់ ក្នុង១០០០កំណើតរស់[2] ហើយស្ត្រីភាគច្រើនបានសម្រាលកូនដោយបុគ្គលិកជំនាញ និងទៅសម្រាលនៅមូលដ្ឋានសុខាភិបាល។ ទោះបីជាការសម្រាលកូនដោយបុគ្គលិកជំនាញមានការកើនឡើងគួរឱ្យកត់សម្គាល់ តែអត្រាមរណភាពមាតា (MMR) របស់កម្ពុជាជាងមួយទសវត្សរ៍នេះបានស្ថិតនៅទ្រឹង ពោលគឺ១៥៤នាក់ ក្នុងចំនួន១០០ ០០០ កំណើតរស់នៅឆ្នាំ២០២១-២០២២ ដែលធ្វើឱ្យកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានអត្រាមរណភាពមាតាខ្ពស់បំផុតក្នុងតំបន់ទោះបីមានការកើនឡើងខ្លាំង នូវការសម្រាលកូនដោយបុគ្គលិកជំនាញ និងនៅមូលដ្ឋានសុខាភិបាលពី១០% ក្នុងឆ្នាំ២០០០ ដល់ ៩៧,៥% ក្នុងឆ្នាំ២០២១-២០២២។ មរណភាពមាតានៅតែបន្តកើតមានដោយសារមូលហេតុនានាដែលអាចបង្ការបាន ហើយអត្រាស្លាប់កើតរបស់ទារកមាន១១,៤នាក់ ក្នុង១០០០ កំណើត តាមទិន្នន័យពីអង្គការសុខភាពពិភពលោក Global Health Observatory Data ។ នេះបង្ហាញពីភាពចាំបាច់ជាបន្ទាន់ក្នុងការកែលម្អគុណភាព នៃការថែទាំដើម្បីកាត់បន្ថយមរណភាពរបស់មាតា ទារក និងកុមារដែលអាចបង្ការបាននៅក្នុងប្រទេសកម្ពុជា។

**ការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប (MPDSR)** គឺជាការអង្កេតតាមដានបែបគុណភាព និងស៊ីជម្រៅទៅលើមូលហេតុ និងកាលៈទេសៈជុំវិញការស្លាប់របស់មាតា និងទារកជុំវិញកំណើតទាំងនៅក្នុងមូលដ្ឋានសុខាភិបាល និងសហគមន៍ ។ ដំណើរការនេះគឺជាផ្នែករួមមួយ នៃកិច្ចខិតខំប្រឹងប្រែងកែលម្អគុណភាពផ្តល់សេវាក្នុងគោលបំណងកាត់បន្ថយមរណភាពរបស់ម្តាយ ទារកស្លាប់កើត និងមរណភាពរបស់ទារកទើបនឹងកើតដែលអាចបង្ការបាន។

ការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប (MPDSR) ពឹងផ្អែកលើការកំណត់អត្តសញ្ញាណករណីស្លាប់ត្រឹមត្រូវ និងការពិនិត្យឡើងវិញលើករណីនោះ ដើម្បីផ្តល់ព័ត៌មានសម្រាប់ការអភិវឌ្ឍផែនការជាក់លាក់ដែលអាចអនុវត្តបាន។ ផែនការទាំងនេះបានកំណត់ក្រុម ឬបុគ្គលដែលត្រូវទទួលខុសត្រូវអនុវត្ត និងពេលវេលាសម្រាប់ការបំពេញកិច្ចការ និងដោយរួមបញ្ចូលយន្តការតាមដានដើម្បីធានាថាសកម្មភាពត្រូវបានអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព ។

ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងមុតមាំក្នុងការពង្រឹងការតាមដាន និងការឆ្លើយតបចំពោះមរណភាពមាតាចាប់តាំងពីពិធីសារជាតិ ស្តីពីការស្រាវជ្រាវមរណភាពមាតាដំបូង ត្រូវបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០០៤។ ទោះបីជាយ៉ាងណា ជាមួយនឹងការផ្លាស់ប្តូរ ដែលមានការសម្រាលកូនកាន់តែច្រើន កើតមាននៅតាមមូលដ្ឋានសុខាភិបាលជាមួយគ្នានេះករណីមរណភាពមាតាភាគច្រើន ក៏កើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាលនោះ ដូចនេះតម្រូវឱ្យមានក្រុមការងារខិតខំប្រឹងប្រែងឱ្យកាន់តែច្រើនថែមទៀតដើម្បីពិនិត្យឡើងវិញ និងអនុវត្តការកែលម្អ

[2] *អង្កេតប្រជាសាស្ត្រ និងសុខភាព កម្ពុជា* (CDHS) *២០១៤ & ២០២១-២០២២*

គុណភាព នៃការថែទាំនៅក្នុងបរិបទទាំងនេះ។ លើសពីនេះទៀតកន្លងមកករណីមរណភាពទារកជុំវិញកំណើត មិនត្រូវបានគេដាក់ពិនិត្យជាលក្ខណៈប្រព័ន្ធដែលធ្វើឱ្យខ្វះចន្លោះការទប់ស្កាត់មរណភាពរបស់ទារកជុំវិញកំណើត។

ពិធីសារជាតិដែលបានធ្វើបច្ចុប្បន្នភាពនេះមានការផ្លាស់ប្តូរសំខាន់ខ្លះៗ ដើម្បីឱ្យការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប បានទាន់ពេលវេលា នៅនឹងកន្លែង និងកាន់តែមានប្រសិទ្ធភាព។

**ទី១** រចនាសម្ព័ន្ធក្រុមការងារ ពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបមានបីកម្រិត គឺ **គណៈកម្មាការថ្នាក់ជាតិ ថ្នាក់ខេត្ត និងមន្ទីរពេទ្យ**។ គណៈកម្មាការមន្ទីរពេទ្យ នឹងពិនិត្យលើករណីមរណភាព ដែលកើតមាននៅមូលដ្ឋានសុខាភិបាលរបស់ខ្លួន និងអនុវត្តផែនការសកម្មភាពដើម្បីធានាការទទួលបានគុណភាព សេវា។ គណៈកម្មាការថ្នាក់ខេត្ត នឹងផ្តោតលើការពិនិត្យករណីមរណភាពសរុប នៅក្នុងតំបន់គ្របដណ្តប់ដែលមានសេវា សាធារណៈ និងឯកជន និងដោះស្រាយទៅលើបញ្ហាទូលំទូលាយ នៃការផ្តល់សេវាក្នុងការថែទាំប្រកបដោយ គុណភាព ជាពិសេសការពន្យារពេលក្នុងការស្វែងរកការថែទាំ ពន្យារពេលទទួលសេវា និងកត្តាចូលរួមទាំងឡាយ ដែលបណ្តាលឱ្យមានមរណភាពកើតឡើង។ករណីមរណភាពមិនអាចកើតឡើងតែនៅតាមមូលដ្ឋានសុខាភិបាល សាធារណៈប៉ុណ្ណោះទេ មរណភាពអាចកើតមានឡើងនៅតាមផ្ទះ នៅសហគមន៍ ឬមរណភាពនៅពេលបញ្ជូន តាមផ្លូវ ក៏ត្រូវបានរួមបញ្ចូលក្នុងការតាមដានរបស់គណៈកម្មាការនៅថ្នាក់ខេត្តដែរ។ ជាចុងក្រោយគណៈកម្មាការ ថ្នាក់ជាតិនឹងទទួលខុសត្រូវក្នុងការត្រួតពិនិត្យ តាមដានជាទូទៅលើដំណើរការពិនិត្យមរណភាពមាតា និង ទារកជុំវិញកំណើតនៅថ្នាក់ក្រោមជាតិ និងនៅក្នុងមន្ទីរពេទ្យជាតិ និងធ្វើការត្រួតពិនិត្យតាមដានលើគុណភាព នៃដំណើរការ និងការអនុវត្ត ដើម្បីធានានូវវិធានការកែលម្អដើម្បីបង្ការមរណភាពដែលកើតឡើងនៅពេលអនាគត។

**ទី២** ពិធីសារថ្មីនេះបានពង្រីកវិសាលភាពដោយបញ្ចូលការពិនិត្យ **មរណភាពទារកជុំវិញកំណើត** និង ការឆ្លើយតប ដើម្បីផ្តោតការយកចិត្តទុកដាក់ទៅលើមរណភាពទារកជុំវិញកំណើត និងគាំទ្រដល់សកម្មភាព ប្រកបដោយ ប្រសិទ្ធភាព ដើម្បីកាត់បន្ថយអត្រាមរណភាពនាពេលអនាគត។

**ទី៣** ពិធីសារថ្មីនេះបានបន្ថែមវិសាលភាពការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត**នៅតាមគ្លីនិក ឯកជន** ដែលធ្វើឱ្យការពិនិត្យមរណភាពមានលក្ខណៈជាប្រព័ន្ធ ដែលអាចគ្របដណ្តប់ករណីមរណភាពរបស់ មាតា និងទារកជុំវិញកំណើតទាំងស្ថាប័នសាធារណៈ និងឯកជន។

ជាចុងក្រោយពិធីសារជាតិថ្មីនេះបានផ្តោតទៅលើការអនុវត្តដោយបានរួមបញ្ចូលការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបទៅក្នុង**ការកែលម្អគុណភាពសេវា មាតានិងទារក**។ ការធ្វើសមាហរណកម្ម នេះបានជំរុញលក្ខណៈជាប្រព័ន្ធទូលំទូលាយដើម្បីតាមដាន និងកែលម្អ ធានាថាអនុសាសន៍ត្រូវបានគាំទ្រ និង សកម្មភាពត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌ នៃការកែលម្អគុណភាព នៅគ្រប់កម្រិតមូលដ្ឋានសុខាភិបាលទាំងនៅខេត្ត និងនៅថ្នាក់ជាតិ។ ជាលទ្ធផល ក្រុមការងារកែលម្អគុណភាពរបស់មន្ទីរពេទ្យ នឹងជាសមាជិករបស់គណៈកម្មាការ ពិនិត្យករណីមរណភាពមាតា និងទាកជុំវិញកំណើត ។

ដើម្បីសម្រេចបានគោលដៅ នៃការកាត់បន្ថយមរណភាពរបស់មាតា និងទារកជុំវិញកំណើត និងការឆ្លើយតប ចាំបាច់ត្រូវមានការខិតខំប្រឹងប្រែងដោយមានការសម្របសម្រួលនៅគ្រប់កម្រិត ចាប់ពីសហគមន៍ មណ្ឌលសុខភាព រហូតដល់ថ្នាក់ខេត្ត និងថ្នាក់ជាតិ ។

## 2- និយមន័យ

### 2.1 មរណភាពមាតា (Maternal Death)

មរណភាពមាតាគឺជាមរណភាពរបស់ស្ត្រីក្នុងអំឡុងពេលមានគភ៌រហូតដល់ ៤២ថ្ងៃក្រោយពេលបញ្ចប់គភ៌ដោយមិនគិតពីរយៈពេល និងទីកន្លែងនៃការទុំនៅនៃគភ៌ ដោយសារមូលហេតុផ្សេងៗដែលទាក់ទងនឹងគភ៌ ឬធ្ងន់ធ្ងរដែលកើតឡើងដោយសារគភ៌ ឬដោយសារការគ្រប់គ្រង (ការថែទាំព្យាបាល) មិនបានត្រឹមត្រូវប៉ុន្តែមិនមែនបណ្តាលមកពីមូលហេតុចៃដន្យ ឬជាឧប្បត្តិហេតុផ្សេងទៀតឡើយ។

មរណភាពមាតាត្រូវបានបែងចែកជាពីរក្រុមតូចៗ ៖

- **មរណភាពមាតាដោយផ្ទាល់** (Direct obstetric deaths):

ជាមរណភាពដែលបណ្តាលមកពីផលវិបាកផ្នែកសម្ភព ទាក់ទងនឹងស្ថានភាពមានគភ៌ (ពេលមានគភ៌ ពេលឈឺពោះសម្រាល និងក្រោយពេលសម្រាល) ដោយសារអន្តរាគមន៍ ការធ្វេសប្រហែស ការព្យាបាលមិនត្រឹមត្រូវ ឬដោយសារព្រឹត្តិការណ៍ណាមួយដែលមិនបានយកចិត្តទុកដាក់ ។

- **មរណភាពមាតាដោយប្រយោល** (Indirect obstetric deaths):

ជាមរណភាពដែលបណ្តាលមកពីជំងឺដែលមានស្រាប់ពីមុន ឬជំងឺដែលកើតឡើងក្នុងអំឡុងពេលមានផ្ទៃពោះហើយដែលមិនមែនដោយសារមូលហេតុដោយផ្ទាល់ នៃការសម្រាលកូន ប៉ុន្តែរងផលប៉ះពាល់ផ្នែកសរីរវិទ្យាកាន់តែធ្ងន់ធ្ងរនៅពេលដែលមាតាមានផ្ទៃពោះ ។

### 2.2 មរណភាពមាតាដោយអូសបន្លាយ

ជាមរណភាពរបស់មាតាដោយផ្ទាល់ ឬប្រយោលលើសពី៤២ ថ្ងៃ ប៉ុន្តែតិចជាងមួយឆ្នាំបន្ទាប់ពីបញ្ចប់ការមានគភ៌។

### 2.3 ការស្លាប់ក្នុងអំឡុងពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយពេលសម្រាល

រាល់មរណភាពទាំងអស់ក្នុងអំឡុងពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយពេលសម្រាល រួមទាំង មូលហេតុនៃការស្លាប់ជាមួយគ្នា (ការស្លាប់ដោយសារមូលហេតុខាងក្រៅនានា ដូចជាគ្រោះថ្នាក់ចរាចរណ៍ របួសដោយចៃដន្យ ការធ្វើឃាត។ល។)

### 2.4 ទារកស្លាប់កើត

ទារកស្លាប់កើតគឺជាការសម្រាលទារកស្លាប់មកក្រៅទាំងស្រុង គឺការយកចេញពីស្ត្រីនូវទារកបន្ទាប់ពីទារកនោះស្លាប់ក្នុងផ្ទៃម្តាយនៅមុនពេលការបញ្ចេញមកក្រៅទាំងស្រុង ឬការយកចេញនៅរយៈពេល២៨សប្តាហ៍ពេញលេញ នៃការមានផ្ទៃពោះ។ ករណីស្លាប់កើតគឺខុសគ្នាពីករណីរំលូតក្នុងករណីមិនមានព័ត៌មានអំពីអាយុគភ៌ ទម្ងន់ទារកពេលកើតចំនួន ១០០០ក្រាម ឬលើស ទៅជាលក្ខណៈវិនិច្ឆ័យកំណត់។

**ទារកស្លាប់កើត អាចត្រូវបានបែងចែកជាពីរប្រភេទធំៗ ៖**

- **ករណីទារកស្លាប់កើតមុនពេលឈឺពោះសម្រាល** (Antepartum stillbirths)

គឺជាការសម្រាលមកក្រៅទាំងស្រុង ឬការយកទារកចេញពីផ្ទៃម្តាយ បន្ទាប់ពីទារកនោះស្លាប់មុនពេលចាប់ផ្តើមឈឺពោះសម្រាល ។

• **ករណីទារកស្លាប់កើតជុំវិញពេលសម្រាល (Intrapartum stillbirths)**
គឺជាការសម្រាលទារកមកក្រៅ ឬយកទារកចេញទាំងស្រុងពីផ្ទៃមាតាបន្ទាប់ពីទារកស្លាប់ក្នុងអំឡុងពេលឈឺពោះសម្រាល ។

## 2.5 ការស្លាប់ទារក៖

ការស្លាប់ទារកក្រោយពេលកើត និងក្នុងអំឡុងពេល២៨ ថ្ងៃដំបូងនៃជីវិត។ "រយៈពេលដំបូងនៃជីវិតទារក" ("early neonatal period") សំដៅលើរយៈពេលប្រាំពីរថ្ងៃដំបូងបន្ទាប់ពីកំណើត (ថ្ងៃទី១ ដល់ថ្ងៃទី៧ បន្ទាប់ពីកំណើត)។ "រយៈពេលយឺត នៃជីវិតទារក" ("late neonatal period") សំដៅលើទារកមានអាយុក្រោមមួយខែ នៃជីវិត (ថ្ងៃទី៨ ដល់ថ្ងៃទី២៨ បន្ទាប់ពីកំណើត)។

## 2.6 ការស្លាប់របស់ទារកជុំវិញកំណើត៖

ចំនួននៃករណីស្លាប់របស់ទារកយ៉ាងហោចណាស់ ២៨ សប្តាហ៍ នៃគភ៌ ឬទម្ងន់ទារក ១០០០ ក្រាម និងការស្លាប់របស់ទារកទើបនឹងកើត (រហូតដល់ពេលកើត និងរួមទាំងប្រាំពីរថ្ងៃដំបូងបន្ទាប់ពីកំណើត)។

## 2.7 កត្តាដែលអាចកែតម្រូវ (Modifiable factors)

កត្តាដែលអាចកែតម្រូវបាន គឺជាកត្តាទាំងឡាយណាដែលអាចបង្ការមរណភាពបានប្រសិនបើមានវិធានការផ្សេងមួយត្រូវបានគេយកមកអនុវត្តនៅពេលសម្រាល និងជុំវិញការសម្រាល ។

ឧទាហរណ៍ ការពន្យារពេលក្នុងការប្រើអុកស៊ីតូស៊ីន (oxytocin) ឬការមិនមានឈាមសម្រាប់បញ្ចូលអាចជាកត្តារួមចំណែក ឬជាកត្តាដែលអាចកែតម្រូវបានមួយនៅក្នុងការស្លាប់របស់ម្តាយដោយសារការធ្លាក់ឈាមក្រោយសម្រាលដែលបានកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល។

កត្តាដែលអាចកែតម្រូវបានអាចចាត់ទុកថាជាការពន្យារពេលនៅក្នុងការថែទាំ (ទី១ - ការពន្យារពេលក្នុងការសម្រេចចិត្តស្វែងរកការថែទាំ ទី២ - ការពន្យារពេលក្នុងការទៅដល់កន្លែងថែទាំ ឬទី៣ - ការពន្យារពេលក្នុងការទទួលបានការថែទាំគ្រប់ជ្រុងជ្រោយ) និងជាកម្រិតខ្វះខាតជាប្រព័ន្ធ។ ការវិភាគរកមូលហេតុឫសគល់ អាចជួយកំណត់កត្តាដែលបង្កបញ្ហាទាំងអស់ ឬរួមចំណែកដល់ការបរាជ័យរបស់ប្រព័ន្ធ និងការស្លាប់កើតរបស់ទារក ឬការស្លាប់ទារកទើបនឹងកើតដែលកំពុងត្រូវបានពិនិត្យឡើងវិញ។

## 3- គោលការណ៍សំខាន់ៗ នៃការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប (MPDSR)

ការអនុវត្តពិធីសារជាតិ នៃការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបត្រូវបានណែនាំដោយគោលការណ៍ស្នូលមួយចំនួនដែលធានាប្រសិទ្ធភាព សុចរិត និងផលជះវិជ្ជមានរបស់ប្រព័ន្ធ។ គោលការណ៍ទាំងនេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបចាប់ពីការប្រមូលទិន្នន័យរហូតដល់ការរៀបចំ និងការអនុវត្តសកម្មភាពឆ្លើយតប។

- រក្សាការសម្ងាត់
- គ្មានការស្តីបន្ទោសចាប់កំហុស

### 3.1- រក្សាការសម្ងាត់

រក្សាការសម្ងាត់ និងកែលម្អមានសារៈសំខាន់សម្រាប់ដំណើរ នៃប្រព័ន្ធការពិនិត្យ មរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប (MPDSR)

- រាល់ព័ត៌មានទាំងអស់ដែលត្រូវបានប្រមូលក្នុងអំឡុងពេលដំណើរការ MPDSR រួមទាំងការពិនិត្យឡើងវិញលើករណីមរណភាព និងការពិភាក្សា ត្រូវតែរក្សាការសម្ងាត់យ៉ាងតឹងរឹងបំផុត។
- អត្តសញ្ញាណបុគ្គល (ទាំងអ្នកជំងឺ និងអ្នកផ្តល់សេវាថែទាំសុខភាពដែលពាក់ព័ន្ធ) មិនត្រូវបានបង្ហាញ ឬពិភាក្សានៅខាងក្រៅពីគណៈកម្មការ MPDSR។
- រក្សាការសម្ងាត់មានសារៈសំខាន់បំផុត ដើម្បីថែរក្សាទំនុកចិត្ត ក្នុងចំណោមអ្នកផ្តល់សេវាថែទាំសុខភាពគ្រួសារ និងសហគមន៍ ដោយធានាបាននូវការរាយការណ៍ដោយស្មោះត្រង់ពិតប្រាកដ និងការចូលរួមក្នុងដំណើរការតាមដាន និងឆ្លើយតបចំពោះមរណភាពមាតា និងទារកជុំវិញកំណើត។
- ទិន្នន័យត្រូវតែជាទិន្នន័យដែលគ្មានព័ត៌មានអត្តសញ្ញាណបុគ្គល (ជាអនាមិក)និងមិនត្រូវប្រើប្រាស់ខុសក្រមសីលធម៌របស់គណៈកម្មាការឡើយ។
- មានតែទិន្នន័យរួមគ្មានព័ត៌មានអត្តសញ្ញាណបុគ្គល (ជាអនាមិក) ត្រូវបានចែករំលែកនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងមន្ទីរពេទ្យ ដើម្បីធានានូវភាពជាឯកជនរបស់អ្នកដែលពាក់ព័ន្ធនៅក្នុងករណីមរណភាពដែលត្រូវធ្វើការពិនិត្យឡើងវិញ។
- សមាជិកទាំងអស់ នៃគណៈកម្មការ MPDSR ត្រូវទទួលស្គាល់ថាព័ត៌មាន និងការពិភាក្សាក្នុងអំឡុងពេលដំណើរការ MPDSR ត្រូវតែរក្សាការសម្ងាត់យ៉ាងតឹងរឹងបំផុត។ ដើម្បីសម្រេចបានគោលដៅនេះ សមាជិកគ្រប់រូប នៃគណៈកម្មាធិការត្រូវធ្វើការប្តេជ្ញាចិត្តជាលាយលក្ខណ៍អក្សរ (ឯកសារដែលមានចុះហត្ថលេខា)។

### 3.2 - គ្មានការស្តីបន្ទោស ៖ « គ្មានការស្តីបន្ទោស» មិនមែនមានន័យថា «មិនទទួលខុសត្រូវ»

- គោលបំណងចម្បង នៃការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបគឺដើម្បីរៀនសូត្រពីការស្លាប់របស់ម្តាយ និងទារកជុំវិញការសម្រាល ដើម្បីបង្ការមរណភាពដែលអាចកើតឡើងនាពេលអនាគត មិនមែនដើម្បីស្តីបន្ទោសឡើយ។

- ការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត មិនមែនជាការស្វែងរកកំហុសនោះទេ ហើយមិនគួរប្រើដើម្បីចាត់វិធានការដាក់ទោសទណ្ឌប្រឆាំងដល់អ្នកផ្តល់សេវាថែទាំសុខភាពណាមួយនៅតាមមូលដ្ឋានសុខាភិបាល ឬបុគ្គលិកដែលពាក់ព័ន្ធក្នុងករណីនេះឡើយ។
- ចំណុចផ្តោតចម្បងការពិនិត្យនេះ គឺទៅលើការកំណត់ចំណុចខ្វះខាតនៅក្នុងប្រព័ន្ធ នៃការថែទាំព្យាបាលក្នុងការស្វែងយល់ពីមូលហេតុឫសគល់ និងការរៀបចំដំណោះស្រាយជាក់ស្តែងដើម្បីកែលម្អគុណភាព នៃការថែទាំ។
- បរិយាកាសដែលមិនដាក់ទណ្ឌកម្មជួយលើកទឹកចិត្តឱ្យមានការសន្ទនាដោយបើកចំហ ការរាយការណ៍ដោយភាពស្មោះត្រង់ និងការចូលរួមយ៉ាងសកម្មក្នុងដំណើរការ MPDSR ដោយមិនខ្លាចការសងសឹក។

## 4- ការផ្សារភ្ជាប់ជាមួយប្រព័ន្ធព័ត៌មាន

ដំណើរការការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបគឺពាក់ព័ន្ធនឹងការប្រមូល និងពិនិត្យទិន្នន័យដោយផ្សារភ្ជាប់ទៅនឹងប្រព័ន្ធទិន្នន័យសុខាភិបាលដូចជា ឌីជីថលលិខិតជូនដំណឹងអំពីមរណភាព និងមូលហេតុ? (NCOD) ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល (HMIS) ប្រព័ន្ធព័ត៌មានសុខាភិបាលថ្នាក់ស្រុក (DHIS2) និងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន (CRVS)។

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន (CRVS) មានសំបុត្រកំណើត និងសំបុត្រមរណភាព សំបុត្រអាពាហ៍ពិពាហ៍ និងមូលហេតុមរណភាព ចងក្រងព័ត៌មាន និងផ្សព្វផ្សាយស្ថិតិអត្រានុកូលដ្ឋាន។ តាមរយៈសមាហរណកម្មរវាងការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប MPDSR ជាមួយប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន (CRVS) ប្រព័ន្ធប្រមូលព័ត៌មានទាំងពីរនេះអាចបំពេញគ្នាទៅវិញទៅមក និងការពង្រឹងប្រព័ន្ធទាំងពីរដើម្បីបង្កើតក្របខណ្ឌដ៏រឹងមាំមួយសម្រាប់ការ ត្រួតពិនិត្យតាមដាន និងកែលម្អការថែទាំសុខភាពមាតា និងកុមារ ដែលចុងក្រោយគឺលើកកម្ពស់សុខមាលភាពរបស់មាតា និងទារក។

នៅប្រទេសកម្ពុជា មានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានរបស់ក្រសួងមហាផ្ទៃភ្ជាប់ជាមួយប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថលលិខិតជូនដំណឹងអំពីមរណភាព (NCOD) របស់ក្រសួងសុខាភិបាល មានប្រព័ន្ធចែករំលែកទិន្នន័យ ដែលអាចដំណើរការទាំងក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។ ការតភ្ជាប់ការងារជាប្រព័ន្ធ រវាងប្រព័ន្ធសុខាភិបាលឌីជីថល និងប្រព័ន្ធចុះបញ្ជីស្ថិតិអត្រានុកូលដ្ឋាន ដែលមានលិខិតជូនដំណឹងពីមរណភាព ជូនដំណឹងកំណើតរស់ និងទិន្នន័យលិខិតវេជ្ជសាស្ត្របញ្ជាក់មូលហេតុមរណភាព និងទិន្នន័យទារកស្លាប់កើត ទាំងនៅមូលដ្ឋានសុខាភិបាលសាធារណនិងឯកជន។ លិខិតវេជ្ជសាស្ត្របញ្ជាក់មូលហេតុមរណភាពបានផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ទូទាំងប្រទេសកាលពីខែ ឧសភា ឆ្នាំ២០២៤ កន្លងទៅនេះហើយដំណើរការពេញលេញនៅគ្រប់តាមមូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេស។




រូបភាពទី 1. វដ្ត នៃការតាមដាន និងឆ្លើយតបចំពោះមរណភាពមាតា និងទារកជុំវិញកំណើត

## 5- ការផ្សារភ្ជាប់ជាមួយការកែលម្អគុណភាព (QI)

គោលបំណងចម្បង នៃការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបគឺដើម្បីជំរុញសកម្មភាពសម្រាប់ការកែលម្អគុណភាព (QI) ហើយខណៈនេះ MPDSR មានតួនាទីយ៉ាងសំខាន់ក្នុងផ្នែកមួយ នៃក្របខ័ណ្ឌកែលម្អគុណភាពជាប្រចាំ រួមបញ្ចូលទាំងការរៀបចំផែនការ ការអនុវត្ត និងការត្រួតពិនិត្យតាមដានបន្តបន្ទាប់។

ទំនាក់ទំនងនេះ ត្រូវបានបង្ហាញយ៉ាងល្អបំផុតតាមរយៈគំរូវង្វង់ភ្លោះដែលបង្ហាញពីការកែលម្អវដ្ត នៃប្រព័ន្ធជាបន្តបន្ទាប់។ វង្វង់ភ្លោះពីរភ្ជាប់គ្នាធ្វើការរួមគ្នាក្នុងពេលតែមួយគំរូនេះរំលេចពីរបៀបដែលដំណើរការកែលម្អគុណភាពជាប្រចាំ ផ្តល់ដំណឹង និងពង្រឹងដោយការឆ្លើយតបជាក់លាក់ចំពោះព្រឹត្តិការណ៍នានាដូចជាមរណភាពរបស់មាតា ឬទារកជុំវិញកំណើត។

ប្រព័ន្ធកែលម្អគុណភាពសេវាជាបន្ត




**រូបភាពទី 2. វដ្ត នៃប្រព័ន្ធកែលម្អគុណភាពសេវា ៖ គំរូវង្វង់ភ្លោះ**

- វង្វង់ខាងឆ្វេង ការកែលម្អការថែទាំជាប្រចាំ៖ ផ្នែកខាងឆ្វេង នៃវង្វង់ភ្លោះ តំណាងឱ្យវដ្ត នៃការកែលម្អប្រព័ន្ធជាប្រចាំក្នុងអំឡុងពេល "ធ្វើការងារជាធម្មតា" ដោយផ្តោតលើការកែលម្អការថែទាំជាប្រចាំ ។ វង្វង់នេះអនុវត្តន៍តាមវដ្ត "រៀបចំផែនការ អនុវត្ត ស្តង់ដា សម្រេចចិត្ត" (Plan-Do-Standardize-Act)។
- វង្វង់ខាងស្តាំការឆ្លើយតបចំពោះព្រឹត្តិការណ៍៖ ផ្នែកខាងស្តាំ នៃវង្វង់ភ្លោះតំណាងឱ្យវដ្តឆ្លើយតបនៅពេលព្រឹត្តិការណ៍ពិសេសកើតឡើង ដូចជាការស្លាប់របស់មាតា ឬទារក ដែលត្រូវបានរកឃើញនៅទីនេះដោយ MPDSR (ការតាមដាន និងការឆ្លើយតបចំពោះមរណភាពមាតា និងទារកជុំវិញកំណើត)។ វង្វង់នេះអនុវត្ត

តាមវិធីសាស្រ្ត "រៀបចំផែនការ អនុវត្ត ស្តង់ដា សម្រេចចិត្ត" (Plan-Do-Standardize-Act) ស្រដៀងគ្នានេះដែរ ប៉ុន្តែផ្តោតលើការឆ្លើយតបចំពោះឧប្បត្តិហេតុជាក់លាក់។

រង្វង់ទាំងពីរត្រូវបានដាក់ជាប់គ្នា ដែលបង្ហាញថាការរៀនសូត្រពីព្រឹត្តិការណ៍ (រង្វង់ខាងស្តាំ) គួរតែផ្តល់ព័ត៌មាន និងពង្រឹងដំណើរការកែលម្អគុណភាពរួមនៅក្នុងការថែទាំជាប្រចាំ (រង្វង់ជុំខាងឆ្វេង)។ ការផ្សារភ្ជាប់គ្នានេះមានសារៈសំខាន់សម្រាប់យន្តការអនុវត្តមិនត្រឹមតែក្នុងការកែលម្អព្រឹត្តការណ៍ដែលបានគ្រោងទុកប៉ណ្ណោះទេ ប៉ុន្តែថែមទាំងរៀនសូត្រពីព្រឹត្តិការណ៍ ដែលមិនបានគ្រោងទុកផងដែរ ដែលជាហេតុនាំឱ្យមានភាពស៊ីសង្វាក់ប្រទាក់ក្រឡាក្នុងការកែលម្អគុណភាពផ្តល់សេវា។

ដូច្នេះការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប ផ្សារភ្ជាប់ទូលំទូលាយជាមួយការងារកែលម្អគុណភាពផ្តល់សេវា។ ការធ្វើបែបនេះអនុញ្ញាតឱ្យមានដំណើរការត្រួតពិនិត្យតាមដាន និងកែលម្អគុណភាពជាប្រព័ន្ធបន្ថែមទៀតនៅមូលដ្ឋានសុខាភិបាលគ្រប់លំដាប់ថ្នាក់។ ការផ្តល់អនុសាសន៍ក្នុងការចុះអង្កេត MPDSR គឺចូលរួមចំណែកច្រើន ក្នុងសកម្មភាពតាមដានជាប់ជាប្រចាំ ក្នុងការអនុវត្តការកែលម្អគុណភាពថែទាំ នៅថ្នាក់មូលដ្ឋានសុខាភិបាលដោយផ្ទាល់ ឬថ្នាក់ខេត្ត។

## 6- រចនាសម្ព័ន្ធ នៃការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប

រចនាសម្ព័ន្ធរបស់ MPDSR មានចំនួនបីកម្រិតៈ **ថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មន្ទីរពេទ្យ។** ករណីស្លាប់ដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល ត្រូវបានពិនិត្យដោយគណៈកម្មាការថ្នាក់មន្ទីរពេទ្យនីមួយៗ រីឯករណីមរណភាពនៅសហគមន៍ នៅមណ្ឌលសុខភាព នៅគ្លីនិកឯកជន និងករណីមរណភាពនៅមន្ទីរពេទ្យដែលមិនមានគណៈកម្មាការ ត្រូវពិនិត្យដោយគណៈកម្មាការខេត្ត។ ក្នុងករណីចាំបាច់ណាមួយ គណៈកម្មការជាតិនឹងចុះដល់មូលដ្ឋាន និងចូលរួមជាមួយគណៈកម្មាការមន្ទីរពេទ្យនិងគណៈកម្មាការខេត្តក្នុងការប្រមូលទិន្នន័យ និងពិនិត្យករណីមរណភាព។

គណៈកម្មាការថ្នាក់មន្ទីរពេទ្យ រាយការណ៍ជូនគណៈកម្មាការថ្នាក់ខេត្ត ដែលនឹងពិនិត្យមើលករណីមរណភាពសរុបរបស់មាតា និងទារកជុំវិញកំណើតនៅក្នុងខេត្តរបស់ខ្លួន។ បន្ទាប់មកគណៈកម្មាការខេត្តបញ្ជូនរបាយការណ៍ទៅគណៈកម្មាការថ្នាក់ជាតិដែលទទួលខុសត្រូវនិងពិនិត្យមើលករណីមរណភាពសរុបនៅថ្នាក់ជាតិ។ មន្ទីរពេទ្យជាតិរាយការណ៍មរណភាពដោយផ្ទាល់ទៅគណៈកម្មាការថ្នាក់ជាតិ។

គណៈកម្មាការមន្ទីរពេទ្យ ត្រូវផ្តល់អនុសាសន៍ដល់មន្ទីរពេទ្យរបស់ខ្លួន និងអនុវត្តសកម្មភាពនៅក្នុងមន្ទីរពេទ្យដើម្បីដោះស្រាយកត្តាគ្លីនិកដែលចូលរួមឱ្យមានករណីមរណភាពមាតា និងទារកជុំវិញកំណើត និងពាំនាំអនុសាសន៍ទាំងអស់ដែលទាក់ទងជាមួយភាគីដែលពាក់ពន្ធ័ នៅក្រៅមូលដ្ឋានសុខាភិបាលតាមរយៈគណៈកម្មការថ្នាក់ខេត្តផងដែរ។ គណៈកម្មការថ្នាក់ខេត្តក្រៅពីផ្តល់អនុសាសន៍ដល់មន្ទីរពេទ្យ និងមណ្ឌលសុខភាពដើម្បីដោះស្រាយកត្តាដែលអាចកែតម្រូវបាន ក៏បានរួមចំណែកដល់ការរៀបចំផែនការថ្នាក់ខេត្តដើម្បីដោះស្រាយនូវ**ការពន្យារពេលទី១ និងទី២** (ការសម្រេចចិត្តស្វែងរកការថែទាំ និងការទៅដល់មូលដ្ឋានសុខាភិបាល)។ រចនាសម្ព័ន្ធនេះធានាថា ទាំងបញ្ហាគ្លីនិក (ពេគវិនិច្ឆ័យគ្លីនិក) និងបញ្ហាប្រព័ន្ធត្រូវបានដោះនៅកម្រិតដែលសមស្រប។ ព័ត៌មានត្រឡប់ នៃការពិនិត្យមរណភាពគួរតែចែករំលែកជាមួយក្រុមគ្រួសារផងដែរ។

លក្ខខណ្ឌយោង (TOR) សម្រាប់គណៈកម្មការនៅកម្រិតថ្នាក់នីមួយៗ (ថ្នាក់ជាតិ ថ្នាក់ខេត្ត និងមន្ទីរពេទ្យ) ត្រូវបានផ្តល់ជូននៅក្នុងផ្នែកខាងក្រោម។ លក្ខខណ្ឌយោងទាំងនេះ រួមមានការទទួលខុសត្រូវ និងសមាសភាពរបស់គណៈកម្មាការនីមួយៗ។លេខាធិការដ្ឋាននៅគ្រប់កម្រិតថ្នាក់ទទួលខុសត្រូវក្នុងការសម្របសម្រួលសកម្មភាព រៀបចំកិច្ចប្រជុំ ធានានូវចងក្រងឯកសារត្រឹមត្រូវ និងរបាយការណ៍អំពីករណីមរណភាពរបស់មាតា និងទារកជុំវិញកំណើត និងសម្របសម្រួលការផ្តល់ព័ត៌មានយោបល់ត្រឡប់ និងការអនុវត្តសកម្មភាព។ ឧបសម្ព័ន្ធទី១ ផ្តល់នូវតារាងប្រៀបធៀបសម្រាប់តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាការ MPDSR នៅថ្នាក់មន្ទីរពេទ្យថ្នាក់ខេត្ត និងថ្នាក់ជាតិ ។

រូបភាពទី 3. រចនាសម្ព័ន្ធរបស់គណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប




— បន្ទាត់បង្ហាញពីទំនាក់ទំនងការរាយការណ៍ និងផ្តល់ព័ត៌មានត្រលប់

តារាង.ទីកន្លែងមរណភាព និងគណៈកម្មការត្រួតទទួលបន្ទុកពិនិត្យករណីមរណភាព

| ទីកន្លែងមរណភាព | | ពិនិត្យករណីដោយ |
|---|---|---|
| នៅមូលដ្ឋានសុខាភិបាល | នៅមូលដ្ឋានសុខាភិបាលសាធារណៈ មន្ទីរពេទ្យដែលមានគណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត | គណៈកម្មការមន្ទីរពេទ្យ |
| | នៅមូលដ្ឋានសុខាភិបាលសាធារណៈ មន្ទីរពេទ្យដែលគ្មានគណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត | គណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើតថ្នាក់ខេត្ត |
| | នៅមណ្ឌលសុខភាព | |
| | នៅក្នុងរថយន្តសង្គ្រោះ | |
| | នៅមន្ទីរពេទ្យឯកជន | |
| នៅក្រៅមូលដ្ឋានសុខាភិបាល | នៅសហគមន៍ | |

## 6.1 លក្ខខណ្ឌយោងសម្រាប់គណៈកម្មាការថ្នាក់ជាតិ

### 6.1.1. គោលបំណង

គោលបំណងរបស់គណៈកម្មាការថ្នាក់ជាតិពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបគឺ៖

- តាមដាន និងពិនិត្យឡើងវិញលើករណីមរណភាពរបស់មាតា និងទារកជុំវិញកំណើតនៅក្នុងប្រទេស។
- ផ្តល់អនុសាសន៍សម្រាប់ការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រ។
- សម្របសម្រួលការបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- លើកកម្ពស់វប្បធម៌គណនេយ្យភាព ការរៀនសូត្រជាប្រចាំ និងការកែលម្អគុណភាពបំរើសេវាសុខភាពមាតា និងទារក។

ដូចបានជម្រាបពីខាងលើ មានករណីមរណភាពមួយចំនួន គណៈកម្មការជាតិនឹងចុះដល់មូលដ្ឋាន និងចូលរួមជាមួយគណៈកម្មាការមន្ទីរពេទ្យ និងគណៈកម្មាការខេត្តក្នុងការប្រមូលទិន្នន័យ និងពិនិត្យករណីមរណភាព។

### 6.1.2. ភារកិច្ច និងការទទួលខុសត្រូវ

- **វិសាលភាពការងារ**

  គណៈកម្មាការត្រូវ ៖

  - ពិនិត្យមើលរបាយការណ៍ថ្នាក់ខេត្តទាំងអស់។
  - វិភាគទិន្នន័យដើម្បីកំណត់ពីលំនាំ និងនិន្នាការនៃមរណភាពរបស់មាតានិងទារកជុំវិញកំណើត ផ្តល់ព័ត៌មានត្រឡប់ដល់ថ្នាក់ខេត្ត និងមន្ទីរពេទ្យជាតិ កម្មវិធីជាតិនិងនាយកដ្ឋាននានារបស់ក្រសួងសុខាភិបាល។ កែលម្អគុណភាព និងអនុវត្តផែនការសកម្មភាពដើម្បីកែលម្អគុណភាពសេវាជាប្រចាំ ។
  - សម្របសម្រួលការបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
  - រៀបចំរបាយការណ៍ប្រចាំឆ្នាំសម្រាប់ចែកចាយជាមួយក្រុមការងារ។
  - ផ្តល់អនុសាសន៍សម្រាប់ការអភិវឌ្ឍន៍គោលនយោបាយ និងយុទ្ធសាស្ត្រដើម្បីកាត់បន្ថយពិនិត្យមរណភាពមាតាជុំវិញកំណើត។
  - ធានាការសម្ងាត់ និងការការពារទិន្នន័យអ្នកជំងឺក្នុងអំឡុងពេលដំណើរការពិនិត្យឡើងវិញ។

- **ភាពញឹកញាប់ នៃកិច្ចប្រជុំ**

  - គណៈកម្មាការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបថ្នាក់ជាតិនឹងជួបប្រជុំរៀងរាល់ត្រីមាស ដើម្បីពិនិត្យទៅលើរបាយការណ៍តាមខេត្ត និងតាមមន្ទីរពេទ្យជាតិ និងតាមដានគុណភាពផ្តល់សេវា ការធ្វើផែនការ និងដំណើរការសកម្មភាព។
  - ក្នុងករណីចាំបាច់ត្រូវប្រជុំបន្ទាន់នឹងត្រូវរៀបចំឡើង។

- **ការរាយការណ៍ និងគណនេយ្យភាព**
  - គណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប ធ្វើរបាយការណ៍ប្រចាំឆ្នាំ ដោយបញ្ជាក់ពីរបកគំហើញសំខាន់ៗ អនុសាសន៍ និងវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាព។
- **រក្សាការសម្ងាត់**
  - សមាជិកទាំងអស់ នៃគណៈកម្មការពិនិត្យមរណភាពមាតាជុំវិញកំណើត និងការឆ្លើយតប ត្រូវតែរក្សាការសម្ងាត់ចំពោះព័ត៌មានណាដែលទាក់ទងនឹងមរណភាព និងទិន្នន័យដែលរសើបដែលបានពិភាក្សាក្នុងអំឡុងពេលពិនិត្យករណីមរណភាព ។
  - ដើម្បីពង្រឹងការងារនេះ ការរក្សាការសំងាត់ និងគោលការណ៍មិនមែនចាប់កំហុស ត្រូវតែបញ្ជាក់ឡើងវិញនៅរាល់ពេលចាប់ផ្តើមការប្រជុំរបស់គណៈកម្មការ ។
- **ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ**
  - គណៈកម្មការ នឹងវាយតម្លៃប្រសិទ្ធភាពការងារជាប្រចាំ ដោយពិនិត្យមើលការអនុវត្តផែនការសកម្មភាព និងផលប៉ះពាល់លើការកាត់បន្ថយ មរណភាពរបស់មាតា និងទារកជុំវិញកំណើត។

### 6.1.3. សមាសភាព នៃគណៈកម្មការ

គណៈកម្មការថ្នាក់ជាតិ មានមន្ត្រីចម្រុះគ្រប់ផ្នែកដែលមានជំនាញបច្ចេកទេសផ្នែកសុខភាពមាតា និងទារកជុំវិញកំណើត។ ដើម្បីធានានូវភាពសមស្រប នៃដំណើរការនិងការចូលរួមបានទៀងទាត់ ជាការសំខាន់ត្រូវមានការពិចារណាឱ្យបានម៉ត់ចត់នៅពេលចាត់តាំងសមាជិកភាព នៃគណៈកម្មការ។ ដើម្បីអាចសម្រេចបាននូវគោលបំណងនេះ ត្រូវមានសមាសភាពជាសមាជិកអចិន្ត្រៃយ៍ និងសមាជិកតាមការចាំបាច់ ដែលនឹងត្រូវអញ្ជើញមកទៅតាមការចាំបាច់ទាក់ទងនឹងករណីនិមួយៗ។

- **សមាជិកអចិន្ត្រៃយ៍**
  - តំណាងមកពីកម្មវិធីជាតិសុខភាពបន្តពូជ
  - តំណាងមកពីមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក (NMCHC)
  - តំណាងមកពីនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល (DPHI)
  - តំណាងមកពីការិយាល័យធានាគុណភាពសុខាភិបាល (QAO) របស់នាយកដ្ឋានមន្ទីរពេទ្យ
  - ការិយាល័យគិលានុបដ្ឋាក និងឆ្មបនាយកដ្ឋានមន្ទីរពេទ្យ
  - តំណាងមកពីមន្ទីរពេទ្យថ្នាក់ជាតិ
  - លេខាធិការ នៃគណៈកម្មការកោសល្យវិច័យ
  - តំណាងមកពីសមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា
  - តំណាងសមាគមវិជ្ជាជីវៈ នៃគ្រូពេទ្យឯកទេសទារក ឬជំងឺកុមារ
  - តំណាងសមាគមវិជ្ជាជីវៈផ្នែកដាក់ថ្នាំសណ្តំ
  - តំណាងមកពីសមាគមឆ្មប

- **សមាជិកមិនអចិន្ត្រៃយ៍ (ករណីចាំបាច់)**
    - តំណាងមកពីសមាគមគ្លីនិក ឬមន្ទីរពេទ្យឯកជន
    - តំណាងក្រុមប្រឹក្សាគណៈឆ្មបកម្ពុជា
    - តំណាងក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកកម្ពុជា
    - តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យកម្ពុជា
    - ផ្សេងៗដូចជាផ្នែកកោសិកាវិភាគ ប្រសិនបើមាន
- **លេខាធិការដ្ឋាន**

លេខាធិការដ្ឋានគួរតែមានអ្នកសម្របសម្រួលចំនួន២ ទៅ ៣នាក់ (មួយនាក់មកពីផ្នែកសុខភាពមាតា និងមួយនាក់ទៀតមកពីផ្នែកទារក) ជាការល្អគឺជាវេជ្ជបណ្ឌិតសុខភាពសាធារណៈ ឬមានចំណេះជំនាញសមស្រប ដែលពួកគាត់ត្រូវរាយការណ៍ជូនប្រធានកម្មវិធីជាតិសុខភាពបន្តពូជ។ បុគ្គលដែលត្រូវបានតែងតាំងជាមន្ត្រីសម្របសម្រួលត្រូវតែមានការទឹកចិត្ត មានចំណេះដឹង និងមានឆន្ទៈក្នុងការរៀនសូត្រ។ លេខាធិការដ្ឋាននេះនឹងត្រូវបានគាំទ្រពីមន្ត្រីជំនួយបន្ថែមទៀតដើម្បីតាមដានទិន្នន័យ និងជួយក្នុងដំណើរការ MPDSR ។ ប្រធានលេខាធិការដ្ឋានគួរតែជាអនុប្រធានគណៈកម្មាការជាតិ។

តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន រួមមាន ៖

- ត្រួតពិនិត្យតាមដាន និងជួយក្នុងការរៀបចំកិច្ចប្រជុំគណៈកម្មាការជាតិ MPDSR ដើម្បីធានាថាកិច្ចប្រជុំត្រូវបានធ្វើឡើងដោយទាន់ពេលវេលា ហើយរបាយការណ៍ត្រូវបានដាក់ជូនទាន់ពេលវេលា និងសមស្រប ។
- សម្របសម្រួលកម្មវិធីបណ្តុះបណ្តាលនានានៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងស្រុក ។ ជួយក្នុងការអភិវឌ្ឍន៍នូវវគ្គសិក្សា និងម៉ូឌុលដែលសមស្រប ។
- កំណត់ពីតម្រូវការបុគ្គលិក និងប្រភពធនធានហិរញ្ញវត្ថុ។
- សម្របសម្រួលប្រតិបត្តិការ និងការស្រាវជ្រាវ។
- សម្របសម្រួលសកម្មភាពផ្សេងៗទៀតដែលទាក់ទងនឹង MPDSR ដែលប្រធានគណៈកម្មាការស្នើសុំ។

## 6.2 លក្ខខណ្ឌយោងរបស់គណៈកម្មាការថ្នាក់ខេត្ត

### 6.2.1. គោលបំណង

គោលបំណង នៃគណៈកម្មាការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបថ្នាក់ខេត្ត គឺ ៖

- តាមដាន និងពិនិត្យឡើងវិញលើករណីមរណភាពរបស់មាតា និងទារកជុំវិញកំណើតដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាលដែលមិនមានគណៈកម្មាការ MPDSR ដូចជាមរណភាពនៅមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព នៅតាមរថយន្តសង្គ្រោះ និងក្នុងសហគមន៍ក្នុងតំបន់គ្របដណ្តប់របស់ខេត្ត។
- ពិនិត្យករណីសរុប នៃមរណភាពមាតា និងទារកជុំវិញការសម្រាលដែលកើតឡើងនៅក្នុងខេត្ត។
- កំណត់ចំណុចខ្វះខាត និងអនុវត្តអនុសាសន៍សម្រាប់ថ្នាក់ខេត្ត។

- លើកកម្ពស់វប្បធម៌គណនេយ្យភាព ការរៀនសូត្រជាប្រចាំ និងការកែលម្អគុណភាព នៃការផ្តល់សេវាមាតា និងទារក។

6.2.2. តួនាទី និងការទទួលខុសត្រូវ

- **វិសាលភាពការងារ នៃគណៈកម្មការ**
    - ពិនិត្យករណីមរណភាពមាតា និងមរណភាពទារកជុំវិញកំណើតដែលកើតមាននៅក្នុងខេត្ត។
    - វិភាគទិន្នន័យដែលបានមកពីគណៈកម្មការមន្ទីរពេទ្យ ដើម្បីកំណត់ពីលំនាំ និងនិន្នាការ នៃមរណភាពមាតា និងទារកជុំវិញកំណើត។
    - រៀបចំផែនការ និងអនុវត្តការសម្រេចចិត្តដោយផ្អែកលើរបកគំហើញ និងត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃអន្តរាគមន៍។
    - ត្រួតពិនិត្យតាមដានជាប្រចាំនូវគុណភាព នៃការថែទាំ និងសូចនាករលទ្ធផលនៅក្នុងខេត្ត។
    - រៀបចំរបាយការណ៍ជូនគណៈកម្មការថ្នាក់ជាតិ។
    - ផ្តល់ព័ត៌មានត្រឡប់ដល់មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យស្រុក និងខេត្ត មណ្ឌល សុខភាព និងសហគមន៍ ឬគណៈកម្មការជាតិប្រសិនបើចាំបាច់។
    - ធានាការសម្ងាត់ និងការរក្សាទិន្នន័យមរណភាពក្នុងអំឡុងពេលដំណើរការពិនិត្យ។
- **ភាពញឹកញាប់ នៃកិច្ចប្រជុំ**
    - គណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបនឹងជួបប្រជុំគ្នាភ្លាមក្រោយការប្រមូលព័ត៌មានបានពេញលេញ ដែលជាធម្មតាគឺក្នុងអំឡុងពេល៧ថ្ងៃ ទៅ១ខែបន្ទាប់ពីមរណភាព។
    - លើសពីនេះទៀត គណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបថ្នាក់ខេត្ត ត្រូវប្រជុំទៀងទាត់ដើម្បីតាមដានគុណភាព នៃការថែទាំ និងការអនុវត្តសម្មភាពដែលត្រូវធ្វើជារៀងរាល់ខែ។
- **របាយការណ៍ និងគណនេយ្យភាព**
    - គណៈកម្មការ MPDSR នឹងផ្តល់របាយការណ៍ពីរដងក្នុងមួយឆ្នាំ ដោយបញ្ជាក់ពីរបកគំហើញសំខាន់ៗអនុសាសន៍ និងវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពដល់គណៈកម្មាធិការថ្នាក់ជាតិ។
    - ផ្តល់ព័ត៌មានត្រឡប់អំពីរបកគំហើញសំខាន់ៗដល់គ្រួសារដែលទទួលមរណភាព។
    - ក្នុងករណីដែលទាក់ទងនឹងដំណើរការផ្លូវច្បាប់ ប្រធានមន្ទីរសុខាភិបាលនឹងរាយការណ៍ជូនអភិបាលរងខេត្តទទួលបន្ទុកការងារសុខាភិបាលក្រោយពេលគណៈកម្មការថ្នាក់ខេត្តបានពិនិត្យករណីមរណភាពនោះរួចរាល់។

- **រក្សាការសម្ងាត់**
    - សមាជិកទាំងអស់របស់គណៈកម្មាការ MPDSR ត្រូវតែរក្សាការសម្ងាត់ចំពោះព័ត៌មានណាដែលទាក់ទងនឹងមរណភាព និងទិន្នន័យដែលធ្វើឱ្យរសើប ដែលបានពិភាក្សាក្នុងអំឡុងពេលពិនិត្យករណីមរណភាពឡើងវិញ។
    - ដើម្បីពង្រឹងការងារនេះ ការរក្សាការសំងាត់ និងគោលការណ៍មិនមែនចាប់កំហុស ត្រូវតែបញ្ជាក់ឡើងវិញនៅរាល់ពេលចាប់ផ្តើមការប្រជុំរបស់គណៈកម្មាការ ។
    - របកគំហើញ និងអនុសាសន៍នឹងត្រូវបានរក្សាជាអនាមិកមុនពេលចែកចាយទៅក្រៅគណៈកម្មាការ
- **ធនធាន និងការគាំទ្រ**

មន្ទីរសុខាភិបាលខេត្ត ត្រូវធានាថាគណៈកម្មាការមានធនធានគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពរបស់ខ្លួនដូចជា ៖

- គាំទ្រផ្នែករដ្ឋបាលសម្រាប់ការរៀបចំកិច្ចប្រជុំ និងថែរក្សាឯកសារ។
- គាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការបណ្តុះបណ្តាលសមាជិកគណៈកម្មាការ និងសម្រាប់ការអនុវត្តផែនការសកម្មភាព។

- **ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ**

គណៈកម្មាការនឹងវាយតម្លៃប្រសិទ្ធភាពរបស់ខ្លួនជាទៀងទាត់ ដោយពិនិត្យឡើងវិញលើការអនុវត្តផែនការសកម្មភាព និងផលជះ នៃការអនុវត្តផែនការនេះលើការកាត់បន្ថយមរណភាពមាតា និងទារកជុំវិញកំណើត។

### 6.2.3. សមាសភាពរបស់គណៈកម្មាការ

គណៈកម្មាការ MPDSR ថ្នាក់ខេត្ត រួមមានមន្ត្រីចម្រុះគ្រប់ផ្នែកដែលមានជំនាញបច្ចេកទេសផ្នែកសុខភាពមាតា និងទារក។ ដើម្បីធានានូវភាពសមស្រប នៃដំណើរការ និងការចូលរួមបានទៀងទាត់ ជាការសំខាន់ត្រូវមានការពិចារណាឱ្យបានម៉ត់ចត់នៅពេលចាត់តាំងសមាជិកភាព នៃគណៈកម្មាការ។ ដើម្បីអាចសម្រេចបាននូវគោលបំណងនេះ ត្រូវមានសមាសភាពជាសមាជិកអចិន្ត្រៃយ៍ និងសមាជិកតាមការចាំបាច់ដែលនឹងត្រូវអញ្ជើញមកទៅតាមការចាំបាច់ទាក់ទងនឹងករណីនីមួយៗ។

- **សមាជិកអចិន្ត្រៃយ៍**
    - ប្រធាន ឬអនុប្រធាន មន្ទីរសុខាភិបាលខេត្ត (ប្រធាន)
    - ប្រធាន ឬអនុប្រធាន ការិយាល័យបង្ការ និងគ្រប់គ្រងជំងឺ (អនុប្រធាន)
    - មន្ទីរសុខាភិបាលខេត្ត មន្ត្រីទទួលបន្ទុកការកែលម្អគុណភាពសេវាសុខាភិបាល
    - ផ្នែកសុខភាពមាតា និងទារកថ្នាក់ខេត្ត
    - តំណាងគណៈកម្មការកោសល្យវិច័យថ្នាក់ខេត្ត
    - ប្រធានការិយាល័យស្រុកប្រតិបត្តិ (គ្រប់ការិយាល័យស្រុកប្រតិបត្តិទាំងអស់)
    - ប្រធានផ្នែកសុខភាពមាតា និងទារកស្រុកប្រតិបត្តិ (គ្រប់ស្រុកប្រតិបត្តិទាំងអស់)
    - ប្រធានមន្ទីរពេទ្យខេត្ត ឬប្រធានមន្ទីរពេទ្យបង្អែកទាំងអស់

- ប្រធានផ្នែកថែទាំ នៃមន្ទីរពេទ្យខេត្ត
- ប្រធានផ្នែកសម្ភព នៃមន្ទីរពេទ្យខេត្ត
- ប្រធានផ្នែក ទារក កុមារតូច NICU នៃមន្ទីរពេទ្យខេត្ត
- មន្ត្រីទទួលបន្ទុកប្រព័ន្ធព័ត៌មានសុខាភិបាល និងផែនការខេត្ត

- **សមាជិកមិនអចិន្ត្រៃយ៍(ករណីចាំបាច់)**
  - អជ្ញាធរមូលដ្ឋាន និងតំណាងសហគមន៍
  - គ្រូពេទ្យជំនាញវិភាគវិទ្យា
  - អ្នកជំនាញផ្សេងៗ
- **លេខាធិការដ្ឋាន**

សមាសភាព ៖ ក្រុមលេខាធិការដ្ឋានត្រូវមានចំនួនបីរូប ប្រធានកម្មវិធីសុខភាពមាតា និងទារកខេត្ត មន្ត្រីទទួលបន្ទុកកែលម្អគុណភាពសេវាមក នៃមន្ទីរសុខាភិបាលខេត្ត និងមន្ត្រីមកពីមន្ទីរពេទ្យខេត្ត។ ប្រធានរបស់លេខាធិការដ្ឋានគឺជាប្រធានកម្មវិធីសុខភាពមាតា និងទារករបស់មន្ទីរសុខាភិបាលខេត្ត។

**តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន រួមមាន ៖**

- ទទួលព័ត៌មានអំពីករណីមរណភាពមាតា ឬទារកជុំវិញកំណើត
- រាយការណ៍ជូនគណៈកម្មការមន្ទីរពេទ្យ
- រៀបចំចាត់តាំងក្រុមប្រមូលទិន្នន័យ
- រៀបចំការពិនិត្យប្រជុំក្រុមការងារមុន (pre-review) និងសម្របសម្រួលកិច្ចប្រជុំ MPDSR
- រៀបចំអនុសាសន៍ និងផែនការសកម្មភាពនៃអង្គប្រជុំ MPDSR
- ធានាថារបាយការណ៍មិនមានដាក់បញ្ចូលព័ត៌មានអំពីអត្តសញ្ញាណ
- បញ្ជូនរបាយការណ៍ទៅកាន់គណៈកម្មការជាតិ។
- លេខាធិការដ្ឋានរាយការណ៍ជូនប្រធានគណៈកម្មធិការខេត្ត

## 6.3 លក្ខខណ្ឌយោងរបស់គណៈកម្មការថ្នាក់មន្ទីរពេទ្យ

ដើម្បីឱ្យដំណើរការឆ្លើយតបនឹងសកម្មភាពការងារទាន់ពេលវេលា មន្ទីរពេទ្យនីមួយៗគួរតែបង្កើតគណៈកម្មការ MPDSR ដើម្បីពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើតដែលបានកើតឡើងនៅក្នុងមន្ទីរពេទ្យរបស់ខ្លួន និងដើម្បីតាមដានគុណភាព នៃការអនុវត្តការថែទាំមាតា និងទារកជាប្រចាំ។ ទោះយ៉ាងណាក៏ដោយកិច្ចការនេះអាស្រ័យលើធនធានមនុស្ស និងសមត្ថភាពរបស់មន្ទីរពេទ្យក្នុងការបង្កើតគណៈកម្មការជាពិសេសនៅមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យខេត្ត ហើយជាបណ្តើរៗអាចពង្រីកទៅដល់មន្ទីរពេទ្យស្រុកផ្សេងទៀតដោយផ្អែកលើសមត្ថភាព និងតម្រូវការរបស់មូលដ្ឋានសុខាភិបាលនីមួយៗ។

### 6.3.1. គោលបំណង

គោលបំណងរបស់គណៈកម្មការ MPDSR ថ្នាក់មន្ទីរពេទ្យ គឺ ៖

- ត្រួតពិនិត្យតាមដាន និងការពិនិត្យឡើងវិញលើរាល់ពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើតដែលកើតឡើងនៅក្នុងមន្ទីរពេទ្យ។
- ត្រួតពិនិត្យតាមដានគុណភាព នៃការថែទាំជាប្រចាំ និងអនុវត្តការកែលម្អគុណភាពសេវាសុខាភិបាលដើម្បីជៀសវាងការស្លាប់ដែលអាចបង្ការបាននៅពេលខាងមុខ។
- លើកកម្ពស់វប្បធម៌ នៃគណនេយ្យភាព ការរៀនសូត្រជាប្រចាំ និងការកែលម្អគុណភាពសេវាសុខភាពមាតានិងទារក ។

### 6.3.2. វិសាលភាព នៃការងារ និងការទទួលខុសត្រូវ

- **វិសាលភាព**

  គណៈកម្មការ MPDSR ថ្នាក់មន្ទីរពេទ្យ ត្រូវ ៖
  - ធ្វើការពិនិត្យឡើងវិញលើករណីមរណភាពមាតា ករណីស្លាប់កើត និងកើតស្លាប់របស់ទារកនៅក្នុងមន្ទីរពេទ្យ។
  - ប្រមូល និងវិភាគទិន្នន័យដើម្បីកំណត់ពីលំនាំនិងនិន្នាការ នៃមរណភាពមាតានិងទារកជុំវិញកំណើត។
  - រៀបចំ និងបង្ហាញរបកគំហើញដល់ថ្នាក់ដឹកនាំមន្ទីរពេទ្យនិងភាគីពាក់ព័ន្ធ។
  - រៀបចំផែនការ និងអនុវត្តសកម្មភាពដោយផ្អែកលើរបកគំហើញ និងត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃអន្តរាគមន៍។
  - តាមដានគុណភាព នៃការថែទាំ និងសូចនាករលទ្ធផលជាប្រចាំ។
  - ផ្តល់ព័ត៌មានត្រឡប់ដល់មណ្ឌលសុខភាព។
  - ធានាការសម្ងាត់ និងការរក្សាទិន្នន័យមរណភាពក្នុងអំឡុងពេលពិនិត្យករណីមរណភាព។

- **ភាពញឹកញាប់ នៃកិច្ចប្រជុំ**

  គណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើតនិងការឆ្លើយតប នឹងជួបប្រជុំនៅក្នុងអំឡុងពេល៧២ម៉ោង ក្រោយមរណភាពកើតឡើង។ ទោះជាយ៉ាងណាមរណភាពទារកជុំវិញកំណើតអាចមានឡើងច្រើនជាង ដែលមិនអាចរៀបចំការប្រជុំបានញឹកញាប់។ ក្នុងករណីនេះ ការពិនិត្យករណីមរណភាពអាចធ្វើឡើងជាទៀងទាត់រៀងរាល់ខែ ជាមួយនឹងការតាមដាន និងកែលម្អគុណភាពសេវា និងអនុវត្តសកម្មភាព។

- **របាយការណ៍ និងគណនេយ្យភាព**
  - គណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតបនឹងផ្តល់របាយការណ៍ប្រចាំត្រីមាសដោយបញ្ជាក់ពីរបកគំហើញសំខាន់ៗ អនុសាសន៍ និងវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពដល់គណៈកម្មការថ្នាក់ខេត្ត។
  - ផ្តល់ព័ត៌មានត្រឡប់អំពីករណីមរណភាពទៅដល់ក្រុមគ្រួសាររបស់សព។

- **រក្សាការសម្ងាត់**

- សមាជិកទាំងអស់របស់គណៈកម្មការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប ត្រូវតែរក្សាការសម្ងាត់ទាក់ទងនឹងព័ត៌មានមរណភាព និងទិន្នន័យដែលរសើបដែលបានពិភាក្សាក្នុងអំឡុងពេលពិនិត្យករណីមរណភាពឡើងវិញ។
- ដើម្បីពង្រឹងការងារនេះ ការរក្សាការសំងាត់ និងគោលការណ៍មិនមែនចាប់កំហុស ត្រូវតែបញ្ជាក់ឡើងវិញនៅរាល់ពេលចាប់ផ្តើមការប្រជុំរបស់គណៈកម្មការ ។
- របកគំហើញ និងអនុសាសន៍នឹងត្រូវបានរក្សាជាអនាមិកមិនមានឈ្មោះមុនពេលចែកចាយទៅក្រៅគណៈកម្មការ។

- **ធនធាន និងការគាំទ្រ**

រដ្ឋបាលរបស់មន្ទីរពេទ្យត្រូវធានាថាគណៈកម្មការពិនិត្យមរណភាពមាតាជុំវិញកំណើត និងការឆ្លើយតបមានប្រភពធនធានថវិកាគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពរបស់ខ្លួន ដូចជា ៖

- ការពិនិត្យមើលឯកសារអ្នកជំងឺ និងទិន្នន័យគ្លីនិក។
- ការគាំទ្រផ្នែករដ្ឋបាលសម្រាប់ការរៀបចំកិច្ចប្រជុំ និងឯកសារ។
- ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការបណ្តុះបណ្តាលសមាជិកគណៈកម្មការ និងសម្រាប់ការអនុវត្តផែនការសកម្មភាព។

- **ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ**

- គណៈកម្មការនឹងវាយតម្លៃប្រសិទ្ធភាពរបស់ខ្លួនជាទៀងទាត់ ដោយពិនិត្យឡើងវិញលើការអនុវត្តផែនការសកម្មភាព និងផលជះ នៃការអនុវត្តផែនការនេះលើការកាត់បន្ថយមរណភាពមាតា និងទារកជុំវិញកំណើត។

### 6.3.3 សមាសភាគរបស់គណៈកម្មការ

គណៈកម្មការ MPDSR ថ្នាក់មន្ទីរពេទ្យ រួមមានមន្ត្រីចម្រុះគ្រប់ផ្នែកដែលមានជំនាញបច្ចេកទេសផ្នែកសុខភាពមាតា និងទារក។ ដើម្បីធានានូវភាពសមស្រប នៃដំណើរការ និងការចូលរួមបានទៀងទាត់ជាការសំខាន់ត្រូវមានការពិចារណាឱ្យបានម៉ត់ចត់នៅពេលចាត់តាំងសមាជិកភាព នៃគណៈកម្មការ។ ដើម្បីអាចសម្រេចបាននូវគោលបំណងនេះ ត្រូវមានសមាសភាពជាសមាជិកអចិន្ត្រៃយ៍ និងសមាជិកតាមការចាំបាច់ដែលនឹងត្រូវអញ្ជើញមកទៅតាមការចាំបាច់ទាក់ទងនឹងករណីនិមួយៗ។

- **សមាជិកអចិន្ត្រៃយ៍**

- ប្រធានមន្ទីរពេទ្យ
- ប្រធានបច្ចេកទេសមន្ទីរពេទ្យ
- ប្រធានផ្នែកថែទាំ
- ប្រធានផ្នែកសម្ភព
- ប្រធានផ្នែកប្រពោធនកម្មទារក ឬផ្នែកថែទាំទារក (NICU/NCU)
- ប្រធានផ្នែកសង្គ្រោះបន្ទាន់ (ICU)

- ប្រធានផ្នែកដាក់ថ្នាំសណ្តំ
- កោសល្យវិច័យនៅក្នុងមន្ទីរពេទ្យ
- គ្រូពេទ្យនៅផ្នែកសម្ភព
- ឆ្មប
- គ្រូពេទ្យនៅផ្នែកទារក ឬកុមារ (គ្រូពេទ្យឯកទេសជំងឺកុមារបើមាន)
- បុគ្គលិកថែទាំ
- បុគ្គលិកផ្នែកដាក់ថ្នាំសណ្តំ
- រដ្ឋបាលការីមន្ទីរពេទ្យ
- អ្នកគ្រប់គ្រងទិន្នន័យ/អ្នកឯកទេសខាងព័ត៌មានសុខាភិបាល
- តំណាងមកពីក្រុមការងារកែលម្អគុណភាព (QI) របស់មន្ទីរពេទ្យខេត្ត

**សមាជិកមិនអចិន្ត្រៃយ៍ (ករណីចាំបាច់)**

- តំណាងមកពីក្រុមការងារ MPDSR ថ្នាក់ខេត្ត
- តំណាងមកពីគ្រូពេទ្យព្យាបាល ឆ្មប គិលានុប្បដ្ឋាក ក្រុមប្រឹក្សាភិបាលគិលានុប្បដ្ឋាក នៅថ្នាក់ខេត្ត

- **លេខាធិការដ្ឋាន**

សមាសភាព៖ សមាសភាពរបស់លេខាធិការដ្ឋានថ្នាក់មន្ទីរពេទ្យមាន ប្រធានផ្នែកសម្ភព ប្រធានផ្នែកប្រពោធនកម្មទារក ឬផ្នែកថែទាំទារក (NICU/NCU) និងប្រធានឆ្មប

**តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន រួមមាន ៖**

- ពិនិត្យប្រព័ន្ធចុះទិន្នន័យសុខាភិបាលឌីជីថលលិខិតជូនដំណឹងអំពីមរណភាព (NCOD) ដើម្បីកំណត់រកករណីមរណភាពមាតា និងទារកជុំវិញកំណើត
- រាយការណ៍ជូនគណៈកម្មាការថ្នាក់មន្ទីរពេទ្យ
- រៀបចំចាត់តាំងក្រុមប្រមូលទិន្នន័យ
- រៀបចំការប្រជុំមុនការប្រជុំពិនិត្យករណីមរណភាព និងសម្របសម្រួលកិច្ចប្រជុំ MPDSR
- រៀបចំអនុសាសន៍ និងផែនការសកម្មភាពពីកិច្ចប្រជុំ MPDSR
- ធានាថារបាយការណ៍មិនមានដាក់បញ្ចូលព័ត៌មានអត្តសញ្ញាណ ។
- ដាក់បញ្ជូនរបាយការណ៍ទៅគណៈកម្មាការថ្នាក់រាជធានី ខេត្ត ឬគណៈកម្មាការជាតិលេខាធិការដ្ឋានរាយការណ៍ទៅប្រធានគណៈកម្មាការថ្នាក់មន្ទីរពេទ្យ

## 7- ជំហាន នៃការតាមដាន និងឆ្លើយតបចំពោះមរណភាពមាតា និងទារកជុំវិញកំណើត

1. កំណត់អត្តសញ្ញាណករណី
2. ប្រមូលព័ត៌មាន
3. ពិនិត្យរួមគ្នាមរណភាពមាតា និងទារកជុំវិញកំណើត ការវិភាគ ការបង្ហាញព័ត៌មាន និងផ្តល់អនុសាសន៍អំពីសកម្មភាពដែលត្រូវអនុវត្ត
4. អនុវត្តន៍ការផ្លាស់ប្តូរ
5. តាមដាន ការអនុវត្ត MPDSR និងការកែលម្អគុណភាពសេវាសុខាភិបាល

**រូបភាពទី 4. លំហូរនៃការតាមដាន និងឆ្លើយតបចំពោះមរណភាពមាតា និងទារកជុំវិញកំណើតទាំងនៅមូលដ្ឋានសុខាភិបាល និងក្រៅមូលដ្ឋានសុខាភិបាល**



## 7.1 កំណត់អត្តសញ្ញាណករណី

### មរណភាពនៅមូលដ្ឋានសុខាភិបាលដែលមានគណៈកម្មាការ MPDSR

ក្រុមការងារលេខាធិការដ្ឋានត្រូវត្រួតពិនិត្យរៀងរាល់ថ្ងៃ លិខិតជូនដំណឹងមរណភាពដែលកើតមានឡើងនៅក្នុងមន្ទីរពេទ្យអំពីមរណភាពមាតា និងទារកជុំវិញកំណើត និងកំណត់អត្តសញ្ញាណករណី ធ្វើរបាយការណ៍ជូនដល់គណៈកម្មាការ MPDSR មន្ទីរពេទ្យរបស់ខ្លួនភ្លាមៗ។ នៅពេលដែលករណីមរណភាពមាតា និងទារកជុំវិញកំណើតភាគច្រើនកើតឡើងនៅបន្ទប់សម្រាលនិងក្រោយសម្រាល ជាការសំខាន់ដែលត្រូវកំណត់បាននូវករណីមរណភាពដែលកើតឡើងនៅតាមផ្នែកផ្សេងៗរបស់មន្ទីរពេទ្យ ដូចជាផ្នែកជំងឺទូទៅ ផ្នែកសង្គ្រោះបន្ទាន់ជាដើម។ គណៈកម្មាការមន្ទីរពេទ្យត្រូវបង្កើនការយល់ដឹង និងធានាថាគ្រប់ករណីមរណភាពមាតា និងទារកជុំវិញកំណើតត្រូវតែកំណត់ អត្តសញ្ញាណបាន និងរាយការណ៍ទោះបីជាមរណភាពនោះកើតឡើងនៅផ្នែកណាមួយ នៃមូលដ្ឋានសុខាភិបាលក៏ដោយ ។

### ការស្លាប់នៅមណ្ឌលសុខភាព គ្លីនិកឯកជន និងមន្ទីរពេទ្យដែលមិនមានគណៈកម្មាការ MPDSR

មណ្ឌលសុខភាព គ្លីនិកឯកជន និងនៅមន្ទីរពេទ្យដែលគ្មានគណៈកម្មាការ MPDSR ត្រូវតែបញ្ចូលទិន្នន័យមរណភាពទៅក្នុងប្រព័ន្ធ NCOD ។ លេខាធិការដ្ឋានរបស់គណៈកម្មាការខេត្តត្រូវពិនិត្យតាមដាន NCOD រៀងរាល់ថ្ងៃ និងពិនិត្យរកករណីមរណភាពមាតា និងទារកជុំវិញកំណើត ដើម្បីផ្ទៀងផ្ទាត់ករណីមរណភាពដែលកើតមាននៅតំបន់គ្របដណ្តប់ និងរាយការណ៍ទៅគណៈកម្មាការថ្នាក់ខេត្ត។

### មរណភាពនៅក្រៅមូលដ្ឋានសុខាភិបាល

លេខាធិការដ្ឋានរបស់គណៈកម្មាការថ្នាក់ខេត្តត្រូវតែពិនិត្យ NCOD រៀងរាល់ថ្ងៃ និងពិនិត្យរកដើម្បីកំណត់អត្តសញ្ញាណមរណភាពមាតា និងទារកជុំវិញកំណើត ដែលកើតក្រៅមូលដ្ឋានសុខាភិបាលតែនៅក្នុងតំបន់គ្របដណ្តប់របស់ខេត្ត និងរាយការណ៍ទៅគណៈកម្មាការថ្នាក់ខេត្ត ។

## 7.2 ការប្រមូលទិន្នន័យ ឬព័ត៌មាន

### មរណភាពនៅមន្ទីរពេទ្យដែលមានគណៈកម្មាការ MPDSR

នៅពេលដែលករណីមរណភាពមាតា ឬទារកជុំវិញកំណើតត្រូវបានកំណត់អត្តសញ្ញាណ (មើលលក្ខណៈវិនិច្ឆ័យនៅផ្នែកបន្ទាប់) លេខាធិការដ្ឋាន នៃគណៈកម្មាការថ្នាក់មន្ទីរពេទ្យនឹងរៀបចំចាត់តាំងក្រុមប្រមូលទិន្នន័យឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ ការប្រមូលទិន្នន័យធ្វើឡើងតែនៅមន្ទីរពេទ្យ ប៉ុន្តែបើមានតម្រូវការចាំបាច់ ក្រុមការងារនឹងត្រូវចុះប្រមូលទិន្នន័យដល់សហគមន៍។ ក្រុមប្រមូលទិន្នន័យនឹងព័ត៌មានដោយប្រើទម្រង់ពិនិត្យករណីមរណភាព (ឧបសម្ព័ន្ធទី ៣៖ ទម្រង់ពិនិត្យករណីមរណភាពមាតា និង ឧបសម្ព័ន្ធទី ៤៖ ទម្រង់ពិនិត្យករណីមរណភាពទារកជុំវិញកំណើត) ពីការពិនិត្យឯកសារកត់ត្រាវេជ្ជសាស្ត្ររបស់អ្នកជំងឺនៅមូលដ្ឋានសុខាភិបាល និងសម្ភាសន៍បុគ្គលិកនៅមូលដ្ឋានសុខាភិបាលដែលពាក់ព័ន្ធក្នុងការថែទាំករណីមរណភាពនោះ។ ជាការសំខាន់ដែរក្នុងការសម្ភាសន៍ជាមួយគ្រួសារករណីមរណភាពដើម្បីទទួលបានព័ត៌មានបន្ត និងពិនិត្យមើលថាតើមានព័ត៌មានណាខ្លះដែលមិនមានភាពស៊ីសង្វាក់គ្នា និងប្រមូលក្តីកង្វល់និងសំណួរនានារបស់ពួកគេ។

បន្ទាប់មកទម្រង់ពិនិត្យករណីមរណភាពត្រូវបានបំពេញសព្វគ្រប់ និងសេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរនឹងត្រូវបានរៀបចំ។

### ការស្លាប់នៅមណ្ឌលសុខភាព គ្លីនិកឯកជន និងមន្ទីរពេទ្យដែលមិនមានគណៈកម្មការ MPDSR

នៅពេលមានពិនិត្យមរណភាពមាតា ឬទារកជុំវិញកំណើត (មើលលក្ខណវិនិច្ឆ័យនៅផ្នែកបន្ទាប់) លេខាធិការដ្ឋាននៃគណៈកម្មការខេត្តនឹងរៀបចំចាត់តាំងក្រុមប្រមូលទិន្នន័យគ្រប់ករណីមរណភាពមាតាទាំងអស់ និងករណីមរណភាពទារកជុំវិញកំណើតខ្លះៗ។ ការប្រមូលទិន្នន័យនេះត្រូវធ្វើក្រោយ៧ថ្ងៃ និងមិនលើសពី៣០ថ្ងៃក្រោយមរណភាព។ មូលដ្ឋានសុខាភិបាលបានផ្តល់សេវាដល់ស្ត្រីត្រូវសហការ និងផ្តល់ព័ត៌មានចាំបាច់មួយចំនួនក្នុងពេលប្រមូលទិន្នន័យ។ ក្រុមអ្នកចុះប្រមូលទិន្នន័យប្រើទម្រង់សម្រាប់ពិនិត្យករណីមរណភាព (ឧបសម្ព័ន្ធទី ៣៖ ទម្រង់ពិនិត្យករណីមរណភាពមាតា និងឧបសម្ព័ន្ធទី ៤៖ ទម្រង់ពិនិត្យករណីមរណភាពទារកជុំវិញកំណើត) សម្រាប់ប្រមូលទិន្នន័យពីឯកសារការកត់ត្រាវេជ្ជសាស្ត្ររបស់អ្នកជំងឺនៅមូលដ្ឋានសុខាភិបាល និងប្រមូលព័ត៌មានដោយសម្ភាសន៍បុគ្គលិកនៅមូលដ្ឋានសុខាភិបាលរួមទាំងបុគ្គលិក ដែលធ្វើការនៅមន្ទីរពេទ្យឯកជនដែលពាក់ព័ន្ធក្នុងការថែទាំករណីមរណភាពនោះ។ ជាការសំខាន់ដែរក្នុងការសម្ភាសន៍ជាមួយគ្រួសារករណីមរណភាពដើម្បីទទួលបានព័ត៌មានបន្ថែម និងពិនិត្យមើលថាតើមានព័ត៌មានណាខ្លះដែលមិនមានភាពស៊ីសង្វាក់គ្នា និងប្រមូលក្តីកង្វល់ និងសំណួរនានារបស់ពួកគេ។ បន្ទាប់មកទម្រង់ពិនិត្យករណីមរណភាពត្រូវបានបំពេញសព្វគ្រប់ និងសេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរនឹងត្រូវបានរៀបចំ។

ដើម្បីឱ្យដំណើរការចុះប្រមូលទិន្នន័យ និងការស្រាវជ្រាវមរណភាពនៅក្រៅមូលដ្ឋានសុខាភិបាលប្រកបដោយប្រសិទ្ធភាព កិច្ចសហការជាមួយមណ្ឌលសុខភាពក្នុងតំបន់ និងអាជ្ញាធរមូលដ្ឋានជាការសំខាន់បំផុត។ បើគ្មានការគាំទ្ររបស់ពួកគេទេ ការប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយអំពីករណីមរណភាពទាំងនេះ មិនអាចធ្វើទៅបាននោះទេ។

### ការស្លាប់នៅក្រៅមូលដ្ឋានសុខាភិបាល (នៅសហគមន៍)

ស្រដៀងគ្នាករណីមរណភាពមាតាស្ថិតនៅមូលដ្ឋានសុខាភិបាលដែលមិនមានគណៈកម្មការ MPDSR ដូចករណីខាងលើ នៅពេលដែលករណីមរណភាពមាតា និងទារកត្រូវបានកំណត់អត្តសញ្ញាណ (មើលលក្ខណៈវិនិច្ឆ័យនៅផ្នែកបន្ទាប់) លេខាធិការដ្ឋាន នៃគណៈកម្មការខេត្តនឹងរៀបចំចាត់តាំងក្រុមប្រមូលទិន្នន័យគ្រប់ករណីមរណភាពមាតាទាំងអស់ និងករណីមរណភាពទារកជុំវិញកំណើតមួយចំនួន។ ការប្រមូលទិន្នន័យនេះត្រូវធ្វើក្រោយរយៈពេល៧ថ្ងៃ និងមិនលើសពី៣០ថ្ងៃក្រោយមរណភាព។ ក្រុមអ្នកចុះប្រមូលទិន្នន័យនឹងសំភាសន៍ជាមួយក្រុមគ្រួសារសព និងអ្នកដែលបានដឹងឮជុំវិញករណីមរណភាព។

ដើម្បីឱ្យដំណើរការចុះប្រមូលទិន្នន័យ និងការស្រាវជ្រាវមរណភាពនៅក្រៅមូលដ្ឋានសុខាភិបាលប្រកបដោយប្រសិទ្ធភាព កិច្ចសហការជាមួយមណ្ឌលសុខភាពក្នុងតំបន់ និងអាជ្ញាធរមូលដ្ឋានជាការសំខាន់បំផុត។ បើគ្មានការគាំទ្ររបស់ពួកគេទេ ការប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយអំពីករណីមរណភាពទាំងនេះ មិនអាចធ្វើទៅបាននោះទេ។

ក្រុមប្រមូលទិន្នន័យនឹងសម្ភាសន៍គ្រួសារសព និងសហគមន៍ដោយប្រើទម្រង់ពិនិត្យករណីមរណភាព (ឧបសម្ព័ន្ធទី៣៖ ទម្រង់ករណីមរណភាពមាតា និងឧបសម្ព័ន្ធទី៤៖ទម្រង់ពិនិត្យករណីមរណភាពទារកជុំវិញការសម្រាល)។ បន្ទាប់មក ទម្រង់ពិនិត្យករណីមរណភាពត្រូវបានបំពេញសព្វគ្រប់ និងសេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរនឹងត្រូវបាន រៀបចំ។

**សមាសភាពក្រុមចុះប្រមូលទិន្នន័យ**

- សមាជិកគណៈកម្មាការ MPDSR ថ្នាក់ខេត្ត (បុគ្គលិក ឬផ្នែកគាំពារមាតា និងទារកខេត្ត)
- វេជ្ជបណ្ឌិតធ្វើការនៅសម្ភព ឬគ្រូពេទ្យផ្នែកកុមារ ធ្វើការនៅមន្ទីរពេទ្យខេត្ត ឬមន្ទីរពេទ្យបង្អែក
- បុគ្គលិកផ្សេងៗទៀតបើចាំបាច់ (មន្ត្រីរបស់ស្រុកប្រតិបត្តិ ឬឆ្មបនៅតាមមណ្ឌលសុខភាព)

**លក្ខខណ្ឌយោងរបស់ក្រុមចុះប្រមូលទិន្នន័យ**

**១- ការប្រមូលទិន្នន័យ** ៖ ក្រុមការងារនឹងប្រមូលទិន្នន័យជាលក្ខណៈប្រព័ន្ធនូវអ្វីដែលបានកើតឡើងតាំងពី នៅផ្ទះ ទៅមណ្ឌលសុខភាព ឬនៅកន្លែងផ្សេងៗទៀតដែលមានពាក់ពន្ធ័ជាមួយមរណភាព។

ព័ត៌មាននឹងទទួលបានដោយ ៖

ក- សម្ភាសន៍ជាមួយក្រុមគ្រួសារញាតិសណ្តានរបស់សព និងសមាជិកផ្សេងៗទៀតនៅក្នុងសហគមន៍

ខ- សម្ភាសន៍ជាមួយគ្រូពេទ្យដែលពិនិត្យព្យាបាលស្ត្រីមុនមរណភាព

គ- ពិនិត្យឯកសារកត់ត្រាវេជ្ជសាស្ត្រទាំងអស់ដែលទាក់ទង

រាល់ព័ត៌មានទាំងអស់ត្រូវបញ្ចូលទៅក្នុងទម្រង់សម្រាប់ពិនិត្យករណីមរណភាពដែលសមស្រប (ឧបសម្ព័ន្ធទី ៣ និងទី៤)។

ការសម្ភាសន៍ជាមួយក្រុមគ្រួសារ និងសាច់ញាត្តិរបស់សពគឺត្រូវធ្វើឡើងដោយការអាណិតអាសូរ និងប្រយ័ត្ន ប្រយែង (sensitive) និងធានាថាមានការគោរពដល់អារម្មណ៍របស់គ្រួសារសព ។ ប្រសិនបើចាំបាច់ ការគាំទ្រផ្លូវចិត្តត្រូវតែផ្តល់ជូន និងរៀបចំឡើង។ ជាការសំខាន់ណាស់ដែលត្រូវជម្រាបជូនច្បាស់ពីគោល បំណង នៃដំណើរការ MPDSR ដោយសង្កត់ធ្ងន់ថាការងារនេះមានគោលបំណងស្វែងរកកង្វះខាត នៃប្រព័ន្ធ ដើម្បីរកដំណោះស្រាយកុំឱ្យមានបញ្ហាដូចគ្នានេះកើតមានឡើងនៅពេលអនាគត។

**គោលការណ៍ទូទៅក្នុងការបំពេញទម្រង់**

- ជៀសវាងការសន្មត់៖ ប្រសិនបើខ្វះខាតព័ត៌មានណាមួយ ដូចជាលទ្ធផលនៃតេស្តស្តង់ដា ចូរគូស សម្គាល់ "មិនដឹង" កុំសន្មត់ ឬទុកវាចោលមិនបំពេញ។
- ពិចារណារកប្រភពទិន្នន័យ៖ សម្រាប់ទិន្នន័យមួយចំនួនដូចជាអាយុ នៃគភ៌ជាការសំខាន់ណាស់ ដែលត្រូវបញ្ជាក់ប្រភពនៃព័ត៌មាននេះ (ឧទាហរណ៍- ការប៉ាន់ស្មានរដូវចុងក្រោយរបស់ម្តាយ តាមរយៈ អេកូសាស្ត្រពីលើកមុន ឬក្រោយ។ល។)
- ដោះស្រាយភាពផ្ទុយគ្នា៖ ព័ត៌មាននៅក្នុងតារាង ឬក្រាហ្វិច និងសៀវភៅកំណត់ត្រាជួនកាលអាច ផ្ទុយគ្នា។ ជាការសំខាន់ដែលត្រូវរំលេចភាពខុសគ្នាទាំងនេះក្នុងអំឡុងពេលដំណើរពិនិត្យករណី និង

ព្យាយាមកែតម្រូវ ឬបំភ្លឺចំណុចទាំងនោះ មុនពេលរាយការណ៍ទិន្នន័យទៅកាន់ថ្នាក់កម្រិតខ្ពស់ជាងនេះរបស់ប្រព័ន្ធសុខាភិបាល។

**២- សង្ខេបទិន្នន័យ ៖**

ក្រុមប្រមូលទិន្នន័យនឹងជួបប្រជុំដើម្បីចងក្រងព័ត៌មាន ដើម្បីស្វែងយល់ឱ្យបានច្បាស់អំពីព្រឹត្តិការណ៍ដែលបណ្តាលឱ្យមានមរណភាពកើតឡើង។ នៅមុនកិច្ចប្រជុំគណៈកម្មាការថ្នាក់ខេត្ត ឬថ្នាក់មន្ទីរពេទ្យ ប្រធានក្រុម អ្នកប្រមូលទិន្នន័យដែលមានជំនាញ និងបទពិសោធន៍ក្នុងការរាយការណ៍ ត្រូវរៀបចំសង្ខេបព័ត៌មានសំខាន់ៗមួយចំនួនសម្រាប់ករណីស្លាប់នីមួយៗ រួមទាំងទិន្នន័យដែលពាក់ព័ន្ធទាំងអស់។
សេចក្តីសង្ខេបគួររំលេចចំណុចទាំងឡាយដូចខាងក្រោម ៖

- ចំណុចសំខាន់ៗពីបញ្ជីត្រួតពិនិត្យ (checklists)
- កត្តា ឬមូលហេតុដែលអាចជៀសវាងបាន និងចំណាត់ថ្នាក់របស់មូលហេតុទាំងនោះ
- សម្រង់សំដីដែលពាក់ព័ន្ធពីបទសម្ភាសន៍
- ចំណុចមិនស៊ីសង្វាក់គ្នារវាងប្រភពទិន្នន័យ។

ការវាយតម្លៃមុន (pre-review assessment) នឹងបង្ហាញពីមូលហេតុ នៃការស្លាប់ កត្តារួមចំណែក និងកត្តាដែលអាចកែសម្រួលបាន។

## 7.3 ការពិនិត្យរួមគ្នាករណីមរណភាពមាតា និងទារកជុំវិញកំណើត ការវិភាគព័ត៌មាន និងផ្តល់អនុសាសន៍ពីការស្លាប់នៅមូលដ្ឋានសុខាភិបាលសាធារណៈដែលមានគណៈកម្មាការ MPDSR

គណៈកម្មាការមន្ទីរពេទ្យត្រូវរៀបចំការពិនិត្យករណីក្នុងរយៈពេល៧២ម៉ោង បន្ទាប់ពីមានការស្លាប់របស់ម្តាយនៅក្នុងមន្ទីរពេទ្យ។ ការកំណត់អំពីមូលហេតុ កត្តាចំបងៗដែលអាចឱ្យមានករណីមរណភាព និងការរៀបចំផែនការ សម្មភាពឆ្លើយតបនឹងត្រូវបានបំពេញនៅពេលប្រជុំពិនិត្យករណី។ ករណីមរណភាពទារកជុំវិញកំណើតត្រូវប្រជុំជារៀងរាល់ខែជាទៀងទាត់ បើទោះមិនមានករណីមរណភាពទេ គណៈកម្មាការមន្ទីរពេទ្យត្រូវរាយការណ៍ថាមិនមានករណីស្លាប់ក្នុងខែនេះ (zero reporting) ។

## មរណភាពនៅមណ្ឌលសុខភាព មរណភាពនៅគ្លីនិកឯកជន និងនៅមន្ទីរពេទ្យដែលគ្មានគណៈកម្មាការ ឬមរណភាពនៅសហគមន៍

គណៈកម្មាការខេត្ត MPDSR ត្រូវធ្វើការពិនិត្យជាបន្ទាន់តាមតែអាចធ្វើទៅបានក្រោយពីប្រមូលព័ត៌មានរួចរាល់ក្នុងអំឡុងពេលមួយខែបន្ទាប់ពីមរណភាព។ ការកំណត់អំពីមូលហេតុ កត្តាចំបងៗដែលអាចឱ្យមានករណីមរណភាពកើតឡើង និងផែនការសម្មភាពរបស់ករណីមរណភាពនិមួយៗនឹងត្រូវបានបំពេញ នៅពេលពិនិត្យករណី។

### ក- ការជ្រើសរើសករណីមរណភាពមកពិនិត្យ

**ករណីមរណភាពរបស់មាតា៖** រាល់មរណភាពមាតាទាំងអស់ត្រូវតែពិនិត្យដោយគ្មានទការលើកលែង។

**ករណីមរណភាពរបស់ទារក៖** នៅក្នុងមន្ទីរពេទ្យធំៗដែលមានបន្ទុកករណីមរណភាពច្រើន គេអាចជ្រើសរើសយកគំរូករណីមួយចំនួនសម្រាប់ការពិនិត្យ។ ឧទាហរណ៍ការពិនិត្យ ស៊ីជម្រៅលើមរណភាព ២-៣ ករណីក្នុងនៅពេល ប្រជុំមួយលើក។ ការជ្រើសរើសករណី គឺផ្តោតសំខាន់ទៅលើករណីដែលអាចជួយសង្គ្រោះជីវិតបាននៅពេលធ្វើ អន្តរាគមន៍ និងជាមួយធនធានដែលមាន ឧទាហរណ៍ យើងពិបាកនឹងជួយសង្គ្រោះចំពោះទារកកើតមានទម្ងន់ទាបជាង ១៥០០ក្រាម។

ខាងក្រោមនេះជាករណីអាទិភាពដែលត្រូវតែលើកយកមកពិនិត្យ៖

- ការស្លាប់កើតជុំវិញពេលសម្រាល (Intrapartum stillbirth)៖ ករណីមរណភាពរបស់ទារកដែលស្តាប់ឮចង្វាក់បេះដូងទារកនៅពេលមកដល់មន្ទីរពេទ្យ ករណីនេះគួរបញ្ចូលក្នុងការពិនិត្យ។
- ការស្លាប់របស់ទារកក្នុងសប្តាហ៍ដំបូងនៃជីវិត (Early perinatal death)៖ ករណីមរណភាពដែលកើតឡើងក្នុងអំឡុងពេល ៧ ថ្ងៃដំបូងនៃជីវិត គួរតែត្រូវត្រួតពិនិត្យឡើងវិញ។
- ស្លាប់នៅពេលមុនសម្រាល (Antepartum stillbirth)៖ ករណីមរណភាពដែលកើតមានឡើងមុនពេលឈឺពោះសម្រាលគួរតែត្រូវពិនិត្យប្រសិនបើអាច។

### ខ- ក្រមសីលធម៌ប្រតិបត្តិ

សមាជិកទាំងអស់ នៃគណៈកម្មការ MPDSR ត្រូវគោរពក្រមសីលធម៌ប្រតិបត្តិដូចខាងក្រោម ។ សមាជិកគ្រប់រូប នៃគណៈកម្មការ MPDSR ត្រូវធ្វើការប្តេជ្ញាចិត្តជាលាយលក្ខណ៍អក្សរ (ឧបសម្ព័ន្ធទី ៦៖ ការបំពេញតាមក្រមសីលធម៌ប្រតិបត្តិ) ។

- សមាជិកទាំងអស់ នៃគណៈកម្មការ MPDSR ត្រូវតែរក្សាការសម្ងាត់ទាក់ទងនឹងព័ត៌មានអ្នកជំងឺ និងទិន្នន័យរសើបដែលបានពិភាក្សាក្នុងអំឡុងពេលពិនិត្យករណី។
- ចូលរួមប្រជុំពិនិត្យករណីមរណភាពទាន់ពេលវេលា។
- ចូលរួមយ៉ាងសកម្មក្នុងការពិភាក្សាផ្តល់យោបល់។
- គោរពមតិ និងរបៀប នៃការផ្តល់យោបល់របស់គ្រប់សមាជិក។
- ទទួលយកលទ្ធផលការពិភាក្សា និងទោះបីជាគំនិតដែលបានលើកឡើងមានការខ្វែងគំនិតគ្នាជៀសវាងការបំពានពាក្យសម្តី។
- គោរពការសម្ងាត់ នៃការពិភាក្សាដែលកើតឡើងក្នុងអំឡុងពេលកិច្ចប្រជុំ។
- យល់ព្រមមិនលាក់បាំងព័ត៌មានដែលមានប្រយោជន៍ ឬមិនក្លែងបន្លំព័ត៌មានដែលអាចផ្តល់ការយល់ដឹងអំពីករណីដែលកំពុងត្រូវបានធ្វើការពិនិត្យពិគ្រោះពិភាក្សា។
- ព្យាយាមឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន (ទទួលស្គាល់ថា វាមិនមែនជារឿងងាយស្រួលនោះទេ) ដើម្បីទទួលយកថាសកម្មភាពផ្ទាល់របស់អ្នកអាចនឹងត្រូវបានសួរនាំ។

## គ- ភាពញឹកញាប់ នៃកិច្ចប្រជុំ

- គណៈកម្មការថ្នាក់មន្ទីរពេទ្យ៖ យ៉ាងហោចណាស់ម្តងក្នុងមួយខែ ដោយមានការប្រជុំបន្ថែមនៅពេលពិនិត្យមរណភាពមាតា ។
- គណៈកម្មការថ្នាក់ខេត្ត៖ យ៉ាងហោចណាស់រៀងរាល់ខែ ដោយមានការប្រជុំបន្ថែមនៅពេលមានករណីមរណភាពដែលកើតមាននៅក្នុងសហគមន៍ ។
- គណៈកម្មការថ្នាក់ជាតិ៖ យ៉ាងហោចណាស់រៀងរាល់ខែ ដោយមានការប្រជុំបន្ថែមនៅពេលមានករណីមរណភាពដែលកើតមាននៅក្នុងសហគមន៍។

## ឃ- របៀបវារៈ នៃកិច្ចប្រជុំ

a. ពិនិត្យឡើងវិញលើកំណត់ហេតុកិច្ចប្រជុំពីលើកមុន (ពិនិត្យមើលអនុសាសន៍ និងការអនុវត្ត)

b. ការពិនិត្យករណីមរណភាពមាតា៖ មូលហេតុ នៃការស្លាប់ កត្តារួមចំណែកកត្តាដែលអាចកែតម្រូវបាន។

c. ការពិនិត្យករណីស្លាប់របស់ទារកជុំវិញកំណើត៖ មូលហេតុ នៃការស្លាប់កត្តារួមចំណែកកត្តាដែលអាចកែតម្រូវបាន។

d. ពិនិត្យលើសូចនាករសម្រាប់ការត្រួតពិនិត្យតាមដានជាប្រចាំ

e. កំណត់ពីកត្តាដែលអាចកែតម្រូវបាន

f. អនុសាសន៍សម្រាប់វិធានការដែលត្រូវអនុវត្ត រួមទាំងការពិនិត្យសកម្មភាពឆ្លើយតបទាំងអស់ដែលបានដាក់អនុវត្តកន្លងមក

លេខាធិការត្រូវធ្វើកំណត់ហេតុកិច្ចប្រជុំ និងបំពេញទម្រង់ទាំងអស់នៅក្នុងអំឡុងពេលដំណើរការពិនិត្យមរណភាព (កំណត់ហេតុកិច្ចប្រជុំអំពី MPDSR ត្រូវមានការកត់ត្រា និងសកម្មភាពដែលត្រូវអនុវត្តក្នុងទម្រង់របាយការណ៍)។

## ង- ការវិភាគ និងការបង្ហាញព័ត៌មាន

ទិន្នន័យបែបបរិមាណ និងគុណភាពនឹងត្រូវបានវិភាគ និងបង្ហាញតាមវិធីដែលកំណត់ពីលំនាំ និងនិន្នាការបំភ្លឺនូវដំណោះស្រាយអាទិភាពមួយចំនួនដែលអាចមានជុំវិញមរណភាព។

ជាផ្នែកមួយ នៃដំណើរការត្រួតពិនិត្យតាមដានជាប្រចាំនៅតាមមូលដ្ឋានសុខាភិបាលគឺជាសូចនាករ ត្រូវតែធ្វើឡើងដើម្បីយល់ដឹងអំពីគុណភាពក្នុងការអនុវត្តការងាររបស់មន្ទីរពេទ្យ ។

ផ្ទាំងបង្ហាញព័ត៌មានត្រួតពិនិត្យតាមដានគុណភាព នៃការថែទាំ (A quality – of – care Monitoring dashboard) គឺជាឧបករណ៍ដ៏មានតម្លៃមួយសម្រាប់យល់ដឹងអំពីសូចនាករទាំងនេះ រួមទាំងគុណតម្លៃសកម្មភាពបច្ចុប្បន្ន និងនិន្នាការអនុវត្តការងារកន្លងមកតាមលំដាប់លំដោយ។ ទម្រង់សង្ខេបប្រចាំខែរបស់មូលដ្ឋានសុខាភិបាល (ឧបសម្ព័ន្ធទី ៨៖ ទម្រង់សង្ខេបប្រចាំខែរបស់មូលដ្ឋានសុខាភិបាល) ត្រូវបានបំពេញ និងភ្ជាប់ទៅនឹងកំណត់ហេតុពេលប្រជុំ។

### ច- ការផ្តល់អនុសាសន៍អំពីសកម្មភាពដែលត្រូវអនុវត្ត

គណៈកម្មាការនឹងផ្តល់អនុសាសន៍អំពីវិធានការការងារក្នុងគោលបំណង ទប់ស្កាត់មរណភាពនៅពេលអនាគត។ អនុសាសន៍នេះត្រូវបានគេចាត់ទុកថាទាក់ទងទៅនឹងកត្តាដែលអាចកែតម្រូវបាន ក្រោយពីកំណត់អត្តសញ្ញាណរបស់មរណភាព។ អនុសាសន៍ត្រូវតែ « SMART ជាក់លាក់ វាស់វែងបាន សមរម្យ អាចធ្វើបាន និងមានពេលវេលាជាក់លាក់ » ទម្រង់សម្រាប់ផែនការសកម្មភាពមានភ្ជាប់ជាឧបសម្ព័ន្ធ ទី៧ ទម្រង់កំណត់ហេតុកិច្ចប្រជុំពិនិត្យរួមគ្នានៃ MPDSR និងទម្រង់សកម្មភាពដែលត្រូវអនុវត្ត។

## 7.4 អនុវត្តសកម្មភាពដើម្បីការកែលម្អ

ការកំណត់បញ្ហាដែលអាចជៀសវាងបាន និងដំណោះស្រាយមិនមែនតែចប់ត្រឹមនេះទេ។ ក្រុម MPDSR ត្រូវឯកភាពគ្នាលើយុទ្ធសាស្ត្រសម្រាប់ផ្សព្វផ្សាយរបកគំហើញ និងជំរុញសកម្មភាពការងារ។ ការផ្សព្វផ្សាយនឹងត្រូវធ្វើឡើងនៅគ្រប់កម្រិតថ្នាក់ និងគ្រប់ក្រុមគោលដៅផ្សេងៗគ្នាផងដែរ។ ក្រុមការងារ MPDSR គួរតែផ្តោតទៅលើ សារគន្លឹះដែលចង់បញ្ជូន ឬផ្តល់ទៅកាន់ក្រុមគោលដៅនីមួយៗ។ មន្ត្រីដែលទទួលខុសត្រូវក្នុងការអនុវត្តន៍សកម្មភាពការងារត្រូវប្រែក្លាយផែនការឱ្យទៅជាសកម្មភាព និងបញ្ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ និងគៀងគរប្រភពធនធានក្នុងការធ្វើការងារ។

របកគំហើញត្រូវផ្តល់ព័ត៌មានជូនក្រុមសំខាន់ៗទាំងបួនមានដូចជា ៖

- សហគមន៍ដែលមរណភាពទាំងនោះកើតឡើងនៅទីកន្លែងនោះ
- បុគ្គលិកធ្វើការនៅមូលដ្ឋានសុខាភិបាលដែលករណីមរណភាពបានកើតឡើង
- ក្រុមការងារ MPDSR ថ្នាក់ស្រុកប្រតិបត្តិ ឬថ្នាក់ខេត្ត
- អ្នកសម្រេចចិត្ត និងអាជ្ញាធរនៅថ្នាក់ខេត្ត ឬថ្នាក់ជាតិ។

ព័ត៌មានត្រឡប់គួរតែផ្តល់តម្លៃ និងថ្លែងអំណរគុណចំពោះបុគ្គលនានាដែលបានសហការ និងរួមបញ្ចូលទស្សនៈការយល់ឃើញរបស់សហគមន៍ផងដែរ។

នៅថ្នាក់មូលដ្ឋានសុខាភិបាល អ្នកសម្របសម្រួលអាចកំណត់សកម្មភាពជាក់លាក់ ដូចជាការផ្លាស់ប្តូរក្នុងកិច្ចការ ឬការបណ្តុះបណ្តាលបន្តអំពីជំនាញសង្គ្រោះជីវិតផ្នែកសម្ភព។ នៅទីនេះ តំណាងថ្នាក់ស្រុកដែលបានចូលរួមក្នុងក្រុម MPDSR គួរតែមានតួនាទីលើកឡើងអំពីចំណុចទាំងនេះជាមួយអាជ្ញាធរពាក់ព័ន្ធ។ ព័ត៌មានត្រឡប់គួរតែមានគោលបំណងស្ថាបនាជាងការស្តីបន្ទោស ដោយសង្កត់ធ្ងន់លើវិធីនានាដើម្បីកែលម្អសេវា ក្នុងពេលអនាគត។ បុគ្គលិកនៅមូលដ្ឋានសុខាភិបាល គួរតែត្រូវបានផ្តល់ជូននូវឱកាសដើម្បីផ្តល់យោបល់លើរបកគំហើញ និងផ្តល់យោបល់អំពីរបៀបពង្រឹង MPDSR នាពេលអនាគត។

## 7.5 តាមដានការអនុវត្តការងារ MPDSR និងការកែលម្អគុណភាព នៃការថែទាំ

ការអនុវត្តប្រកបដោយប្រសិទ្ធភាពការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប (MPDSR) តម្រូវឱ្យមានការតាមដានយ៉ាងជិតស្និទ្ធនិងជាប្រចាំ ដើម្បីធានាការសម្រេចបាននូវភាពប្រសើរឡើងនៃគុណភាពផ្តល់សេវា។ ការមានដំណើរការត្រួតពិនិត្យតាមដានដ៏រឹងមាំមួយ គឺជួយក្នុងការតាមដានវឌ្ឍនភាព

និងដោះស្រាយបញ្ហាប្រឈមបានទាន់ពេលវេលា។ ការត្រួតពិនិត្យតាមដានគួរតែផ្តោតលើសមាសធាតុសំខាន់ៗ ដូចខាងក្រោម៖

- **ការអនុវត្តអនុសាសន៍ ៖** វាយតម្លៃថាតើអនុសាសន៍អំពីសកម្មភាពដែលត្រូវបានកំណត់ក្នុងអំឡុងពេលពិនិត្យករណីមរណភាព កំពុងត្រូវបានអនុវត្តតាមការគ្រោងទុកដែរឬទេ។
- **ការប្រកាន់ខ្ជាប់តាមពេលវេលាកំណត់ ៖** វាយតម្លៃថាតើអនុសាសន៍កំពុងត្រូវបានអនុវត្តក្នុងគម្រោងពេលវេលាដែលបានស្នើឡើងឬទេ ដោយធានាថា ការពន្យារពេលត្រូវបានរកឃើញ និងដោះស្រាយភ្លាមៗ។
- **ប្រសិទ្ធភាព នៃវិធានការ៖** កំណត់ថាតើអនុសាសន៍ដែលបានអនុវត្ត នាំទៅរកលទ្ធផលដែលចង់បានដូចជាការកាត់បន្ថយមរណភាពមាតា និងទារក ឬការកែលម្អក្នុងការអនុវត្តផ្នែកគ្លីនិក។
- **កំណត់បញ្ហាប្រឈម ៖** ប្រសិនបើលទ្ធផលដែលចង់បានមិនត្រូវបានសម្រេច សូមតាមដានមើលឧបសគ្គ ឬចំណុចខ្វះខាតដែលអាចកើតមាននៅក្នុងដំណើរការអនុវត្តន៍។ កិច្ចការនេះអាចពាក់ព័ន្ធនឹងការពិនិត្យមើលកត្តានានា ដូចជា កង្វះខាតធនធាន ការបណ្តុះបណ្តាលបុគ្គលិក ការសម្របសម្រួលរវាងកម្រិតថ្នាក់ផ្សេងៗ នៃប្រព័ន្ធសុខាភិបាល ឬភាពសមស្រប នៃអន្តរាគមន៍។

បន្ថែមពីលើសមាសធាតុដែលបានរៀបរាប់ខាងលើ ការផ្តល់ព័ត៌មានត្រឡប់ជាទៀងទាត់ កិច្ចប្រជុំពិនិត្យមើលទិន្នន័យ និងការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំងអ្នកផ្តល់សេវាថែទាំសុខភាព ថ្នាក់ដឹកនាំមូលដ្ឋានសុខាភិបាល និងតំណាងសហគមន៍គឺជាការចាំបាច់ដើម្បីធានាថា ការតាមដានមិនត្រឹមតែជាសកម្មភាពឆ្លើយតបប៉ុណ្ណោះទេ ប៉ុន្តែជាការងារដែលត្រូវតែធ្វើជាប្រចាំដើម្បីកែលម្អគុណភាពផ្តល់សេវា។ ទិន្នន័យដែលបានមកពីការត្រួតពិនិត្យតាមដានត្រូវបានវិភាគ និងប្រើប្រាស់ដើម្បីកែសម្រួលយុទ្ធសាស្ត្រ ដោយធានាថាការរៀនសូត្រ និងការកែតម្រូវជាប្រចាំ ត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការតាមដាន និងឆ្លើយតបចំពោះមរណភាពមាតា និងទារកជុំវិញកំណើត។

## 8- ការតាមដាន និងឆ្លើយតបចំពោះមរណភាពមាតា និងទារកជុំវិញកំណើតក្នុងអំឡុងពេលមានគ្រោះមហន្តរាយ

### គោលបំណង

ក្នុងអំឡុងពេលមានគ្រោះមហន្តរាយ បន្ទុក នៃមរណភាពមាតានិងទារកជុំវិញកំណើត មានការកើនឡើងដោយសារការរំខានទៅលើសេវាថែទាំសុខភាព កង្វះហេដ្ឋារចនាសម្ព័ន្ធ និងសម្ពាធបន្ថែមទៀតទៅលើក្រុមដែលងាយរងគ្រោះរួចទៅហើយនោះ (មាតា និងទារក) ។ ពិធីសារនេះ បង្ហាញពីការបន្សាំជាក់លាក់ដែលចាំបាច់ដើម្បីថែរក្សាដំណើរការតាមដាន និងឆ្លើយតបចំពោះមរណភាពមាតា និងទារកជុំវិញកំណើត សមស្របតាមយុទ្ធសាស្ត្រជាតិក្នុងការរៀបចំផែនការត្រៀមឆ្លើយតបគ្រោះមហន្តរាយ (នាយកដ្ឋានការពារសុខភាពឆ្នាំ២០២០ ដល់ ឆ្នាំ២០២៤)។

### ចំណុចដែលគួរយកចិត្តទុកដាក់៖

- អត្រាមរណភាពកើនឡើង និងរបាយការណ៍មិនត្រឹមត្រូវ៖ គ្រោះមហន្តរាយអាចបណ្តាលឱ្យមានការកើនឡើង នៃមរណភាពមាតា និងទារកជុំវិញកំណើត ហើយករណីទាំងនោះអាចមិនត្រូវបានរាយការណ៍។
- ការតាមដាន និងឆ្លើយតបបន្ទាន់ ៖ វាមានសារៈសំខាន់ណាស់ដែលបុគ្គលិកសុខាភិបាល និងអាជ្ញាធរមូលដ្ឋានត្រូវតែមានការយកចិត្តទុកដាក់ក្នុងការ ប្រមូលទិន្នន័យអំពីមរណភាពដើម្បីផ្តល់ព័ត៌មាន និងការឆ្លើយតបបន្ទាន់។

### ចំណុចគន្លឹះសមស្របនៅពេលគ្រោះមហន្តរាយ៖

ប្រើប្រាស់គម្រោងសកម្មភាពការងាររបស់យុទ្ធសាស្ត្រជាតិក្នុងការរៀបចំផែនការត្រៀមឆ្លើយតបគ្រោះមហន្តរាយសម្រាប់សុខភាព (នាយកដ្ឋានការពារសុខភាព ឆ្នាំ២០២០ ដល់ឆ្នាំ២០២៤)។

| ដំណាក់កាល | យុទ្ធសាស្ត្រ |
|---|---|
| បង្ការហានិភ័យ និង កាត់បន្ថយហេតុការណ៍ ដែលកើតឡើង | • ពង្រឹងយន្តការការគ្រប់គ្រងប្រព័ន្ធគ្រោះមហន្តរាយ និងការឆ្លើយតបរបស់ផ្នែកសុខាភិបាល<br>• កំណត់កត្តាហានិភ័យ និងកត្តាដែលបង្កឱ្យមានគ្រោះមហន្តរាយកើតឡើង ដោយសហការជាមួយសហគមន៍ ដៃគូដែលពាក់ព័ន្ធ និងវិស័យឯកជន។ |
| ការរៀបចំ | • រៀបចំស្តង់ដារសម្រាប់ដំណើរការទំនាក់ទំនង (និយាមប្រតិបត្តិទំនាក់ទំនង) នៅពេលមានគ្រោះមហន្តរាយ។<br>• ពង្រឹងប្រព័ន្ធតាមដានប្រកាសអាសន្ន (EWS-Strengthen the Early Warning System) អំពីសុវត្ថិភាពក្នុងវិស័យសុខាភិបាល។<br>• ធ្វើបច្ចុប្បន្នភាពអំពីទិន្នន័យគ្រប់គ្រងគ្រោះមហន្តរាយ |

| | |
|---|---|
| ឆ្លើយតប | • រាប់ចំនួនមរណភាពរបស់មាតា ឬមរណភាពទារក<br>• ចុះប្រមូលទិន្នន័យបន្ទាន់ និងធ្វើការប៉ាន់ប្រមាណអំពីផលប៉ះពាល់ក្នុងការផ្តល់សេវាសុខភាព<br>• ពិនិត្យលើករណីមរណភាពមាតា និងទារក ជុំវិញកំណើត និងការឆ្លើយតប (MPDSR) មិនត្រូវបានលើកទឹកចិត្តឱ្យធ្វើទេនៅក្នុងពេលមានគ្រោះមហន្តរាយ |
| នៅពេលគ្រោះមហន្តរាយបានបញ្ចប់ | • រៀបចំប្រព័ន្ធតាមដានមរណភាពមាតា និងទារកនៅតាមមូលដ្ឋានសុខាភិបាលមានលក្ខណៈសាមញ្ញដោយប្រើទម្រង់ឧបករណ៍ប្រមូលទិន្នន័យខ្លី ឬតិចតួច ។<br>• បញ្ចូលជាសមាជិកនូវក្រុមការងារគ្រោះមហន្តរាយ ក្នុងក្រុមការងារពិនិត្យតាមដានមរណភាពមាតា ។<br>• ធ្វើការប្រជុំពិនិត្យករណីមរណភាពពីចំងាយនៅពេលដែលការធ្វើដំណើរត្រូវបានរឹតបន្តឹង។<br>• ផ្តល់អាទិភាពដល់ការផ្គត់ផ្គង់នូវការខ្វះខាតសម្ភារបរិក្ខា (ឧទាហរណ៍ ឈាម ឱសថសម្លាប់មេរោគ សម្ភារស្តេរីល)បុគ្គលិក និងរចនាសម្ព័ន្ធ<br>• សហការជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការកៀរគរធនធាន។ |

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១ ៖ តារាងតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាការ MPDSR ថ្នាក់មន្ទីរពេទ្យ ថ្នាក់ខេត្ត និង ថ្នាក់ជាតិ**

| | ថ្នាក់មន្ទីរពេទ្យ | ថ្នាក់ខេត្ត | ថ្នាក់ជាតិ |
|---|---|---|---|
| ការពិនិត្យករណីមរណភាព | • ករណីមរណភាពនៅមូលដ្ឋានសុខាភិបាល<br>• តាមដានទៀងទាត់អំពីគុណភាពថែទាំ | • ករណីមរណភាពក្នុងសហគមន៍ នៅមណ្ឌលសុខភាព នៅគ្លីនិកឯកជន<br>• មរណភាពនៅតាមមូលដ្ឋានសុខាភិបាល ដែលមិនមានគណៈកម្មការ<br>• គ្រប់ករណីមរណភាពមាតា និងទារកជុំវិញកំណើត<br>• តាមដានទៀងទាត់អំពីគុណភាពថែទាំ | • គ្រប់ករណីមរណភាពមាតា និងទារកជុំវិញកំណើត<br>• តាមដានទៀងទាត់អំពីគុណភាពថែទាំ |
| ភាពញឹកញាប់នៃ កិច្ចប្រជុំ | • ពិនិត្យមរណភាពក្នុងអំឡុងពេល៧២ម៉ោងបន្ទាប់ពីមរណភាព<br>• ជាប្រចាំរៀងរាល់ខែដើម្បីតាមដានការងារ | • ពិនិត្យករណីមរណភាពឱ្យបានឆាប់រហ័សក្រោយព័ត៌មានត្រូវបានប្រមូលពេញលេញ (ក្នុងអំឡុងពេល៧ថ្ងៃ ទៅ១ខែក្រោយមរណភាព)។<br>• ប្រជុំការងារឱ្យបានទៀងទាត់រៀងរាល់ខែដើម្បីតាមដានការងារ | • រៀងរាល់បីខែម្តងក្នុងការពិនិត្យករណីមរណភាព និងតាមដានសកម្មភាពការងារដែលបានអនុវត្ត<br>• ប្រជុំបន្ទាន់បើចាំបាច់ |
| រាយការណ៍ជូន | • គណៈកម្មាការថ្នាក់ខេត្ត (មន្ទីរពេទ្យជាតិរាយការណ៍ជូនគណៈកម្មាការថ្នាក់ជាតិ) | • គណៈកម្មាការថ្នាក់ជាតិ | • របាយការណ៍ប្រចាំឆ្នាំសម្រាប់ចែកចាយជាទូទៅ |
| ព័ត៌មានត្រឡប់ | • មូលដ្ឋានសុខាភិបាលផ្ទាល់ខ្លួន និងមណ្ឌលសុខភាព<br>• គ្រួសារសព | • មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងសហគមន៍<br>• ក្រុមគ្រួសារសព | • ផ្តល់ព័ត៌មានត្រឡប់ដល់ថ្នាក់ខេត្ត មន្ទីរពេទ្យជាតិ និងថ្នាក់ជាតិ កម្មវិធីជាតិ និងនាយកដ្ឋាននានា ដែលពាក់ពន្ធ័ |

| | | | |
|---|---|---|---|
| សមាជិក<br>អចិន្ត្រៃយ៍ | • ប្រធានមន្ទីរពេទ្យ<br>• ប្រធានបច្ចេកទេសមន្ទីរពេទ្យ<br>• ប្រធានផ្នែកថែទាំ<br>• ប្រធានផ្នែកសម្ភព<br>• ប្រធានផ្នែកពោធនកម្ម ទារក ឬថែទាំទារក NICU/NCU<br>• ប្រធានផ្នែកសង្គ្រោះបន្ទាន់ (ICU)<br>• ប្រធានផ្នែកដាក់ថ្នាំសណ្តំ<br>• ក្រុមកោសល្យវិច័យនៅក្នុងមន្ទីរពេទ្យ<br>• បន្ថែមក្រុមគ្រូពេទ្យបច្ចេកទេស ៖ ឆ្មប ឯកទេសសម្ភព ឯកទេសទារក ឬកុមារ ក្រុមថែទាំ, គ្រូពេទ្យព្យាបាល បុគ្គលិកផ្នែកដាក់ថ្នាំសណ្តំ<br>• រដ្ឋបាលមន្ទីរពេទ្យ<br>• អ្នកគ្រប់គ្រងទិន្នន័យ ឬ អ្នកឯកទេសខាងព័ត៌មានសុខាភិបាល<br>• តំណាងមកពីក្រុមការងារកែលម្អគុណភាព (QI) របស់មន្ទីរពេទ្យខេត្ត<br>• តំណាងគណៈគ្រូពេទ្យ គណៈឆ្មប គណៈគិលានុបដ្ឋាកនៅតាមខេត្ត។ | • ប្រធាន ឬអនុប្រធាន មន្ទីរសុខាភិបាលខេត្ត (ប្រធាន)<br>• ប្រធាន ឬអនុប្រធានការិយាល័យការិយាល័យបង្ការ និងគ្រប់គ្រងជំងឺ (អនុប្រធាន)<br>• មន្ទីរសុខាភិបាលខេត្តមន្ត្រីទទួលបន្ទុកការកែលម្អគុណភាពសេវាសុខាភិបាល<br>• តំណាងក្រុមកោសល្យវិច័យផ្នែកសុខភាពមាតា និងទារកថ្នាក់ខេត្ត<br>• ប្រធានស្រុកប្រតិបត្តិ (គ្រប់ស្រុកប្រតិបត្តិទាំងអស់)<br>• ប្រធានផ្នែកគាំពារមាតា និងទារកស្រុកប្រតិបត្តិ (គ្រប់ស្រុកប្រតិបត្តិទាំងអស់)<br>• ប្រធានមន្ទីរពេទ្យខេត្ត ឬ ប្រធានមន្ទីរពេទ្យបង្អែកទាំងអស់<br>• ប្រធានផ្នែកថែទាំ នៃមន្ទីរពេទ្យខេត្ត ឬប្រធានផ្នែកថែទាំមន្ទីរពេទ្យបង្អែកទាំងអស់<br>• ប្រធានផ្នែកសម្ភព នៃមន្ទីរពេទ្យខេត្ត<br>• ប្រធានផ្នែកទារក ឯកទេសកុមារតូច (NCU/NICU) នៃមន្ទីរពេទ្យខេត្ត | • តំណាងមកពីកម្មវិធីជាតិសុខភាពបន្តពូជ<br>• តំណាងមកពីមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក<br>• តំណាងមកពីនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល<br>• តំណាងមកពីការិយាល័យធានាគុណភាព ក្រសួងសុខាភិបាល មួយរូប<br>• តំណាងមកពីគណៈកម្មាការជាតិកែលម្អគុណភាពសេវាសុខាភិបាល ឬនាយកដ្ឋានមន្ទីរពេទ្យ<br>• ការិយាល័យគិលានុបដ្ឋាក និងឆ្មបតំណាង ឬ នាយកដ្ឋានមន្ទីរពេទ្យ<br>• តំណាងមកពីមន្ទីរពេទ្យជាតិ<br>• លេខាធិការដ្ឋាន<br>• តំណាងក្រុមកោសល្យវិច័យ<br>• តំណាងសមាគមក្រុមឯកទេសសម្ភព និងរោគស្ត្រី<br>• តំណាងសមាគមន៍ក្រុមឯកទេសកុមារ ឬទារក<br>• តំណាងសមាគមអ្នកដាក់ថ្នាំសណ្តំ<br>• តំណាងមកពីសមាគមឆ្មប |

| | | | |
|---|---|---|---|
| | | • មន្ត្រីទទួលបន្ទុកប្រព័ន្ធព័ត៌មានសុខាភិបាល និងផែនការខេត្ត | |
| **សមាជិកមិនអចិន្ត្រៃយ៍** | • | • អាជ្ញាធរមូលដ្ឋាន និងអ្នកតំណាងសហគមន៍<br>• គ្រូពេទ្យជំនាញវិភាគវិទ្យា<br>• អ្នកជំនាញផ្សេងៗដែលពាក់ព័ន្ធ | • តំណាងមកពីសមាគមព្យាបាលគ្លីនីកឯកជន<br>• តំណាងមកពីគណៈវិជ្ជាជីវៈឆ្មប<br>• តំណាងមកពីគណវិជ្ជាជីវៈគិលានុបដ្ឋាក<br>• តំណាងមកពីគណវិជ្ជាជីវៈគ្រូពេទ្យ<br>• គ្រូពេទ្យជំនាញវិភាគវិទ្យា<br>• អ្នកជំនាញផ្សេងៗដែលពាក់ព័ន្ធ។ |

## ឧបសម្ព័ន្ធទី ២ ៖ លិខិតជូនដំណឹង និងបញ្ជាក់មូលហេតុមរណភាព

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(ឈ្មោះមូលដ្ឋានសុខាភិបាល)

លេខចេញ៖

# លិខិតជូនដំណឹងពីមរណភាព

លេខសម្គាល់៖…………

**ប្រភេទមូលដ្ឋានសុខាភិបាល៖**

**ប្រភេទទីកន្លែងមរណភាព៖**
☐ នៅមូលដ្ឋានសុខាភិបាល ☐ នៅផ្ទះ
☐ ផ្សេងៗ សូមបញ្ជាក់…………………

**លេខកូដមូលដ្ឋានសុខាភិបាល៖** ☐☐☐☐☐☐

**ឈ្មោះមរណជន *៖**
នាមត្រកូល ………………………………….
នាមខ្លួន……………………………………..
*ប្រសិនបើអ្នកស្លាប់ទើបនឹងកើត ដោយគ្មានឈ្មោះ ចូរសរសេរ "កូនរបស់ <ឈ្មោះម្ដាយ>"

**ថ្ងៃខែឆ្នាំមរណភាព៖** D D M M Y Y Y Y

**ម៉ោងទទួលមរណភាព(២៤ ម៉ោង)៖** H H : M M

**ថ្ងៃខែឆ្នាំកំណើត៖** D D M M Y Y Y Y

**អាយុ បើមិនមានថ្ងៃខែឆ្នាំកំណើត៖** ☐ ☐ ☐
ឬតិចជាង 24 ម៉ោង៖ ☐ ☐ **ម៉ោង** ☐ ☐ **នាទី**

**ភេទមរណជន៖**
☐ ប្រុស
☐ ស្រី

**ប្រភេទនៃមរណភាព៖**
☐ ស្លាប់ករណីធម្មតា
☐ ស្លាប់ករណីមិនធម្មតា

**ទីកន្លែងមរណភាព(មូលដ្ឋានសុខាភិបាល ឬផ្ទះ ឬ កន្លែងផ្សេងៗ)៖**
ឃុំ/សង្កាត់៖ ……………… ក្រុង/ស្រុក/ខណ្ឌ៖ ………………រាជធានី-ខេត្ត៖………………

**ទីលំនៅបច្ចុប្បន្នរបស់មរណជន(ឬទីលំនៅឋានរបស់ម្ដាយបើមរណជនជាទារក)៖**
ឃុំ/សង្កាត់៖ ………………ក្រុង/ស្រុក/ខណ្ឌ៖ ………………
រាជធានី-ខេត្ត៖ ………………

☐ សង្ស័យមរណភាពមាតា

លេខទូរសព្ទ ញាតិមរណជន ឬ អ្នករាយការណ៍ ៖
………………

# លិខិតវេជ្ជសាស្ត្របញ្ជាក់មូលហេតុមរណភាព

*ទម្រង់ ក៖* ទិន្នន័យវេជ្ជសាស្ត្រ៖ ផ្នែកទី១ និង ផ្នែកទី២

| ១. រាយការណ៍អំពីជំងឺ ឬលក្ខខណ្ឌ ដែលបណ្ដាលអោយស្លាប់ដោយផ្ទាល់នៅក្នុងជួរ (ក) រាយការណ៍អំពីខ្សែសង្វាក់នៃហេតុការណ៍តាមលំដាប់លំដោយ (បើមាន) បញ្ជាក់អំពីមូលហេតុបន្ទាប់បន្សំនៃការស្លាប់នៅជួរក្រោមគេបង្អស់។ | | **មូលហេតុនៃការស្លាប់** | **ចន្លោះពេល** (ចាប់ពីពេលចាប់ផ្ដើមរហូតដល់ពេលស្លាប់) |
|---|---|---|---|
| | ក | | |
| | ខ | ដោយសារ៖ | |
| | គ | ដោយសារ៖ | |
| | ឃ | ដោយសារ៖ | |

| ២.លក្ខខណ្ឌសំខាន់ៗផ្សេងទៀតដែលរួមចំណែកដល់ការស្លាប់ (ចន្លោះពេល អាចត្រូវបានរួមបញ្ចូលនៅក្នុងរង្វង់ក្រចក នៅពីក្រោយលក្ខខណ្ឌនីមួយៗ) | |
|---|---|

*ទម្រង់ ខ៖* ទិន្នន័យវេជ្ជសាស្ត្រដទៃទៀត

| | |
|---|---|
| តើមានការវះកាត់ក្នុងរយៈពេល ១៤ សប្ដាហ៍ចុងក្រោយដែរឬទេ? | ☐ មាន ☐ គ្មាន ☐ មិនដឹង |
| ប្រសិនបើមាន សូមបញ្ជាក់កាលបរិច្ឆេទនៃការវះកាត់ | D D M M Y Y Y Y |

| | | | |
|---|---|---|---|
| ប្រសិនបើមាន សូមបញ្ជាក់មូលហេតុ នៃការវះកាត់ (មរណភាព ឬលក្ខខណ្ឌ) | | | |
| តើមានការស្នើសុំធ្វើកោសល្យវិច្ច័យ? | ☐ មាន ☐ គ្មាន ☐ មិនដឹង | | |
| ប្រសិនបើមាន តើរបកគំហើញនានាត្រូវបានប្រើប្រាស់នៅក្នុងលិខិតបញ្ជាក់នេះដែរឬទេ? | ☐ បាទ/ចាស ☐ ទេ ☐ មិនដឹង | | |
| **ប្រភេទនៃការស្លាប់៖** | | | |
| ☐ ជំងឺ | ☐ ការបំពានផ្លូវកាយ | ☐ មិនអាចកំណត់បាន | |
| ☐ ឧបទ្ទវហេតុ | ☐ អន្តរាគមន៍តាមផ្លូវច្បាប់ | ☐ រង់ចាំការស៊ើបអង្កេត | |
| ☐ ការធ្វើបាបខ្លួនឯងដោយចេតនា/អត្តឃាដ | ☐ សង្គ្រាម | ☐ មិនដឹង | |
| ប្រសិនបើមានមូលហេតុខាងក្រៅ ឬជាតិពុល៖ ☐ មូលហេតុខាងក្រៅ ☐ ការពុល | កាលបរិច្ឆេទគ្រោះថ្នាក់ | D D M M Y Y Y Y | |
| សូមពណ៌នាថាតើមូលហេតុខាងក្រៅកើតឡើងដោយរបៀបណា (ប្រសិនបើការពុល សូមបញ្ជាក់អំពីសារជាតុពុល) | | | |
| **ទីកន្លែងកើតមូលហេតុខាងក្រៅ៖** | | | |
| ☐ នៅផ្ទះ | ☐ ទីលំនៅ ជាវិទ្យាស្ថាន ឬអគារ | ☐ សាលារៀន ស្ថាប័នដទៃទៀត តំបន់រដ្ឋបាលសាធារណៈ | ☐ កីឡាដ្ឋាន |
| ☐ ផ្លូវ និងផ្លូវជាតិ | ☐ តំបន់ពាណិជ្ជកម្ម និងសេវាកម្ម | ☐ តំបន់ឧស្សាហកម្ម និងតំបន់សាងសង់ | ☐ កសិដ្ឋាន |
| ☐ កន្លែងដទៃទៀត (សូមបញ្ជាក់)៖ | | | ☐ មិនដឹង |
| **ទារកស្លាប់កើត ☐ ទារកកើតស្លាប់ ☐ ៖** | | | |
| មានទារកច្រើនក្នុងផ្ទៃ ☐ មាន ☐ គ្មាន ☐ មិនដឹង | ទារកកើតស្លាប់ ☐ មាន ☐ គ្មាន ☐ មិនដឹង | | |
| បើស្លាប់ក្នុងរយៈពេល ២៤ម៉ោង សូមបញ្ជាក់រយពេលដែលបានរស់៖….. | ទម្ងន់ទារក (គិតជាក្រាម)៖………….. | ភេទមរណជន៖ ☐ប្រុស ☐ស្រី ☐មិនដឹង | |
| អាយុគ័ភ៌គិតជាសប្តាហ៍ | | ថ្ងៃខែឆ្នាំកំណើតម្តាយ៖………………………… | ឬ អាយុ (គិតជាឆ្នាំពេញ) ………… |
| ចំនួនទារកកើតរស់ (មកដល់បច្ចុប្បន្ន) | | ចំនួនទារកស្លាប់កើត (មកដល់បច្ចុប្បន្ន) | |
| ប្រសិនបើស្លាប់ជុំវិញកំណើត សូមបញ្ជាក់ស្ថានភាពរបស់ម្តាយ ដែលធ្វើអោយប៉ះពាល់ដល់ទារកក្នុងផ្ទៃ និងទារកទើបនឹងកើត | | | |
| ចំពោះស្ត្រី មរណជន តើមានផ្ទៃពោះដែរឬទេ? ☐ មាន ☐ គ្មាន ☐ មិនដឹង | ☐ នៅពេលស្លាប់ ☐ <៤២ថ្ងៃមុនពេលស្លាប់ ☐ ៤៣ថ្ងៃ-១ឆ្នាំមុនពេលស្លាប់ ☐ មិនដឹង | | |
| តើការមានផ្ទៃពោះរួមចំណែកដល់មូលហេតុនៃការស្លាប់ដែរឬទេ? ☐ បាទ/ចាស ☐ ទេ ☐ មិនដឹង | | | |

ថ្ងៃ...........................ខែ .............ឆ្នាំ .......... ព.ស. ២៥៦..

....................., ថ្ងៃទី..........ខែ.............. ឆ្នាំ ២០............

ហត្ថលេខា និងឈ្មោះគ្រូពេទ្យ

**បានឃើញ និងអនុម័ត**

ប្រធាន

ទម្រង់ពិនិត្យឡើងវិញលើមរណភាពទារក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

(ឈ្មោះមូលដ្ឋានសុខាភិបាល)

លេខចេញ៖

# ទារកស្លាប់កើត

លេខសម្គាល់៖…………

| ប្រភេទមូលដ្ឋានសុខាភិបាល៖ | ប្រភេទទីកន្លែងមរណភាព៖ ☐ នៅមូលដ្ឋានសុខាភិបាល ☐ នៅផ្ទះ | លេខកូដមូលដ្ឋានសុខាភិបាល៖ ☐☐☐☐☐☐ |
|---|---|---|

| ថ្ងៃខែឆ្នាំសម្រាលកូនរស់លើកមុន៖ | ថ្ងៃខែឆ្នាំសម្រាលទារកស្លាប់កើត៖ | ប្រភេទអ្នកផ្តល់សេវាសម្រាលកូន៖ | ប្រភេទកំណើតទារក |
|---|---|---|---|
| D D M M Y Y Y Y | D D M M Y Y Y Y | ☐ វេជ្ជបណ្ឌិតវះកាត់ ☐ វេជ្ជបណ្ឌិត ☐ ឆ្មប ☐ ផ្សេងៗ | ☐ កូនទោល ☐ភ្លោះពីរ ☐ ភ្លោះបី ☐ ភ្លោះបួន ☐ ផ្សេងៗ |

| ទីកន្លែងកើត( មូលដ្ឋានសុខាភិបាល ឬកន្លែងផ្សេងៗ )៖ | ទីលំនៅបច្ចុប្បន្នរបស់ម្តាយ៖ |
|---|---|
| ឃុំ/សង្កាត់៖ ……………… ក្រុង/ស្រុក/ខណ្ឌ៖ ………………រាជធានី-ខេត្ត៖……………… | ឃុំ/សង្កាត់៖ ………………ក្រុង/ស្រុក/ខណ្ឌ៖ ……………… រាជធានី-ខេត្ត៖ ……………… |

## លិខិតវេជ្ជសាស្ត្របញ្ជាក់មូលហេតុមរណភាព

*ទម្រង់ ក៖* ទិន្នន័យវេជ្ជសាស្ត្រ៖ ផ្នែកទី១ និង ផ្នែកទី២

| | | | មូលហេតុនៃការស្លាប់ | ចន្លោះពេល (ចាប់ពីពេលចាប់ផ្តើមរហូតដល់ពេលស្លាប់) |
|---|---|---|---|---|
| ១. រាយការណ៍អំពីជំងឺ ឬលក្ខខណ្ឌ ដែលបណ្តាលអោយស្លាប់ដោយផ្ទាល់នៅក្នុងជួរ (ក) រាយការណ៍អំពីខ្សែសង្វាក់នៃហេតុការណ៍តាមលំដាប់លំដោយ (បើមាន) បញ្ជាក់អំពីមូលហេតុបន្ទាប់បន្សំនៃការស្លាប់នៅជួរក្រោមគេបង្អស់។ | | ក | | |
| | | ខ | | |
| | | គ | | |
| | | ឃ | | |
| ២.លក្ខខណ្ឌសំខាន់ៗផ្សេងទៀតដែលរួមចំណែកដល់ការស្លាប់ (ចន្លោះពេល អាចត្រូវបានរួមបញ្ចូលនៅក្នុងរង្វង់ក្រចក នៅពីក្រោយលក្ខខណ្ឌនីមួយៗ) | | | | |

*ទម្រង់ ខ៖* ទិន្នន័យវេជ្ជសាស្ត្រដទៃទៀត

| | |
|---|---|
| តើមានការវះកាត់ក្នុងរយៈពេល ១៤ សប្តាហ៍ចុងក្រោយដែរឬទេ? | ☐ មាន ☐ គ្មាន ☐ មិនដឹង |
| ប្រសិនបើមាន សូមបញ្ជាក់កាលបរិច្ឆេទនៃការវះកាត់ | D D M M Y Y Y Y |
| ប្រសិនបើមាន សូមបញ្ជាក់មូលហេតុនៃការវះកាត់ (មរណភាព ឬលក្ខខណ្ឌ) | |
| តើមានការស្នើសុំធ្វើកោសល្យវិច្ច័យ? | ☐ មាន ☐ គ្មាន ☐ មិនដឹង |
| ប្រសិនបើមាន តើរបកគំហើញនានាត្រូវបានប្រើប្រាស់នៅក្នុងលិខិតបញ្ជាក់នេះដែរឬទេ? | ☐ បាទ/ចាស ☐ ទេ ☐ មិនដឹង |

**ប្រភេទ នៃការស្លាប់៖**

| | | |
|---|---|---|
| ☐ ជំងឺ | ☐ ការបំពានផ្លូវកាយ | ☐ មិនអាចកំណត់បាន |
| ☐ ឧបទ្ទវហេតុ | ☐ អន្តរាគមន៍តាមផ្លូវច្បាប់ | ☐ រង់ចាំការស៊ើបអង្កេត |
| ☐ ការធ្វើបាបខ្លួនឯងដោយចេតនា/អត្ត | ☐ សង្គ្រាម | ☐ មិនដឹង |

| | | | |
|---|---|---|---|
| ឃាដ | | | |
| ប្រសិនបើមានមូលហេតុខាងក្រៅ ឬជាតិពុល៖ ☐ មូលហេតុខាងក្រៅ ☐ ការពុល | កាលបរិច្ឆេទគ្រោះថ្នាក់ | D D M M Y Y Y Y | |
| សូមពណ៌នាថាតើមូលហេតុខាងក្រៅកើតឡើងដោយរបៀបណា (ប្រសិនបើការពុល សូមបញ្ជាក់អំពីសារធាតុពុល) | | | |
| **ទីកន្លែងកើតមូលហេតុខាងក្រៅ៖** | | | |
| ☐ នៅផ្ទះ | ☐ ទីលំនៅ ជាវិទ្យាស្ថាន ឬអគារ | ☐ សាលារៀន ស្ថាប័នដទៃទៀត តំបន់រដ្ឋបាលសាធារណៈ | ☐ កីឡាដ្ឋាន |
| ☐ ផ្លូវ និងផ្លូវជាតិ | ☐ តំបន់ពាណិជ្ជកម្ម និងសេវាកម្ម | ☐ តំបន់ឧស្សាហកម្ម និងតំបន់សាងសង់ | ☐ កសិដ្ឋាន |
| ☐ កន្លែងដទៃទៀត (សូមបញ្ជាក់)៖ | | | ☐ មិនដឹង |
| **ទារកស្លាប់កើត ☐ ទារកកើតស្លាប់ ☐ ៖** | | | |
| មានទារកច្រើនក្នុងផ្ទៃ ☐ មាន ☐ គ្មាន ☐ មិនដឹង | ទារកកើតស្លាប់ ☐ មាន ☐ គ្មាន ☐ មិនដឹង | | |
| បើស្លាប់ក្នុងរយៈពេល ២៤ម៉ោង សូមបញ្ជាក់រយពេលដែលបានរស់៖….. | ទម្ងន់ទារក (គិតជាក្រាម)៖………….. | ភេទមរណជន៖ ☐ប្រុស ☐ ស្រី ☐មិនដឹង | |
| អាយុគភ៌គិតជាសប្តាហ៍ | | ថ្ងៃខែឆ្នាំកំណើតម្តាយ៖…………………………… | ឬ អាយុ (គិតជាឆ្នាំពេញ) ………… |
| ចំនួនទារកកើតរស់ (មកដល់បច្ចុប្បន្ន) | | ចំនួនទារកស្លាប់កើត (មកដល់បច្ចុប្បន្ន) | |
| ប្រសិនបើស្លាប់ជុំវិញកំណើត សូមបញ្ជាក់ស្ថានភាពរបស់ម្តាយ ដែលធ្វើអោយប៉ះពាល់ដល់ទារកក្នុងផ្ទៃ និងទារកទើបនឹងកើត | | | |
| ចំពោះស្ត្រី មរណជន តើមានផ្ទៃពោះដែរឬទេ? ☐ មាន ☐ គ្មាន ☐ មិនដឹង | ☐ នៅពេលស្លាប់ ☐ <៤២ថ្ងៃមុនពេលស្លាប់ ☐ ៤៣ថ្ងៃ-១ឆ្នាំមុនពេលស្លាប់ ☐ មិនដឹង | | |
| តើការមានផ្ទៃពោះរួមចំណែកដល់មូលហេតុនៃការស្លាប់ដែរឬទេ? ☐ បាទ/ចាស ☐ ទេ ☐ មិនដឹង | | | |

ថ្ងៃ...........................ខែ ............ឆ្នាំ .......... ព.ស. ២៥៦..

...................., ថ្ងៃទី.........ខែ............. ឆ្នាំ ២០............

ហត្ថលេខា និងឈ្មោះគ្រូពេទ្យ

**បានឃើញ និងអនុម័ត**

ប្រធាន

## ឧបសម្ព័ន្ធទី ៣ ៖ ទម្រង់ពិនិត្យករណីមរណភាពមាតា

ទម្រង់បំពេញដោយ ៖ ____________________ មុខតំណែង ៖ ____________________ ថ្ងៃខែឆ្នាំ ៖ ________________

| សេចក្តីសង្ខេបខ្លីអំពីករណី ៖ |
|---|
| |

| ផ្នែកទី ១ ៖ ការកំណត់អត្តសញ្ញាណ | | | | |
|---|---|---|---|---|
| 1.1 ឈ្មោះពេញរបស់ម្តាយ (លេខកូដរបស់មូលដ្ឋាន) | | | | |
| 1.2 អាសយដ្ឋានរបស់ម្តាយ (បច្ចុប្បន្ន) | | | | |
| 1.3 ឈ្មោះមូលដ្ឋានសុខាភិបាល | | | | |
| 1.4 ស្រុក និងខេត្ត នៃមូលដ្ឋានសុខាភិបាល | ឃុំ/ខណ្ឌ៖ | ស្រុក៖ | ខេត្ត៖ | |
| 1.5 កម្រិតមូលដ្ឋានសុខាភិបាល | | | | |
| 1.6 បានបញ្ជូន | មិនបានបញ្ជូន | បញ្ជូនចូលមកពី៖ | | |
| | | បញ្ជូនចេញពី៖ | | |
| 1.7 ប្រភពព័ត៌មាន | | | | |
| 1.7.1 ឯកសារអ្នកជំងឺក្នុងមូលដ្ឋានសុខាភិបាល | ទេ | បាទ/ចាស៎ | | |
| 1.7.2 ការសម្ភាសបុគ្គលិកមូលដ្ឋានសុខាភិបាល | ទេ | បាទ/ចាស៎ | | |
| 1.7.3 ការសម្ភាសគ្រួសារអ្នកជំងឺ/អ្នកដឹងរឿង | ទេ | បាទ/ចាស៎ | | |
| **ផ្នែកទី ២ ៖ ព័ត៌មានសាចតារ** | | | | |
| 2.1 ប្រវត្តិសម្ភព | មានគភ៌សរុប (Gravidity): | ចំនួនកូនសរុប (Parity): | | |
| | កំណើតរស់ (Live births): | ស្លាប់កើត (Stillbirths): | រលូតដោយឯកឯង៖ | រំលូត៖ |
| 2.1a សម្រាលដោយវះកាត់ពីមុន | គ្មាន | ប្រសិនមានចំនួន If yes, number: | ថ្ងៃខែឆ្នាំសម្រាលដោយវះកាត់ចុងក្រោយបំផុត៖ | |
| 2.1b ផលវិបាក នៃការមានផ្ទៃពោះពីមុន | គ្មាន | បើមាន ចូរពណ៌នា៖ | | |
| 2.2 អាយុម្តាយ | | | | |
| 2.3 កម្រិតអប់រំរបស់ម្តាយ | មិនបានរៀន | កំរិតវប្បធម៌៖ | | |
| 2.4 មុខរបររបស់ម្តាយ | | | | |

| | | | | |
|---|---|---|---|---|
| 2.5 ស្ថានភាពអាពាហ៍ពិពាហ៍ | នៅលីវ | រៀបការ | មេម៉ាយ | |
| | លែងលះ | បែកគ្នា | រស់នៅជាមួយគ្នា | |
| 2.6 ការប្រើមធ្យោបាយពន្យារកំណើតមុនពេលមានផ្ទៃពោះ | ទេ | បាទ/ចាស់ | បើបាទ/ចាស់ តើមធ្យោបាយអ្វី | |
| 2.7 ចម្ងាយពីផ្ទះទៅមូលដ្ឋានសុខាភិបាល | មូលដ្ឋានសុខាភិបាល | | Km:<br>រយៈពេល | មធ្យោបាយធ្វើដំណើរៈ |
| 2.8 ចម្ងាយពីការបញ្ជូនពីមូលដ្ឋានសុខាភិបាលទៅមូលដ្ឋានសុខាភិបាលផ្សេងៗ | មូលដ្ឋានសុខាភិបាលបញ្ជូន | មូលដ្ឋានសុខាភិបាលទទួល | Km:<br>រយៈពេល | មធ្យោបាយធ្វើដំណើរ |
| | | | | |
| **ផ្នែកទី ៣ ៖ ព័ត៌មានលម្អិតអំពីមរណភាព** | | | | |
| 3.1 ថ្ងៃខែឆ្នាំ នៃមរណភាព | | ពេលវេលា នៃការស្លាប់ | | |
| 3.2 ស្លាប់ក្នុងអំឡុងពេល | មានផ្ទៃពោះ | ឈឺពោះសម្រាល/សម្រាល | ក្រោយពេលសម្រាល | រំលូត |
| | មិនដឹង | | | |
| 3.2.1 អាយុគភ៌ពេលស្លាប់ | ត្រីមាសទីមួយ | ត្រីមាសទីពីរ | ត្រីមាសទីបី | មិនដឹង |
| 3.3 ទីកន្លែងមរណភាព | មូលដ្ឋានសុខាភិបាល ( CPA1,CPA2, Private,etc ) | នៅផ្ទះ | តាមផ្លូវ | ផ្សេងទៀត សូមបញ្ជាក់ |
| | មិនដឹង | | | |
| | បើនៅមូលដ្ឋានសុខាភិបាល សូមបញ្ជាក់ៈ | | | |
| 3.4 បើការស្លាប់កើតឡើងក្នុងមូលដ្ឋានសុខាភិបាល តើនៅក្នុងអំឡុង ២៤ ម៉ោង នៃការចូលពេទ្យឬទេ ? | ទេ ( លើសពី ២៤ ម៉ោង ) | បាទ/ចាស់ ( ក្នុងអំឡុង ២៤ម៉ោង ) | | |
| 3.5 មូលហេតុឬសគល់ នៃការស្លាប់ ( ICD 11 ): | ______________ _ | | | |
| | ក្រុមទី 1 | ក្រុមទី 2 | ក្រុមទី 3 | ក្រុមទី 4 |
| | ក្រុមទី 5 | ក្រុមទី 6 | ក្រុមទី 7 | ក្រុមទី 8 |
| | ក្រុមទី 9 | | | |
| 3.6 មូលហេតុបន្ទាប់បន្សំនៃការស្លាប់ ( ICD11 code ): | ______________ _ | មិនបានកំណត់ | | |
| 3.7 កោសល្យវិច័យ | មិនបានធ្វើ | បានបញ្ចប់ | | |
| **ផ្នែកទី ៤ ៖ ការមានផ្ទៃពោះ និងការថែទាំមុនពេលសម្រាល** | | | | |
| 4.1 ប្រភេទ នៃគភ៌ | កូនមួយ | កូនច្រើន= | មិនដឹង | |
| 4.2 ការថែទាំផ្ទៃពោះមុនពេលសម្រាល | | | | |
| 4.2a ចំនួនដងនៃការមកពិនិត្យ | __________ | មិនដឹង | | |
| 4.2b អាយុគភ៌ពេលមកពិនិត្យដំបូង | __________ | មិនដឹង | | |
| 4.3 កត្តាហានិភ័យមុនពេលសម្រាល | | | | |
| 4.1a លើសសម្ពាធឈាម | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.2b ប្រូតេអ៊ីនក្នុងទឹកនោម | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.3c ជាតិស្ករក្នុងទឹកនោម | ទេ | បាទ/ចាស់ | មិនដឹង | |

| | | | | |
|---|---|---|---|---|
| 4.4d ស្លេកស្លាំង | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.5e ការបង្ករោគក្នុងផ្លូវនោម | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.6f សុកពាំងមាត់ស្បូន | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.7g គ្រុនចាញ់ | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.8h ផ្សេងទៀត ______________________ | | | | |
| 4.4 តេស្តមន្ទីរពិសោធន៍ដែលបានអនុវត្ត | | | | |
| 4.4a ប្រភេទឈាម និង Rh | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.4b អេម៉ូក្លូប៊ីន | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.4c ស្វាយ | ទេ | បាទ/ចាស់ | មិនដឹង | |
| មេរោគថ្លើម | | | | |
| ជាតិស្ករក្នុងឈាម | | | | |
| 4.4d ស្លួច | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.4e ការវិភាគទឹកនោម | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.4f ផ្សេងទៀត | ទេ | បាទ/ចាស់ | មិនដឹង | |
| 4.5 ចាក់ថ្នាំបង្ការតេតាណូស | ចំនួនដង | | | |
| 4.6 ស្ថានភាពមេរោគអេដស៍ | មេរោគអេដស៍-អវិជ្ជមាន | មេរោគអេដស៍-វិជ្ជមាន | មិនបានធ្វើ | មិនដឹង |
| 4.6.1 វិធានការ មេរោគអេដស៍-វិជ្ជមាន | | HAART | ផ្សេងទៀត សូមបញ្ជាក់៖ | |
| 4.7 ស្ថានភាពរបេង | Tb-អវិជ្ជមាន | Tb-វិជ្ជមាន | ការព្យាបាល៖ | |
| **ផ្នែកទី ៥ ៖ ប្រវត្តិ នៃជំងឺបច្ចុប្បន្ន និងមាត់មុនពេលចូលសម្រាកពេទ្យ** | | | | |
| 5.1 រោគសញ្ញា | | | | |
| 5.1a គ្រុនក្តៅ | ទេ | បាទ/ចាស់ | មិនដឹង | បើបាទ/ចាស់, ចាប់ផ្តើម៖ |
| 5.1b លើសសម្ពាធឈាម | ទេ | បាទ/ចាស់ | មិនដឹង | បើបាទ/ចាស់, ចាប់ផ្តើម៖ |
| 5.1c ក្រឡាភ្លើង/ប្រកាច់ | ទេ | បាទ/ចាស់ | មិនដឹង | បើបាទ/ចាស់, ចាប់ផ្តើម៖ |
| 5.1d ហើម | ទេ | បាទ/ចាស់ | មិនដឹង | បើបាទ/ចាស់, ចាប់ផ្តើម៖ |
| 5.1e ស្រវាំងភ្នែក | ទេ | បាទ/ចាស់ | មិនដឹង | បើបាទ/ចាស់, ចាប់ផ្តើម៖ |
| 5.1f ហូរឈាម | ទេ | បាទ/ចាស់ | មិនដឹង | បើបាទ/ចាស់, ចាប់ផ្តើម៖ |
| 5.2 ពណ៌នាបែបគុណវិស័យ នៃដំណើរការជំងឺ (នៅពេលរោគសញ្ញាបានចាប់ផ្តើម តើគាត់/គ្រួសារបានធ្វើអ្វីខ្លះចំពោះបញ្ហានេះ) | | | | |
| 5.3 អ្នកជំងឺមកដោយខ្លួនឯង ដោយមិនមានការបញ្ជូន | ទេ | បាទ/ចាស់ | | |
| បានបញ្ជូន | ទេ | បាទ/ចាស់ | | |
| ហេតុផលសម្រាប់ការបញ្ជូន៖ | | | | |
| 5.3 រថយន្តគិលានសង្គ្រោះត្រូវបានប្រើ | ទេ | បាទ/ចាស់ | | |

| | | | | |
|---|---|---|---|---|
| បើបាទ/ចាស់ តើមានឱសថ និងបុគ្គលិកសុខាភិបាលនៅលើរថយន្តនោះ ឬទេ? | ទេ | បាទ/ចាស់ | | |
| 5.4 បុគ្គលអមដំណើរមកជាមួយ? | ទេ | បាទ/ចាស់ | ប្រសិនបើបាទ/ចាស់ សូមបញ្ជាក់ | |
| 5.5 កាលបរិច្ឆេទ និងពេលវេលា នៃការចាប់ផ្តើមរោគសញ្ញា | | | | |
| 5.6 កាលបរិច្ឆេទ និងពេលវេលា នៃការសម្រេចចិត្តបញ្ជូន/ជម្លៀសៈ | | | | |
| 5.7 កាលបរិច្ឆេទ និងពេលវេលា នៃការចេញដំណើរពីកន្លែងបញ្ជូនៈ | | | | |
| 5.8 កាលបរិច្ឆេទ និងពេលវេលា នៃការមកដល់មូលដ្ឋានសុខាភិបាលដែលត្រូវបានបញ្ជូនមកៈ | | | | |
| **ផ្នែកទី ៦ ៖ ការចូលសម្រាកពេទ្យរបស់ស្ត្រី** | | | | |
| 6.1 សញ្ញាជីវិត | | | | |
| 6.1a ចង្វាក់បេះដូង/ជីពចរ | ទេ | បាទ/ចាស់ | មិនដឹង | បញ្ជាក់ៈ |
| 6.1b សម្ពាធឈាមស៊ីស្តូលិក | ទេ | បាទ/ចាស់ | មិនដឹង | បញ្ជាក់ៈ |
| 6.1c សម្ពាធឈាមដ្យាស្តូលិក | ទេ | បាទ/ចាស់ | មិនដឹង | បញ្ជាក់ៈ |
| 6.1d សីតុណ្ហភាព | ទេ | បាទ/ចាស់ | មិនដឹង | បញ្ជាក់ៈ |
| 6.1e ចង្វាក់ដង្ហើម | ទេ | បាទ/ចាស់ | មិនដឹង | បញ្ជាក់ៈ |
| 6.1f កម្ពស់ | ទេ | បាទ/ចាស់ | មិនដឹង | បញ្ជាក់ៈ |
| 6.1g ទម្ងន់ | ទេ | បាទ/ចាស់ | មិនដឹង | បញ្ជាក់ៈ |
| 6.1h ផ្សេងទៀត | ទេ | បាទ/ចាស់ | មិនដឹង | បញ្ជាក់ៈ |
| កំរិតអុកស៊ីសែនក្នុងឈាម | ទេ | បាទ/ចាស់ | មិនដឹង | បញ្ជាក់ៈ |
| 6.2 ការពិនិត្យពោះ | | | | |
| 6.2a កម្ពស់ស្បូន | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.2b ចង្វាក់បេះដូងទារកពេលចូលមក | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.2c ទម្រង់រូបរាងទារក | ធម្មតា | ខុសធម្មតា | | |
| 6.2d ផ្សេងទៀត | ...................... | | | |
| 6.3 ការពិនិត្យអាងត្រគាក | | | | |
| 6.3a ដំណាក់កាលឈឺពោះសម្រាល | មិនក្នុងពេលឈឺពោះ | ទីមួយ | ទីពីរ | ទីបី |
| 6.3b ភាពខុសធម្មតា នៃអាងត្រគាក | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4 ផលវិបាកពេលចូលមក | | | | |
| 6.4a បែកទឹកភ្លោះមុនឈឺពោះសម្រាល | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4b បម្រុងក្រឡាភ្លើង | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4c ក្រឡាភ្លើង | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4d របើកសុកពីស្បូន | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4e សុកពាំងមាត់ស្បូន | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4f ឈឺពោះសម្រាលមុនពេលកំណត់ | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4g រលូត | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4h រលាកតម្រងនោម | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4i ការឃាយីបង្ករមេរោគក្នុងឈាម( sepsis ) | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4j គ្រុនចាញ់ | ទេ | បាទ/ចាស់ | មិនដឹង | |

| | | | | |
|---|---|---|---|---|
| 6.4k ទាក់ទងនឹងការរំលូតកូន | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4l គភ៌ក្រៅស្បូន | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4m គភ៌កូនពង | ទេ | បាទ/ចាស់ | មិនដឹង | |
| 6.4n ផ្សេងទៀត | ទេ | បាទ/ចាស់ | មិនដឹង | |
| **ផ្នែកទី ៧ ៖ ការឈឺពោះសម្រាល និងការសម្រាល (ឬការរំលូត)** | | | | |
| 7.1 រដូវចុងក្រោយរបស់ម្តាយ | ថ្ងៃ | ខែ | ឆ្នាំ | មិនដឹង |
| 7.2 ថ្ងៃខែឆ្នាំសម្រាល (ឬរំលូត) | ថ្ងៃ | ខែ | ឆ្នាំ | |
| 7.2.1 ពេលវេលា នៃការសម្រាល (ឬរំលូត) | | | | |
| 7.3 អាយុគភ៌ | | មិនដឹង | | |
| 7.3.1 វិធីសាស្ត្រ នៃការកំណត់ | ច្បាស់ពីថ្ងៃមករដូវចុងក្រោយ | មិនច្បាស់ពីថ្ងៃមករដូវចុងក្រោយ | អេកូពីដំបូង | អេកូក្រោយមកទៀត |
| 7.4 ទីកន្លែងសម្រាល (ឬរំលូត) | មូលដ្ឋានសុខាភិបាល | ផ្ទះ | តាមផ្លូវ | ផ្សេងទៀត, សូមបញ្ជាក់ |
| | មិនដឹង | | | |
| | ប្រសិនបើនៅមូលដ្ឋានសុខាភិបាល សូមបញ្ជាក់៖ | | | |
| 7.4.1 បុគ្គលិកធ្វើការសម្រាល (ឬអ្នកផ្តល់សេវារំលូត) | ឆ្មប | គិលានុបដ្ឋាក | វេជ្ជបណ្ឌិត | ផ្សេងទៀត៖ |
| | គ្មាននរណាទេ | មិនដឹង | | |
| 7.5 ចាប់ផ្តើមឈឺពោះសម្រាល | ដោយឯកឯង | ដោយចេតនា | វះកាត់យកកូន ឬវះកាត់មុនឈឺពោះសម្រាល | មិនដឹង |
| 7.6 ចង្វាក់បេះដូងទារក | ទេ | បាទ/ចាស់ | មិនដឹង | |
| 7.7 បានប្រើប៉ាតូក្រាហ្វ | ទេ | បាទ/ចាស់ | មិនដឹង | |
| 7.8 ផលវិបាកនៃការឈឺពោះ និងការសម្រាល | | | | |
| 7.8a ធ្លាក់ឈាមជុំវិញការសម្រាល | ទេ | បាទ/ចាស់ | មិនដឹង | |
| 7.8b ការបង្ករោគជុំវិញការសម្រាល | ទេ | បាទ/ចាស់ | មិនដឹង | |
| 7.8c បម្រុងក្រឡាភ្លើង ឬក្រឡាភ្លើងជុំវិញពេលសម្រាល | ទេ | បាទ/ចាស់ | មិនដឹង | |
| 7.8d ការឈឺពោះសម្រាលមិនរួច | ទេ | បាទ/ចាស់ | មិនដឹង | |
| 7.9 វិធីនៃការសម្រាល | CVD | សម្រាលជើងគូទមកមុន | ការសម្រាលដោយមានជំនួយ (បូម/តង្កៀបទាញ) | សម្រាលដោយការវះកាត់ |
| | ផ្សេងទៀត៖ | មិនដឹង | | |
| ក្នុងករណីសម្រាលដោយមានជំនួយ ពេលវេលារវាងការសម្រេចចិត្ត និងការសម្រាល | _________នាទី | មិនដឹង | n/a | |
| ក្នុងករណីសម្រាលដោយវះកាត់ពេលវេលារវាងការសម្រេចចិត្ត និងការសម្រាល | _________នាទី | មិនដឹង | n/a | |
| 7.10 ការគ្រប់គ្រងសកម្មដំណាក់កាលទីបី? (prophylactic oxytocin អុកស៊ីតូស៊ីនបង្ការ) | ទេ | បាទ/ចាស់ | មិនដឹង | |
| 7.11 សល់កំទេចសុក | ទេ | បាទ/ចាស់ | មិនដឹង | |
| 7.12 ការធ្លាក់ឈាមក្រោយសម្រាល | ទេ | បាទ/ចាស់ | មិនដឹង | |

| | | | | |
|---|---|---|---|---|
| 7.13 ការបង្ករោគក្រោយពេលសម្រាល | ទេ | បាទ/ចាស់ | មិនដឹង | |
| 7.14 បម្រុងក្រឡាភ្លើង/ក្រឡាភ្លើងក្រោយពេលសម្រាល | ទេ | បាទ/ចាស់ | មិនដឹង | |
| **ផ្នែកទី ៨ ៖ ទារកទើបនឹងកើត ( ក្រោម ២៨ ថ្ងៃ )** | | | | |
| 8.1 ការសម្រាលរស់ ឬទារកស្លាប់កើត<br>Live birth of stillbirth | កើតមករស់<br>( Livebirth ) | ស្លាប់កើត<br>( Stillbirth ) | មិនដឹង | |
| | បើស្លាប់កើត<br>( stillbirth ) | ស្លាប់កើតស្រស់ៗ/ជុំវិញពេលសម្រាល | ស្លាប់កើត ទន់ជ្រាយ / មុនពេលសម្រាល | |
| 8.1 ពិន្ទុអាប់ហ្គា | ១ នាទី = | ៥ នាទី = | ១០ នាទី = | |
| 8.2 ការសង្គ្រោះទារក | មិនត្រូវការ | ថង់ + ម៉ាស់ | មិនបានធ្វើ | ផ្សេងទៀត៖ |
| 8.3 ភេទរបស់ទារក | ប្រុស | ស្រី | | |
| 8.4 ទម្ងន់ពេលកើត | _________ក្រាម | | | |
| **ផ្នែកទី ៩ ៖ អន្តរាគមន៍** | | | | |
| 9.1 គភ៌កូនដំបូង | | | | |
| ការសម្អាតស្បូនដោយឧបករណ៍ | ទេ | បាទ/ចាស់ | មិនដឹង | |
| Misoprostol ( ឱសថ ) | ទេ | បាទ/ចាស់ | មិនដឹង | |
| ការវះពោះ | ទេ | បាទ/ចាស់ | មិនដឹង | |
| ការកាត់ស្បូន | ទេ | បាទ/ចាស់ | មិនដឹង | |
| ការកាត់ដៃស្បូន ( Salpingectomy ) | ទេ | បាទ/ចាស់ | មិនដឹង | |
| ការបញ្ចូលឈាម | ទេ | បាទ/ចាស់ | មិនដឹង | |
| អង់ប៊ីយ៉ូទិក | ទេ | បាទ/ចាស់ | មិនដឹង | |
| ផ្សេងទៀត | ទេ | បាទ/ចាស់ | មិនដឹង | |
| 9.2 មុនពេលសម្រាល | | | | |
| ការបញ្ចូលឈាម | ទេ | បាទ/ចាស់ | មិនដឹង | |
| ស្បូនពន្លាត់ ( Version ) | ទេ | បាទ/ចាស់ | មិនដឹង | |
| ការជំរុញការឈឺពោះ ( Labour induction ) | ទេ | បាទ/ចាស់ | មិនដឹង | |
| ម៉ាញ៉េស្យូមស៊ុលហ្វាត ( Magnesium sulfate ) | ទេ | បាទ/ចាស់ | មិនដឹង | |
| អង់ទីប៊ីយ៉ូទិក | ទេ | បាទ/ចាស់ | មិនដឹង | |
| ផ្សេងទៀត | ទេ | បាទ/ចាស់ | មិនដឹង | |
| 9.3 ជុំវិញពេលសម្រាល | | | | |
| ការបង្កើនការឈឺពោះសម្រាល ( Labour augmentation ) | ទេ | បាទ/ចាស់ | មិនដឹង | |
| ការវះកាត់ឆ្អឹងសន្លាក់ត្រគាក ( Symphysiotomy ) | ទេ | បាទ/ចាស់ | មិនដឹង | |
| ការកាត់ស្បូន | ទេ | បាទ/ចាស់ | មិនដឹង | |
| ការបញ្ចូលឈាម | ទេ | បាទ/ចាស់ | មិនដឹង | |
| ម៉ាញ៉េស្យូមស៊ុលហ្វាត ( Magnesium sulfate ) | ទេ | បាទ/ចាស់ | មិនដឹង | |
| អង់ទីប៊ីយ៉ូទិក | ទេ | បាទ/ចាស់ | មិនដឹង | |
| ប្រតិបត្តិការដែលបង្កការខូចខាត ( Destructive operations ) ( ឧទា. ការចោះលលាដ៍ក្បាល | ទេ | បាទ/ចាស់ | មិនដឹង | |

| | | | | |
|---|---|---|---|---|
| ទារក ( craniotomy ) ) | | | | |
| ផ្សេងទៀត | ទេ | បាទ/ចាស៎ | មិនដឹង | |
| 9.4 ក្រោយពេលសម្រាល | | | | |
| ការវះពោះ ( Laparotomy ) | ទេ | បាទ/ចាស៎ | មិនដឹង | បញ្ជាក់: |
| ការកាត់ស្បូន | ទេ | បាទ/ចាស៎ | មិនដឹង | |
| ការបញ្ចូលឈាម | ទេ | បាទ/ចាស៎ | មិនដឹង | |
| ម៉ាញ៉េស្យូមស៊ុលហ្វាត ( Magnesium sulfate ) | ទេ | បាទ/ចាស៎ | មិនដឹង | |
| អង់ទីប៊ីយ៉ូទិក ( Antibiotics ) | ទេ | បាទ/ចាស៎ | មិនដឹង | |
| អុកស៊ីតូស៊ីន ( Oxytocin ) | ទេ | បាទ/ចាស៎ | មិនដឹង | |
| Misoprostol | ទេ | បាទ/ចាស៎ | មិនដឹង | |
| ផ្សេងទៀត | ទេ | បាទ/ចាស៎ | មិនដឹង | |
| 9.5 អន្តរាគមន៍ផ្សេងទៀត | | | | |
| ថ្នាំសណ្តំទូទៅ | ទេ | បាទ/ចាស៎ | មិនដឹង | |
| ថ្នាំសណ្តំតាមខ្នង ឬឆ្អឹងខ្នង | ទេ | បាទ/ចាស៎ | មិនដឹង | |
| ការដាក់អុកស៊ីសែនជំនួយដង្ហើម ( ICU ventilation ) | ទេ | បាទ/ចាស៎ | មិនដឹង | |
| ផ្សេងទៀត | ទេ | បាទ/ចាស៎ | មិនដឹង | |
| **ផ្នែកទី ១០ ៖ ការពន្យារពេលសំខាន់ៗ និងកត្តាដែលអាចកែតម្រូវបាន** | | | | |
| 10.1 ការពន្យារពេលសំខាន់ៗ | | | | |
| ការពន្យារពេលទី ១ ៖ យឺតក្នុងការស្គាល់ពីបញ្ហា និងសម្រេចចិត្តមកទទួលសេវា | មិនត្រូវបានកំណត់ | បញ្ជាក់៖ | | |
| ការពន្យារពេលទី ២ ៖ការទៅដល់មូលដ្ឋានសុខាភិបាល | មិនត្រូវបានកំណត់ | បញ្ជាក់៖ | | |
| ការពន្យារពេលទី ៣ ៖ ទទួលបានការព្យាបាលទាន់ពេល | មិនត្រូវបានកំណត់ | បញ្ជាក់៖ | | |
| 10.2 កត្តាដែលអាចកែតម្រូវបាន | | | | |
| ទាក់ទងនឹងគ្រួសារ | មិនត្រូវបានកំណត់ | បញ្ជាក់៖ | | |
| ទាក់ទងនឹងរដ្ឋបាល | មិនត្រូវបានកំណត់ | បញ្ជាក់៖ | | |
| ទាក់ទងនឹងអ្នកផ្តល់សេវា | មិនត្រូវបានកំណត់ | បញ្ជាក់៖ | | |
| ផ្សេងទៀត ______________ | មិនត្រូវបានកំណត់ | បញ្ជាក់៖ | | |

c/s: ការសម្រាលដោយវះកាត់; CVD: cephalic vaginal childbirth; ELBW: ទម្ងន់ពីកំណើតទាបខ្លាំងបំផុត ( extremely low birthweight ); EmOC: emergency obstetric care ( ការសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងថែទាំទារកទើបនឹងកើត ); HAART: highly active antiretroviral therapy ( ការព្យាបាលដោយឱសថប្រឆាំងវីរុសដែលសកម្មខ្លាំង ); HIV: human immunodeficiency virus ( មេរោគដែលធ្វើឱ្យចុះខ្សោយប្រព័ន្ធភាពស៊ាំរបស់មនុស្ស; IPT: intermittent preventive treatment ( ការព្យាបាលបង្ការគ្រុនចាញ់សម្រាប់ស្ត្រីមានផ្ទៃពោះ ); LBW: low birthweight ( ទម្ងន់ទាបពីកំណើត ); LMP: last menstrual period ( រដូវចុងក្រោយ ); NVP: nevirapine prophylaxis; TT: tetanus toxoid ( តេតាណូស ); VLWB: very low birthweight ( ទម្ងន់ពេលកើតទាបខ្លាំង )

## ឧបសម្ព័ន្ធទី ៤ ៖ ទម្រង់ពិនិត្យករណីមរណភាពទារកជុំវិញការសម្រាល

ទម្រង់បំពេញដោយ ៖ ________________ មុខតំណែង ៖________________ ថ្ងៃខែឆ្នាំ ៖ ______________

| សេចក្ដីសង្ខេបអំពីករណី ៖ |
|---|
| |

| | | | | | |
|---|---|---|---|---|---|
| **ផ្នែកទី ១ ៖ ការកំណត់អត្តសញ្ញាណ** | | | | | |
| 1.1 លេខអត្តសញ្ញាណ/ឈ្មោះពេញរបស់ម្ដាយ | | | | | |
| 1.2 លេខអត្តសញ្ញាណ/ឈ្មោះពេញរបស់ទារក | | | | | |
| 1.3 អាសយដ្ឋានរបស់ម្ដាយ | | | | | |
| 1.4 ឈ្មោះមូលដ្ឋានសុខាភិបាល ៖ | | | | | |
| 1.5 ស្រុក និងខេត្ត នៃមូលដ្ឋានសុខាភិបាល | ស្រុក ៖ | ខេត្ត ៖ | | | |
| 1.6 កម្រិត នៃមូលដ្ឋានសុខាភិបាល | | | | | |
| 1.7 បានបញ្ជូន | មិនបានបញ្ជូន | បញ្ជូនមកពី៖ | | | |
| | | បញ្ជូនចេញទៅ៖ | | | |
| **ផ្នែកទី ២ ៖ ព័ត៌មានសាវតា** | | | | | |
| 2.1 ប្រវត្តិសម្ភព | ចំនួនគភ៌សរុប (Gravidity) ៖ | ចំនួនកូនសរុប (Parity): | | | |
| | កំណើតរស់ (Live births): | ករណីស្លាប់កើត (Stillbirths): | ករណីមរណភាពទារកទើបនឹងកើត (Neonatal deaths): | ករណីស្លាប់ផ្សេងទៀត ៖ | |
| 2.1a ការសម្រាលដោយវះកាត់ពីមុន | គ្មាន | ចំនួន៖ | ថ្ងៃខែឆ្នាំនៃការសម្រាលដោយវះកាត់ថ្មីៗបំផុត៖ | | |
| 2.1b ផលវិបាកនៃពពោះពីមុន | គ្មាន | ថ្ងៃខែឆ្នាំ៖ | ពណ៌នា៖ | | |
| 2.2 អាយុរបស់ម្ដាយ | | | | | |

| | | | | | |
|---|---|---|---|---|---|
| 2.3 ការអប់រំរបស់ម្ដាយ | គ្មាន | ចំនួនឆ្នាំ នៃការអប់រំ៖ | | | |
| 2.4 ស្ថានភាពអាពាហ៍ពិពាហ៍ | នៅលីវ | រៀបការ | មេម៉ាយ | | |
| | លែងលះ | នៅបែកគ្នា | រស់នៅជាមួយគ្នា | | |
| 2.5 ការប្រើប្រាស់មធ្យោបាយពន្យារកំណើតមុនពេលមានគភ៌ | ទេ | បាទ/ចាស៎ | បើបាទ/ចាស៎ តើប្រភេទអ្វី | | |
| **ផ្នែកទី ៣ ៖ ព័ត៌មានលម្អិតអំពីការស្លាប់** | | | | | |
| 3.1 ថ្ងៃខែឆ្នាំ នៃការស្លាប់ | | ពេលវេលា នៃការស្លាប់ | | | |
| 3.2 ពេលវេលា នៃការស្លាប់ (គូសរង្វង់យកមួយ) | ការស្លាប់របស់ទារកទើបនឹងកើត | ស្លាប់កើតជុំវិញការសម្រាល (Intrapartum stillbirth) | ស្លាប់កើតមុនពេលសម្រាល (Antepartum stillbirth) | ស្លាប់កើត មិនដឹងពេលវេលា | |
| បើទារកទើបនឹងកើតស្លាប់ អាយុគិតជាថ្ងៃ៖ | | | | | |
| បើទារកស្លាប់កើត អាយុគភ៌គិតជាសប្ដាហ៍ | | | | | |
| 3.3 ទីកន្លែងស្លាប់ | មូលដ្ឋានសុខាភិបាល | ផ្ទះ | តាមផ្លូវ | ផ្សេងទៀត សូមបញ្ជាក់ | |
| | មិនដឹង | | | | |
| | បើនៅមូលដ្ឋានសុខាភិបាល សូមបញ្ជាក់ឈ្មោះ៖ | | បញ្ជាក់ផ្នែក/អគារ៖ | | |
| 3.4 លក្ខខណ្ឌមាតាចម្បង (ICD-11) | M1 | M2 | M3 | M4 | M5 |
| | ផ្សេងទៀត | មិនដឹង | | | |
| 3.5 មូលហេតុ នៃការស្លាប់ | | | | | |
| a. ពីកំណើត (Congenital) | បញ្ជាក់៖ | | | | |
| b. ផលវិបាកមុនពេលសម្រាល (antepartum complications) | បញ្ជាក់៖ | | | | |
| c. ផលវិបាកជុំវិញពេលសម្រាល (intrapartum complications) | បញ្ជាក់៖ | | | | |
| d. ផលវិបាកនៃការកើតមិនគ្រប់ខែ (complications of prematurity) | បញ្ជាក់៖ | | | | |
| e. ការបង្ករោគ | តេតាណូស | មេរោគយាយី | រលាកស្រោមខួរ | ស្វាយ | រាក |
| | ផ្សេងទៀត សូមបញ្ជាក់ | | | មិនដឹង | |
| f. ផ្សេងទៀត សូមបញ្ជាក់ | | | | | |
| g. មិនដឹង/មិនបញ្ជាក់ | | | | | |
| **ផ្នែកទី ៤ ៖ ការមានគភ៌ និងការថែទាំផ្ទៃពោះមុនពេលសម្រាល** | | | | | |
| 4.6 ប្រភេទ នៃគភ៌ | កូនទោល | កូនច្រើន = | មិនដឹង | | |
| 4.7 ការថែទាំមុនពេលសម្រាល | | | | | |
| 4.7a ចំនួនដងនៃការមកពិនិត្យ | __________ | មិនដឹង | | | |
| 4.7b អាយុគភ៌នៅពេលមកពិនិត្យលើកទីមួយ | __________ | មិនដឹង | | | |
| 4.8 ការចាក់ថ្នាំបង្ការតេតាណូស | | | | | |

| | | | | | |
|---|---|---|---|---|---|
| 4.9 ស្ថានភាពមេរោគអេដស៍ | មេរោគអេដស៍-អវិជ្ជមាន | មេរោគអេដស៍-វិជ្ជមាន | មិនបានធ្វើ | មិនដឹង | |
| 4.9.1 វិធានការមេរោគអេដស៍-វិជ្ជមាន | | HAART | ផ្សេងទៀត សូមបញ្ជាក់៖ | | |
| 4.10 ស្ថានភាពរបេង | Tb-អវិជ្ជមាន | Tb-វិជ្ជមាន | ការព្យាបាល៖ | | |
| 4.11 តេស្តស្វាយ | អវិជ្ជមាន | ស្វាយ-វិជ្ជមាន | មិនបានធ្វើ | មិនដឹង | |
| **ផ្នែកទី ៥ ៖ ការឈឺពោះសម្រាល និងការសម្រាល** | | | | | |
| 5.1 រដូវចុងក្រោយរបស់ម្តាយ | ថ្ងៃ | ខែ | ឆ្នាំ | មិនដឹង | |
| 5.2 ថ្ងៃខែឆ្នាំសម្រាល | ថ្ងៃ | ខែ | ឆ្នាំ | | |
| 5.2.1 ពេលវេលាសម្រាល | | | | | |
| 5.3 អាយុគភ៌ | | unknown | | | |
| 5.3.1 វិធីសាស្រ្ត នៃការកំណត់ | ថ្ងៃខែឆ្នាំរដូវចុងក្រោយច្បាស់ | ថ្ងៃខែឆ្នាំរដូវចុងក្រោយមិនច្បាស់ | អេកូពីដំបូង | អេកូពេលក្រោយមកទៀត | |
| 5.4 ទីកន្លែងសម្រាល | មូលដ្ឋានសុខាភិបាល | ផ្ទះ | តាមផ្លូវ | ផ្សេងទៀត សូមបញ្ជាក់ | |
| | មិនដឹង | | | | |
| | បើនៅមូលដ្ឋានសុខាភិបាល សូមបញ្ជាក់៖ | | | | |
| 5.4.1 អ្នកជួយសម្រាល | ឆ្មប | គិលានុបដ្ឋាក | វេជ្ជបណ្ឌិត | ផ្សេងទៀត៖ | |
| | គ្មាននរណាជួយ | មិនដឹង | | | |
| 5.5 ការចាប់ផ្តើមឈឺពោះ | ដោយឯកឯង | ដោយជំរុញ | វះកាត់/មុនពេលចាប់ផ្តើមឈឺពោះ | មិនដឹង | |
| 5.6 ចង្វាក់បេះដូងទារក | ទេ | បាទ/ចាស៎ | មិនដឹង | | |
| 5.7 ប៉ាតូក្រាហ្វត្រូវបានប្រើប្រាស់ | ទេ | បាទ/ចាស៎ | មិនដឹង | | |
| 5.8 វិធីនៃការសម្រាល | CVD | ជើង/ក្បាលមកមុនតាមទ្វារមាស | សម្រាលដោយមានជំនួយ (បូម/ដង្កៀបទាញ) | ដោយវះកាត់ | |
| | ផ្សេងទៀត៖ | មិនដឹង | | | |
| ក្នុងករណីសម្រាលដោយមានជំនួយ ពេលវេលារវាងការសម្រេចចិត្ត និងការសម្រាល | _________នាទី | មិនដឹង | n/a | | |
| ក្នុងករណីសម្រាលដោយវះកាត់ ពេលវេលារវាងការសម្រេចចិត្តនិងការសម្រាល | _________នាទី | មិនដឹង | n/a | | |
| 5.10 ពិន្ទុអាប់ហ្គា | ១ នាទី= | មិនដឹង | | | |
| | ៥ នាទី= | មិនដឹង | | | |
| | ១០ នាទី= | មិនដឹង | | | |
| 5.11 ការសង្គ្រោះទារក | មិនត្រូវការ | ថង់/ស្នប់ + ម៉ាស់ | មិនបានធ្វើ | ផ្សេងទៀត៖ | |
| 5.12 ភេទរបស់ទារក | ប្រុស | ស្រី | | | |
| 5.13 ទម្ងន់ពេលកើត | _________ក្រាម | | | | |
| **ផ្នែកទី ៦ ៖ ការពន្យារពេលសំខាន់ៗ និងកត្តាដែលអាចកែតម្រូវបាន** | | | | | |
| 6.1 ការពន្យារពេលសំខាន់ៗ | | | | | |
